២

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

ពុទ្ធសាសនបណ្ឌិត្យ
INSTITUT BOUDDHIQUE

ឆ្នាំទី ៣៨ ខែ កុម្ភៈ

ព.ស. ២៥០៨ គ.ស. ១៩៦៦

– ភ្នំពេញ –

ទំហំ 160 x 245

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

ចេញរាល់ខែ ពីពុទ្ធសាសនបណ្ឌិត្យ

## របាញ្ជីរឿង

*ផ្នែកសាសនា* — *ទំព័រ*

១ នមត្ថុ រតនត្តយស្ស ពុទ្ធកិច្ច ព្រះសាសនមុនី កិម-ត្ទួរ រៀបរៀង (តចប់) . . . ១២១

២— មកពីហេតុអ្វី បានជាមនុស្សធ្វើអំពើអាក្រក់កើត? លោក ប៊ូ-ប៉ូ រៀបរៀង . . ១៣៨

*ផ្នែកអក្សរសាស្ត្រ*

៣ វចនានុក្រម សំស្ក្រឹត-ខ្មែរ ព្រះមហា ប៉ាង—ខាត់ រៀបរៀង (ត) . . ១៦០

៤— ព្រះរាជនិពន្ធរាមកេរ្តិ៍ លោក ឌ. គាម ស្រាវជ្រាវ (ត) . . . . . ១៦២

៥— រឿងសាមកុក អ្នកឧកញ៉ាវិបុលរាជសេនា នូ កន ប្រែរៀបរៀង(ត) . . . ១៧៨

៦— ឯកសារ សាស្ត្រាស្ទឹករីតនិងក្រាំង លោក ញ៉ុក-ថែម រៀបរៀង (ត) . . . ១៨៨

៧ អធិប្បាយភាសិត ពាក្យកាព្យ បណ្ឌិតមហា ឈឹម-ស៊ុម សាស្ត្រាចារ្យ (ត) . ១៩៥

៨— ឯកសារ កម្ពុជសុរិយា លោក ឌ-គាម ប្រមូលរៀបរៀង (ត) . . . . ២១១

*ផ្នែកកំណត់និងប្រវត្តិការណ៍*

៩— ពិធីប្រគល់ព្រះរាជអំណោយ នៃសម្ដេចព្រះប្រមុខរដ្ឋ ចំពោះពុទ្ធិកវិទ្យាល័យ . . . ២២៧

មួយឆ្នាំមាន ១២ សៀវភៅ តម្លៃជាវ ២៣០៖០០ ៛

# សូមព្រះតេជៈដ៏កល់លើត្បូង
# សូមព្រះរាជទានក្រាបបង្គំទូលក្រោមល្អងធូលីព្រះបាទ
# នៃសម្តេចព្រះមហាក្សត្រិយានី ជាម្ចាស់ជីវិតលើត្បូង

សូមទ្រង់ជ្រាប ។

"តាមរយៈឯកឧត្តម រដ្ឋមន្ត្រីក្រសួងធម្មការ"

ក្នុងឱកាសអភិលក្ខិតសម័យ នៃពិធីចម្រើនព្រះជន្មវស្សាសម្តេចជាអម្ចាស់ជីវិត លើត្បូង និងក្នុងមហានក្ខត្តឫក្សសម័យ នៃពិធីចូលឆ្នាំ មមី អដ្ឋស័ក ព.ស. ២៥០៩ នេះ

ទូលព្រះបង្គំជាខ្ញុំ តាំងនាមព្រះសង្ឃជាសមាជិកទាំងអស់ នៃក្រុមជំនុំព្រះត្រៃបិដក ដែលមានសម្តេចព្រះពោធិវង្ស ហួត-តាត ជាអធិបតី ព្រះតេជៈព្រះគុណព្រះមុនីកោសល សូរ-ហាយ ជាអធិបតីរង និងតាំងនាមបុគ្គលិកធ្វើការក្នុងវិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យ នៃក្រសួងធម្មការ ក្រោមឱវាទនៃឯកឧត្តម ទ្រិញ-រ៉ាញ ជាអនុរដ្ឋលេខាធិការ

សូមព្រះរាជទានព្រះបរមរាជវរោកាស ក្រាបបង្គំទូលថ្វាយ នូវព្រះសព្ពសាធុការពរ សិរីសួស្តីជោគជ័យមង្គល វិបុលសុខមហាប្រសើរ ចំពោះសម្តេចជាអម្ចាស់ជីវិតលើត្បូង សូមគុណបុណ្យព្រះរតនត្រ័យ គុណទេវតាឆ្មាំថ្មី និងគុណវត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងសកលលោក សូមមេត្តាជួយអភិបាលរក្សាសម្តេចជាអម្ចាស់ជីវិត សូមព្រះអង្គទ្រង់គង់នៅក្នុងព្រះបរមសុខ ប្រកបដោយព្រះសុខភាពបរិបូណ៌ មានព្រះជន្មាយុ

ជាន់រយព្រះវស្សា ដើម្បីទ្រង់គង់នៅជាម្លប់ដ៏ត្រជាក់ ពន្លាកពន្លឺជាទីជ្រកកោន នៃកូនចៅព្រះអង្គគ្រប់ ៗ កាយ ។

ដើម្បីជាការតបស្នងព្រះមហាករុណាធិគុណដ៏ឧត្តម ចំពោះសម្តេចជាអម្ចាស់ជីវិត ដែលទ្រង់ជាព្រះអគ្គពុទ្ធសាសនូបត្ថម្ភក៍ ទូលព្រះបង្គំជាខ្ញុំសូមព្រះរាជទានក្រាបបង្គំទូលថ្វាយ ក្នុងឱកាសនេះ នូវគម្ពីរព្រះត្រៃបិដក ដែលជាលទ្ធផលនៃការងាររបស់ក្រុមជំនុំព្រះត្រៃបិដក នៃវិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យ ក្រសួងធម្មការ ចំនួនប៉ែតសិបបួន ក្បាល គឺពី ភាគ ១ ដល់ ៨៤ ដើម្បីថ្វាយព្រះអង្គទ្រង់រក្សាទុកជាព្រះរាជទ្រព្យផ្ទាល់ព្រះអង្គ ។ ឯភាគជាបន្ត ១ ទៅទៀត ដែលនឹងចេញផ្សាយនៅពេលក្រោយ ទូលព្រះបង្គំជាខ្ញុំ នឹងក្រាបបង្គំទូលថ្វាយសម្តេចជាអម្ចាស់ ជាលំដាប់ដរាបដល់ចប់ ។

ទូលព្រះបង្គំជាខ្ញុំទាំងអស់ជាកូនចៅ សូមឧទ្ទិសជាបង្សុកូលសាមគ្គីជុំវិញព្រះរាជបល្ល័ង្ក និងអង្គសម្តេចព្រះមហាក្សត្រិយានីជាអម្ចាស់ជីវិត ព្រមទាំងអង្គសម្តេចព្រះឧបយុវរាជ ព្រះប្រមុខរដ្ឋ ដោយសូមព្រះរាជទានក្រាបបង្គំទូលថ្វាយ នូវសេចក្តីស្មោះត្រង់ ស្វាមីភក្តិ ចំពោះល្អងធូលីព្រះបាទលុះទីអវសាន ។

គួរពុំគួរសូមព្រះករុណាទ្រង់ព្រះមេត្តាប្រោស

សូមព្រះរាជទានក្រាបបង្គំទូលថ្វាយ នៅថ្ងៃទី ២៥ មីនា ១៩៦៦

ទូលព្រះបង្គំជាខ្ញុំ ណាង-ហ៊ាបអាង

នាយកវិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យ នៃក្រសួងធម្មការ

# សូមក្រាបបង្គំទូល
# សម្ដេចសហជីវិន ព្រះប្រមុខរដ្ឋ

សូមទ្រង់ជ្រាប ។

« តាមរយៈឯកឧត្ដម រដ្ឋមន្ត្រីក្រសួងធម្មការ »

សូមទ្រង់ព្រះមេត្តាប្រោស

ក្នុងឱកាសមហានក្ខត្តឫក្សនៃពិធីចូលឆ្នាំ មមី អដ្ឋស័ក ព.ស. ២៥០៩ នេះ

ទូលព្រះបង្គំ តាងនាមព្រះសង្ឃជាសមាជិកទាំងអស់ នៃក្រុមជំនុំព្រះត្រៃបិដក ដ៏មានសម្ដេចព្រះពោធិវង្ស ហួត-តាត ជាអធិបតី ព្រះតេជះព្រះគុណព្រះមុនីកោសល សួរ-ហាយ ជាអធិបតីរង និងតាងនាមបុគ្គលិកធ្វើការក្នុងវិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យ នៃក្រសួងធម្មការ ក្រោមឱវាទនៃឯកឧត្ដម ទ្រឹញ-ហ៊ុញ ជាអនុរដ្ឋលេខាធិការ

សូមព្រះវរកាយក្រាបបង្គំទូលថ្វាយ នូវសព្ទសាធុការពរ សិរីសួស្ដី ជោគជ័យមង្គល វិបុលសុខមហាប្រសើរ ចំពោះសម្ដេចជាអម្ចាស់ ព្រមទាំងព្រះរាជវង្សានុវង្សទាំងអស់ សូមគុណបុណ្យព្រះរតនត្រ័យ គុណទេវតាឆ្មាំជី និងគុណវត្ថុស័ក្ដិសិទ្ធិទាំងឡាយក្នុងសកលលោក សូមមេត្តាជួយអភិបាលរក្សាសម្ដេចជាអម្ចាស់ សូមព្រះអង្គទ្រង់គង់នៅក្នុងព្រះបរមសុខ ប្រកបដោយព្រះសុខភាពបរិបូណ៌ជានិច្ចនិរន្តរ មានព្រះជន្មាទីឃាយុជាងរយព្រះវស្សា ដើម្បីទ្រង់គង់នៅជាម្លប់ដ៏ត្រជាក់ ពំនាក់ពំនឹង ជាទីពឹងជ្រកកោន នៃកូនចៅព្រះអង្គគ្រប់ៗកាយ ។

ដើម្បីជាការតបស្នងសងព្រះមហាករុណាធិគុណដ៏ឧត្តម ចំពោះសម្តេចជាអម្ចាស់ ដែលទ្រង់ជាព្រះអគ្គពុទ្ធសាសនូបត្ថម្ភក៏ដ៏ធំ ខ្ញុំព្រះបង្គំ សូមក្រាបបង្គំទូលថ្វាយក្នុងឱកាសនេះ នូវសៀវភៅគម្ពីរព្រះត្រៃបិដក ដែលជាលទ្ធផលនៃការងាររបស់ក្រុមជំនុំព្រះត្រៃបិដក នៃវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ក្រសួងធម្មការ ចំនួន ប៉ែតសិបបួន ក្បាល " គឺពីភាគ ១ ដល់ ៨៤ " ដើម្បីថ្វាយព្រះអង្គទ្រង់រក្សាទុកជាព្រះរាជទ្រព្យផ្ទាល់ព្រះអង្គ ។ ឯភាគជាបន្ត ១ ទៅទៀត ដែលនឹងចេញផ្សាយនៅពេលក្រោយ ខ្ញុំព្រះបង្គំ នឹងក្រាបបង្គំទូលថ្វាយសម្តេចជាអម្ចាស់ ជាលំដាប់ដរាបដល់ចប់ ។

ខ្ញុំព្រះបង្គំទាំងអស់ជាកូនចៅ សូមប្តេជ្ញាចិត្តជាប់បរបួរសាមគ្គីជុំវិញព្រះរាជបល្ល័ង្ក និងអង្គសម្តេចឪ ដោយកម្លាំងជាមួយព្រះរាជវេជ្ជកិច្ចបាលសង្គម ដផ្លែតាមព្រះមាគ៌ានយោបាយដ៏ត្រឹមត្រូវ នៃសម្តេចជាអម្ចាស់ គ្រប់កាលៈទេសៈ ព្រមទាំងសូមក្រាបបង្គំទូលថ្វាយនូវសេចក្តីស្មោះត្រង់ ស្វាមីភក្តិ ចំពោះត្រៃបាវចនា គឺ ជាតិ សាសនា ព្រះរាជបល្ល័ង្ក ដ៏មានសម្តេចព្រះមហាក្សត្រិយានីជាអម្ចាស់ជីវិត ជាព្រះនិមិត្តរូប លុះទីអវសានឥតរួញរាឡើយ ។

គួរពុំគួរសូមទ្រង់ព្រះមេត្តាប្រោស

សូមក្រាបបង្គំទូលថ្វាយ នៅថ្ងៃទី ២៤ មីនា ១៩៦៦

ខ្ញុំព្រះបង្គំ លាង-ហាបអាន

នាយកវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ នៃក្រសួងធម្មការ

# ផ្នែកសាសនា

> ពាក្យឃាត់មិនឲ្យ ធ្វើការអាក្រក់
> ជាការលាមក, ឲ្យធ្វើល្អទៅ,
> ឲ្យជ្រះស្អាតចិត្ត កុំឲ្យហ្មងសៅ,
> បីនេះលោកហៅ ពុទ្ធសាសនា ។
>
> ប.ព.

## ពុទ្ធកិច្ច

(ត បប់)

### ពុទ្ធុបដ្ឋាក

*ភិក្ខុអ្នកបម្រើព្រះពុទ្ធ*

ព្រះសាសនមុនី កិម-គួរ រៀបរៀង

*ព្រះសម្មាសម្ពុទ្ធបរមគ្រូនៃយើង ដែលទ្រង់បានត្រាស់ដឹងហើយនៅក្នុងរវាងបឋមពោធិកាល តាំងពីវស្សាទី ១ ដល់វស្សាទី ១៩ ឬទី ២០ មានភិក្ខុជាឧបដ្ឋាកអ្នកបម្រើព្រះអង្គមិនជាប់ មិនទៀងទាត់ទេ ដូនកាល នាគសមាលភិក្ខុបម្រើ, ដូនកាល នាគិតភិក្ខុបម្រើ, ដូនកាល ឧបវាណភិក្ខុបម្រើ, ដូនកាល សុនក្ខត្តភិក្ខុបម្រើ, ដូនកាល ចុន្ទសាមណេរបម្រើ, ដូនកាល សាគតភិក្ខុបម្រើ, ដូនកាល រាធភិក្ខុបម្រើ, ដូនកាល មេឃិយភិក្ខុបម្រើ ។ ភិក្ខុជាឧបដ្ឋាកទាំងអស់នេះពុំសូវឈ្លាសវៃក្នុងការបម្រើឲ្យបានជិតដល់ នាំឲ្យព្រះអង្គមានការលំបាកមួយដងមួយកាលក៏មាន ដូចឧបវាណភិក្ខុជាដើម បម្រើដោយធ្វើកិច្ចត្រឹមតែ ៤ យ៉ាង គឺ ១- បោសសំអាតទីខាងក្នុងគន្ធកុដិ*

ទិងទីជាបរិវេណខាងក្រៅនៃគន្ធកុដិ, ២-ថ្វាយទឹកនិងឈើស្ទន់, ៣-ថ្វាយទឹកសម្រាប់ស្រង់, ៤- កាន់បាត្រនិងចីវរជូនព្រះដំណើរព្រះអង្គទៅកាន់ទីដទៃប៉ុណ្ណោះ ឯកិច្ចក្រៅពីនេះ ពុំសូវយល់ឡើយ ។ ដូចកាលគ្រាមួយព្រះភគវ័ត ទ្រង់យាងទៅកាន់ផ្លូវឆ្ងាយជាមួយនឹងនាគសមាលភិក្ខុ, លុះយាងទៅដល់ត្រង់ផ្លូវបែកជាពីរ, នាគសមាលភិក្ខុគេចចេញអំពីផ្លូវ ក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស, ខ្ញុំព្រះអង្គនឹងទៅតាមផ្លូវនេះ ។ ព្រះភគវ័ត ទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកចូលមកខាងណេះ កុំទៅតាមផ្លូវនោះ, យើងទៅតាមផ្លូវនេះវិញ ។ នាគសមាលភិក្ខុ ក្រាបទូលថា បើដូច្នោះ សូមព្រះអង្គកាន់យកបាត្រនិងចីវររបស់ព្រះអង្គទៅចុះ ឯខ្ញុំព្រះអង្គទៅតាមផ្លូវនេះហើយ លុះក្រាបទូលដូច្នោះហើយ ក៏ប្រារព្ធដាក់បាត្រនិងចីវររបស់ព្រះអង្គលើផែនដី ។ ខណៈនោះ ព្រះសម្ពុទ្ធទ្រង់ត្រាស់ថា នែភិក្ខុ ចូរអ្នកយកបាត្រនិងចីវរមកឲ្យតថាគត ។ នាគសមាលភិក្ខុនាំយកបាត្រនិងចីវរមកថ្វាយព្រះអង្គ ។ ក៏ទ្រង់កាន់យកបាត្រនិងចីវរយាងទៅ ។ នាគសមាលភិក្ខុ ដើរទៅតាមផ្លូវដែលខ្លួនត្រូវការទៅនោះ ។ ពួកចោរឃើញហើយ ក៏នាំគ្នាចូលដណ្ដើមយកបាត្រនិងចីវរផង វាយសីសៈនៃនាគសមាលភិក្ខុបែកចេញឈាមហូរស្រោកផង ទើបនាគសមាលភិក្ខុនោះគិតថា ឥឡូវនេះ មានតែព្រះមានព្រះភាគទេ ជាទីពឹងរបស់អាត្មាអញ ឯបុគ្គលដទៃ មិនមែនជាទីពឹងរបស់អាត្មាអញឡើយ ហើយក៏ទៅកាន់សំ-

ណាក់ព្រះតថាគត ដោយមានឈាមកំពុងហូរចេញសស្រាក់, ព្រះសម្ពុទ្ធទ្រង់ទតឃើញក៏ត្រាស់សួរថា នែភិក្ខុ ហេតុអ្វីក៏បានទៅជាយ៉ាងនេះ? នាគសមាលភិក្ខុ បានក្រាបទូលព្រះអង្គតាមដំណើរនោះ ដោយសព្វគ្រប់ ទើបព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងកុំគិត កុំអាក់អន់តូចចិត្តឡើយ ព្រោះតែហេតុនេះហើយ បានជាតថាគតឃាត់អ្នកថា កុំឲ្យទៅតាមផ្លូវនោះ ។

មិនតែប៉ុណ្ណោះទេ គ្រាមួយ ព្រះតថាគត ទ្រង់យាងទៅកាន់ជន្តុគ្រាមក្នុងបាចីនវំសមិគទាយវ័ន ជាមួយនឹងមេឃិយភិក្ខុ ។ នៅក្នុងទីនោះ មេឃិយភិក្ខុ ត្រាច់ទៅបិណ្ឌបាត្រក្នុងជន្តុគ្រាម បានឃើញអម្ពវ័ន (ព្រៃស្វាយ) មួយ គួរជាទីជ្រះថ្លា ដែលជិតនៅទៀបឆ្នេរស្ទឹង ហើយក្រាបទូលព្រះអង្គថា សូមទ្រង់ព្រះមេត្តាប្រោស, សូមព្រះអង្គទទួលយកបាត្រនិងចីវររបស់ព្រះអង្គទៅវិញចុះ, ខ្ញុំព្រះអង្គសុំទៅធ្វើសមណធម៌ក្នុងអម្ពវ័ននោះហើយ ។ ព្រះសម្ពុទ្ធទ្រង់ឃាត់អស់វារៈ ៣ ដងថា ម្នាលមេឃិយៈ អ្នកកុំអាលទៅបោលតថាគត ឲ្យតថាគតនៅតែម្នាក់ឯងឡើយ, ចូរអ្នកនៅរង់ចាំបន្តិចទៅសិន ទំរាំនឹងមានភិក្ខុដទៃណាមួយ មកនៅជាមួយតថាគត ហើយ សឹមអ្នកទៅចុះ ។ មេឃិយភិក្ខុ ទោះបីព្រះអង្គទ្រង់ត្រាស់ឃាត់យ៉ាងណាក៏ដោយ នៅតែទទូចដំនះទៅទាល់តែបាន, លុះដល់ចូលទៅធ្វើសមណធម៌ក្នុងអម្ពវ័ននោះ ក៏ត្រូវអកុសលវិតក្កៈទាំងឡាយ កើតឡើង

គ្រប់សង្កត់ជិះជាន់ ពុំអាចតាំងចិត្តធ្វើសមណធម៌បានឡើយ ក៏ត្រឡប់មកក្រាបទូលព្រះមានព្រះភាគវិញ ទើបព្រះអង្គទ្រង់ត្រាស់នឹងមេឃិយភិក្ខុនោះថា តថាគតកំណត់ដឹងនូវហេតុរបស់អ្នកដូចនេះហើយ បានជាតថាគតហាមមិនឲ្យអ្នកទៅ តែអ្នកមិនព្រមស្តាប់តថាគតសោះ លុះទ្រង់ប្រទានឱវាទចំពោះមេឃិយភិក្ខុរួចហើយ ព្រះអង្គទ្រង់យាងទៅកាន់ចារិក តាមលំដាប់ រហូតដល់ក្រុងសាវត្ថី ។

គ្រានោះ ព្រះសម្មាសម្ពុទ្ធ ទ្រង់គង់លើពុទ្ធាសនៈដ៏ប្រសើរ ដែលឧបដ្ឋាកភិក្ខុតាក់តែងថ្វាយ ក្នុងបរិវេណនៃគន្ធកុដិ នាវត្តជេតពន ដោយមានភិក្ខុសង្ឃអង្គុយគាល់ក្រៀបក្រាក្នុងទីនោះ ទើបទ្រង់ត្រាស់ទៅកាន់ភិក្ខុទាំងនោះថា ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ តថាគតកាន់តែចាស់ហើយ, ភិក្ខុជាឧបដ្ឋាកបម្រើតថាគត តាំងពីដើមមកមិនប្រាកដ មិនទៀងទាត់សោះ ជួនកាលភិក្ខុនេះ ជួនកាលភិក្ខុនោះ ជាហេតុនាំឲ្យតថាគតមានការលំបាកច្រើន ហើយសុទ្ធតែជាអ្នកមិនសូវប៉ិនប្រសប់ក្នុងការបម្រើផង ។ បណ្ដាភិក្ខុទាំងឡាយ ដែលបានធ្វើជាឧបដ្ឋាកបម្រើតថាគតមកហើយនោះ ភិក្ខុខ្លះមានការចចេសពេក មិនសូវស្តាប់តថាគតសោះ បើតថាគតថាទៅផ្លូវនេះ ត្រឡប់ជាទៅផ្លូវដទៃវិញក៏មាន, ភិក្ខុខ្លះដាក់បាត្រនិងចីវររបស់តថាគតចោលលើផែនដីក៏មាន, ភិក្ខុខ្លះរត់ចោលតថាគត ឲ្យតថាគតនៅតែម្នាក់ឯង ហើយទៅនៅក្នុងទីដទៃក៏មាន, បើដូច្នេះ អ្នកទាំងឡាយ ចូរនាំគ្នាជ្រើស

រើសភិក្ខុរូបណាមួយ ឲ្យធ្វើជាឧបដ្ឋាកបម្រើតថាគត ឲ្យបានទៀងទាត់ជាប់លាប់តទៅ · ភិក្ខុទាំងនោះ បានស្តាប់ព្រះពុទ្ធដីការបស់ព្រះអង្គដូច្នោះហើយ ក៏កើតធម្មសង្វេគគ្រប់ៗគ្នា ។ គ្រានោះ ព្រះសារីបុត្តមានអាយុជាអគ្គសាវ័ក បានក្រោកអំពីអាសនៈ ហើយក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គដែលបានបំពេញបារមីធម៌ អស់រយៈកាលមួយអសង្ខេយ្យកម្រៃមួយសែនកប្ប ព្រោះប្រាថ្នាចំពោះព្រះអង្គតែម្យ៉ាងប៉ុណ្ណោះ បុគ្គលប្រហែលដូចខ្ញុំព្រះអង្គជាអ្នកមានប្រាជ្ញាច្រើន នឹងធ្វើជាឧបដ្ឋាកបម្រើព្រះអង្គពុំគួរទេឬ ? បើព្រះអង្គពុំទ្រង់យល់ទាស់ទេ ខ្ញុំព្រះអង្គសូមថ្វាយខ្លួនជាឧបដ្ឋាក ចាប់ដើមពីត្រឹមថ្ងៃនេះតទៅ ។ ព្រះសម្ពុទ្ធទ្រង់ត្រាស់ឃាត់ថា ម្នាលសារីបុត្ត, ណ្ហើយកុំចុះ អ្នកជាបុគ្គលមានប្រាជ្ញាច្រើន នៅក្នុងទិសណា ទិសនោះមិនស្ងាត់សូន្យទេ , ឱវាទរបស់អ្នកប្រហែលនឹងឱវាទរបស់ព្រះពុទ្ធទាំងឡាយដែរ ។ ដោយហេតុនេះ អ្នកកុំសូមឋានៈជាឧបដ្ឋាកបម្រើតថាគតឡើយ ។ លំដាប់តមកទៀត អសីតិមហាសាវ័កទាំងអស់ មានព្រះមហាមោគ្គល្លានជាដើម បានចូលក្រាបបង្គំទូលសូមទីជាឧបដ្ឋាកដោយទំនងនេះគ្រប់ៗ អង្គបន្តគ្នា តែព្រះសម្ពុទ្ធទ្រង់ត្រាស់ឃាត់ពុំអនុញ្ញាត ចំពោះភិក្ខុទាំងនោះឡើយ ។ ចំណែកខាងព្រះអានន្ទត្ថេរ អង្គុយនៅស្ងៀម ទើបភិក្ខុទាំងឡាយ និយាយទៅនឹងព្រះអានន្ទថា ម្នាលអានន្ទមានអាយុ ភិក្ខុសង្ឃ

បានសូមជាទីឧបដ្ឋាកបម្រើព្រះពុទ្ធគ្រប់ ៗ គ្នា លោកចូរសូមទីនេះទៅ! ព្រះអានន្ទតបឆ្លើយថា ម្នាលអាវុសោទាំងឡាយ ទីជាឧបដ្ឋាកដែលខ្ញុំសូមបានហើយ តើទីនេះប្រាកដបែបណាទៅ? ព្រះបរមសាស្ដា មិនឃើញខ្ញុំទេឬ? បើព្រះអង្គទ្រង់សព្វព្រះហឫទ័យ គង់តែត្រាស់ប្រាប់ខ្ញុំថា អានន្ទ ចូរបម្រើតថាគតទៅ ។ គ្រានោះ ព្រះតថាគតទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អានន្ទ ជាបុគ្គលមានប្រាជ្ញាស្រាប់ មិនចាំបាច់អ្នកដទៃមកដាស់តឿនបង្ខំទេ អានន្ទមុខតែដឹងខ្លួនឯងហើយបម្រើតថាគត ។ លំដាប់នោះ ភិក្ខុទាំងឡាយពោលថា ម្នាលអានន្ទ ចូរលោកក្រោកឡើង ចូរសូមទីជាឧបដ្ឋាកបម្រើព្រះទសពល ចាប់ដើមពីត្រឹមថ្ងៃនេះតទៅ ។ ព្រះអានន្ទជាអ្នកប្រាជ្ញ មានប្រាជ្ញាឈ្លាសវៃប៉ិនប្រសប់ក្នុងកិច្ចបម្រើ នាំឲ្យព្រះអង្គមានសេចក្ដីស្រួលគ្រប់យ៉ាង មិនលំបាកដោយកិច្ចណាមួយឡើយ ប៉ុន្តែមុននឹងចូលធ្វើជាឧបដ្ឋាកបម្រើ ព្រះអានន្ទ(១) បានទូលសូមពរ ៨ យ៉ាងអំពីព្រះសម្មាសម្ពុទ្ធ, ព្រះអង្គក៏ទ្រង់អនុញ្ញាតឲ្យ តាមសេចក្ដីសុំរបស់ព្រះអានន្ទ គឺពរដែលត្រូវឃាត់ ៤ យ៉ាង ពរដែលត្រូវសូម ៤ យ៉ាង ដូចតទៅនេះ :

## ពរដែលត្រូវឃាត់ ៤ យ៉ាងនោះគឺ

១– សូមព្រះមានព្រះភាគ កុំប្រទានចីវរល្អ ៗ ដែលព្រះអង្គបានហើយដល់ខ្ញុំព្រះអង្គ ។

---

១ ព្រះអានន្ទដែលបានចូលធ្វើជាពុទ្ធុបដ្ឋាក ក្នុងវាំងមជ្ឈិមពោធិកាល វស្សាទី ២០ នៃព្រះសម្ពុទ្ធ ។

២– សូមព្រះមានព្រះភាគ កុំប្រទានបិណ្ឌបាតល្អ ៗ ដែលព្រះអង្គបានហើយដល់ខ្ញុំព្រះអង្គ ។

៣– សូមព្រះមានព្រះភាគ កុំប្រទានទីកន្លែងឲ្យខ្ញុំព្រះអង្គនៅក្នុងគន្ធកុដិជាមួយនឹងព្រះអង្គ ។

៤– សូមព្រះមានព្រះភាគ កុំនាំខ្ញុំព្រះអង្គទៅកាន់ទីនិមន្ត ដែលគេនិមន្តហើយ ។

## ពរដែលត្រូវសូម ៤ នោះគឺ

១– សូមព្រះមានព្រះភាគ ទ្រង់ទៅកាន់ទីនិមន្ត ដែលខ្ញុំព្រះអង្គបានទទួលនិមន្តគេហើយ ។

២– បើមានបរិស័ទមកអំពីខាងក្រៅរដ្ឋ ឬខាងក្រៅជនបទ ឬក៏មកអំពីទីណាមួយ ដើម្បីចង់ចូលគាល់ព្រះអង្គ សូមឲ្យខ្ញុំព្រះអង្គអាចនាំបរិស័ទនោះចូលគាល់បាន ។

៣– កាលណាបើខ្ញុំព្រះអង្គមានសេចក្ដីសង្ស័យកើតឡើង សូមឲ្យខ្ញុំព្រះអង្គបានចូលគាល់ទូលសួរក្នុងកាលណោះ ។

៤– បើព្រះមានព្រះភាគ សម្ដែងធម៌ណាក្នុងទីកំបាំងមុខនៃខ្ញុំព្រះអង្គ វេលាដែលព្រះអង្គយាងត្រឡប់មកវិញ សូមព្រះមានព្រះភាគ សម្ដែងធម៌នោះដល់ខ្ញុំព្រះអង្គ ។

ព្រះសម្មាសម្ពុទ្ធ ទ្រង់ត្រាស់សួរអានន្ទថា ម្នាលអានន្ទ ចុះអ្នកឃើញ

ទោសដូចម្តេចខ្លះក្នុងពរ ៤ ខាងដើមនោះ? ព្រះអានន្ទក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស, បើខ្ញុំព្រះអង្គនឹងបាននូវវត្ថុពរទាំងនោះហើយ អ្នកផងទាំងឡាយ មុខជានឹងរិះគន់ខ្ញុំព្រះអង្គយ៉ាងនេះថា ព្រះអានន្ទបានបរិភោគប្រើប្រាស់នូវចីវរ បិណ្ឌបាតល្អៗដែលព្រះទសពលបានហើយ ,បាននៅក្នុងគន្ធកុដិជាមួយ, បានទៅកាន់ទីនិមន្តក្នុងទីជាមួយ ព្រោះតែលាភប្រយោជន៍ទាំងនោះហើយ ទើបព្រះអានន្ទទទួលធ្វើជាឧបដ្ឋាកបម្រើព្រះតថាគត, បើយ៉ាងហ្នឹង អ្នកណាក៏អាចទទួលភារៈបម្រើព្រះអង្គបានដែរ ។

ព្រះសព្វញ្ញុពុទ្ធ ទ្រង់ត្រាស់សួរអានន្ទថា ម្នាលអានន្ទ ចុះអ្នកឃើញអានិសង្សដូចម្តេចខ្លះក្នុងពរ៤ខាងចុងនោះ? ព្រះអានន្ទក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស, បើមានកុលបុត្តទាំងឡាយក្នុងសាសនានេះ ជាអ្នកមានសទ្ធា មិនបានឱកាសចូលជួបផ្ទាល់នឹងព្រះមានព្រះភាគ ហើយគេបាននិយាយនឹងខ្ញុំព្រះអង្គយ៉ាងនេះថា បពិត្រព្រះអានន្ទ,ថ្ងៃស្អែកនេះ សូមលោកម្ចាស់ទទួលភត្តក្នុងផ្ទះនៃយើងជាមួយនឹងព្រះមានព្រះភាគ, បើព្រះអង្គមិនទ្រង់យាងទៅក្នុងទីនោះទេក្តី ខ្ញុំព្រះអង្គមិនបានឱកាសដើម្បីនាំបរិស័ទចូលគាល់ក្នុងខណៈដែលគេត្រូវការក្តី មិនបានទូលសួរធម៌ដើម្បីបន្ទោបង់សេចក្តីសង្ស័យក្តី អ្នកផងទាំងឡាយ មុខតែនឹងថាឲ្យខ្ញុំព្រះអង្គយ៉ាងនេះថា ព្រះអានន្ទបម្រើព្រះទសពលដូចម្តេច សព្វបើកិច្ចបន្តិចបន្តួចប៉ុណ្ណោះ ព្រះមានព្រះភាគមិនទ្រង់ធ្វើសេចក្តីអនុគ្រោះ, មួយទៀត គេនឹងសួរធម៌ណា

មួយ ចំពោះខ្ញុំព្រះអង្គក្នុងទីកំបាំងព្រះភក្ត្រនៃព្រះអង្គថា បពិត្រព្រះអានន្ទ, គាថានេះ សូត្រនេះ ជាតកនេះជាដើម តើព្រះមានព្រះភាគទ្រង់សម្ដែងក្នុងទីណា ? បើខ្ញុំព្រះអង្គឆ្លើយទៅនឹងគេមិនរួចទេ អ្នកផងទាំងឡាយ មុខតែនឹងថាឲ្យខ្ញុំព្រះអង្គយ៉ាងនេះថា លោកម្ចាស់ជាតែនៅជាប់តាមកិតកើយជាមួយនឹងព្រះទសពលមិនស្ងួរឃ្លាត ដូចជាស្រមោល យូរ-ខែ-ឆ្នាំហើយ តែមិនចេះមិនដឹងធម៌វិន័យ ដែលព្រះអង្គបានសម្ដែងហើយ ព្រោះហេតុនោះ ខ្ញុំព្រះអង្គចង់ដឹងធម៌វិន័យ ដែលព្រះអង្គបានសម្ដែងហើយ ក្នុងទីកំបាំងមុខនោះ ដើម្បីនឹងបានសម្ដែងប្រាប់គេម្ដងទៀត ។

ព្រះអានន្ទត្ថេរ លុះបានទទួលនូវពរទាំង ៨ ប្រការនោះ ដែលព្រះសម្មាសម្ពុទ្ធទ្រង់អនុញ្ញាតឲ្យហើយ ក៏បាននាមថាជា ពុទ្ធុបដ្ឋាក (អ្នកបម្រើព្រះពុទ្ធ) ។ អនន្តរនេះ ព្រះអានន្ទត្ថេរបានកសាងកុសលបំពេញបារមីអស់រយៈកាលមួយសែនកប្ប ទើបបានសម្រេចនូវលទ្ធផលដែលខ្លួនប្រាថ្នានេះ ។ ចាប់ដើមតាំងអំពីថ្ងៃដែលបានទទួលឋានៈជាឧបដ្ឋាកមក, ក្រៅអំពីពរទាំង ៨ ប្រការនោះ ព្រះអានន្ទត្ថេរ បានយកចិត្តទុកដាក់បម្រើព្រះពុទ្ធជាម្ចាស់ ដោយកិច្ចទាំងឡាយ មានយ៉ាងនេះជាដើម ជាប្រក្រតីផងទៀត គឺ ថ្វាយទឹកសម្រាប់ប្រើប្រាស់ និងទឹកសម្រាប់ស្រង់, ថ្វាយឈើស្ទន់, បរិកម្មព្រះហស្ត និង ព្រះបាទ, បរិកម្មព្រះបិដ្ឋ, បោសសំអាតគន្ធកុដិ និង បរិវេណនៃគន្ធកុដិ ព្រមទាំងរៀបចំពុទ្ធាសនៈថ្វាយ

តាមកាលដ៏គួរផង ៗ នៅក្នុងវេលារាត្រីមួយ ៗ ព្រះអានន្ទត្ថេរ កាន់ប្រទីបដើរក្រឡឹងជុំវិញបរិវេណនៃគន្ធកុដិ ចំនួន ៨ ឬ ៩ ដង ដើម្បីរង់ចាំស្តាប់ព្រះបន្ទូល ក្រែងព្រះអង្គត្រាស់ការហៅរកខ្លួន ដោយមានកិច្ចការអ្វីមួយ ៗ នេះជាកិច្ចវត្តរបស់ព្រះអានន្ទត្ថេរ ដែលបានបំពេញជាប្រក្រតីក្នុងឋានៈនៃខ្លួនជាពុទ្ធុបដ្ឋាក[1] ៗ

ក្នុងកាលជាខាងក្រោយមក ព្រះបរមសាស្តា ទ្រង់សរសើរព្រះអានន្ទត្ថេរ ថាជា ធម្មភណ្ឌាគារិក ( អ្នកឃុំធម៌ ) ហើយទ្រង់តាំងព្រះអានន្ទត្ថេរ ក្នុងទីជាឯតទគ្គៈ មានឋានៈដ៏ខ្ពង់ខ្ពស់ ជាងលោកពហុស្សុតទាំងឡាយ ក្នុងពុទ្ធសាសនានេះ ៗ

## អាការដែលព្រះពុទ្ធទ្រង់សម្តែងធម៌

អាការដែលព្រះសម្មាសម្ពុទ្ធ ទ្រង់សម្តែងធម៌ទូន្មានសត្វ រមែងទ្រង់សម្តែងអនុលោមទៅតាមអធ្យាស្រ័យ ឬ ឧបនិស្ស័យ (ជាចំណុចចិត្ត) នៃសត្វ តាមថ្នាក់ ជាន់ទាប ជាន់កណ្តាល និងជាន់ខ្ពស់ ដើម្បីឲ្យសត្វបានទទួលនូវប្រយោជន៍ទាំង ៣ យ៉ាងគឺ

១– ទិដ្ឋធម្មិកត្ថៈ ប្រយោជន៍ដែលសត្វគប្បីបានក្នុងជាតិនេះមួយយ៉ាង,

---

១ ទោះបីតម្រូវឲ្យភិក្ខុដទៃបម្រើព្រះភគវ័តមួយដងមួយកាល ក៏ជាភារៈលើព្រះអានន្ទបាត់បែងទាំងអស់ ៗ

២- សម្បរាយិកត្ថៈ ប្រយោជន៍ដែលសត្វគប្បីបានក្នុងជាតិខាងមុខមួយយ៉ាង,

៣- បរមត្ថៈ ប្រយោជន៍ដ៏ប្រសើរក្រៃលែង គឺ មគ្គ ផល និព្វាន ដែលសត្វគប្បីបាន មិនមានកំណត់កប់ថា ជាតិនេះ ឬ ជាតិមុខៗ មួយយ៉ាង ។ ទុកទៃដែលទ្រង់ប្រៀនប្រដៅអំពីប្រយោជន៍ជាតិនេះ មានចំនួនតិចជាងទុកទដទៃ ៗ ដូចទុកទៃដែលទ្រង់ប្រៀនប្រដៅទីឃជាណុកោ-លិយបុត្ត និង ទដ្ឋយព្រាហ្មណ៍ជាដើម ដោយធម៌ ៤ ប្រការគឺ

១- ឧដ្ឋានសម្បទា ការដល់ព្រមដោយសេចក្តីព្យាយាមក្នុងការស្វែងរកទ្រព្យសម្បត្តិ ឲ្យកើតមានឡើង,

២- អារក្ខសម្បទា ការដល់ព្រមដោយការចេះថែរក្សាទ្រព្យសម្បត្តិ ដែលរកបានមកហើយ មិនឲ្យវិនាសដោយហេតុណាមួយ,

៣- កល្យាណមិត្តតា ភាពជាអ្នកមានការសេពគប់កប់រកយកមនុស្សល្អធ្វើជាមិត្តសម្លាញ់,

៤-សមជីវិតា ភាពជាអ្នកចេះលៃលកចិញ្ចឹមជីវិត តាមសមគួរដល់កម្លាំងទ្រព្យសម្បត្តិ ដែលខ្លួនរកបាន ។ល។

ទុកទៃដែលទ្រង់ប្រៀនប្រដៅ អំពីប្រយោជន៍ជាតិនេះ មានចំនួនតិចជាងទុកទៃដែលប្រៀនប្រដៅ អំពីប្រយោជន៍ជាតិមុខ សូម្បីប្រយោជន៍ជាតិមុខៗនោះសោតទៀត ក៏ព្រះអង្គទ្រង់ប្រៀនប្រដៅមានចំនួនតិចជាង

បរមត្ថប្រយោជន៍ដែរ ដូចទ្រង់ប្រៀនប្រដៅឲ្យសត្វតាំងនៅ ក្នុងសទ្ធា សីល ចាគៈ បញ្ញា ជាដើម ។ ឯបរមត្ថប្រយោជន៍ គឺព្រះអង្គទ្រង់សម្តែង អំពីធម៌ជាក់ជាន់ខ្ពស់មាន ឈាន សមាបត្តិ មគ្គ ផល ជាដើម ដើម្បី ធ្វើឲ្យសត្វឆ្លងរួចចាកផុតភពទាំង ៣ ឆ្ពោះមុខទៅកាន់អមតមហានិព្វាន ដែលជាធម្មជាតរំលត់ខន្ធទាំង ៥ ដាច់សូន្យ លែងមានការអន្ទោលកើត ស្លាប់ ក្នុងវដ្តសង្សារតទៅទៀត ។

## អាការដែលព្រះពុទ្ធទ្រង់បញ្ញត្តវិន័យ

អាការដែលព្រះសម្មាសម្ពុទ្ធ ទ្រង់បញ្ញត្តវិន័យចំពោះសាវ័ក-សាវិកា របស់ព្រះអង្គនោះ គឺ ក្នុងសម័យដែលមានកុលបុត្តកុលធីតា ជាអ្នកមាន សទ្ធា ចូលបួសក្នុងព្រះពុទ្ធសាសនាដោយច្រើន, អ្នកបួសទាំងនោះហៅ ថា សហធម្មិកបព្វជិត មាន ៥ ពួកគឺ ភិក្ខុ ភិក្ខុនី សិក្ខមានា សាមណេរៈ សាមណេរី ។ បុរសដែលមានអាយុយ៉ាងតិចត្រឹម ២០ ឆ្នាំ បានចូល មកទទួលឧបសម្បទា សម្រេចដោយញត្តិចតុត្ថកម្មវាចា អំពីសំណាក់ ភិក្ខុសង្ឃ ហៅថា ភិក្ខុ ។ ស្រីដែលមានអាយុយ៉ាងតិចត្រឹម ២០ ឆ្នាំ បានចូលមកទទួលឧបសម្បទា សម្រេចដោយចតុត្ថកម្មវាចា អំពីសំណាក់ ភិក្ខុនីសង្ឃ ឬ អំពីសំណាក់ឧភតោសង្ឃ ហៅថា ភិក្ខុនី ។ សាមណេរី ដែលមានអាយុច្រើន ហើយមានបំណងនឹងបួសជាភិក្ខុនី បានទទួល សិក្ខាសម្មតិអំពីសំណាក់ភិក្ខុនីសង្ឃ ប្រព្រឹត្តឲ្យបានបរិបូណ៌អស់ ២ ឆ្នាំ

ជាមុន ទើបទទួលឧបសម្បទាជាខាងក្រោយ ហៅថា សិក្ខមានា ។ កុមារដែលចូលមកសូមបព្វជ្ជា ហើយបានទទួលត្រៃសរណគមន៍ ព្រមទាំងសិក្ខាបទផង អំពីសំណាក់ភិក្ខុជាឧបជ្ឈាយ៍ ហៅថា សាមណេរ ។ កុមារីដែលចូលមកសូមបព្វជ្ជា ហើយបានទទួលត្រៃសរណគមន៍ ព្រមទាំងសិក្ខាបទផង អំពីសំណាក់ភិក្ខុនីជាឧបជ្ឈាយ៍ ហៅថា សាមណេរី ។

បណ្ដាសហធម្មិកបព្វជិតទាំង៥ ពួកនោះ ដែលកើតមានច្រើនឡើងក្នុងព្រះពុទ្ធសាសនា ហើយមានបព្វជិតខ្លះ មានអាកប្បកិរិយាប្រព្រឹត្តខ្វះខ្វាតពុំសមរម្យ ទើបព្រះសម្ពុទ្ធបរមគ្រូទ្រង់បញ្ញត្តសិក្ខាបទ គឺវិន័យឡើងតាំងអំពីសិក្ខាបទតូចតាចកាយវង់ជាលំដាប់ រហូតដល់សិក្ខាបទធំ ៗ មានបារាជិកសិក្ខាបទជាដើម ដើម្បីជាច្បាប់ឃុំគ្រងក្រុបបព្វជិតទាំងនោះ ឲ្យមានចរិយាសណ្ដាប់ធ្នាប់រៀបរយល្អឡើង ។

មួយយ៉ាងទៀត ព្រះអង្គទ្រង់បញ្ញត្តវិន័យឡើង ព្រោះទ្រង់យល់ឃើញនូវអំណាចនៃប្រយោជន៍ ១០ យ៉ាង គឺ

១– សង្ឃសុដ្ឋុតាយ ដើម្បីសេចក្ដីល្អរៀបរយនៃសង្ឃ,

២– សង្ឃផាសុតាយ ដើម្បីសេចក្ដីសប្បាយនៃសង្ឃ,

៣– ទុម្មង្កូនំ បុគ្គលានំ និគ្គហាយ ដើម្បីសង្កត់សង្កិននូវបុគ្គលទាំងឡាយដែលទ្រុស្តសីល,

៤- បេសលានំ ភិក្ខូនំ ផាសុវិហារាយ ដើម្បីនៅជាសុខស្រួលនៃភិក្ខុទាំងឡាយ ដែលមានសីលជាទីស្រឡាញ់,

៥- ទិដ្ឋធម្មិកានំ អាសវានំ សំវរាយ ដើម្បីរាំងអាសវធម៌ទាំងឡាយ ដែលកើតមានក្នុងបច្ចុប្បន្ន,

៦- សម្បរាយិកានំ អាសវានំ បដិឃាតាយ ដើម្បីកំចាត់បង់នូវអាសវធម៌ទាំងឡាយដែលកើតមានក្នុងបរលោក,

៧- អប្បសន្នានំ បសាទាយ ដើម្បីញុំាងជនទាំងឡាយដែលមិនទាន់ជ្រះថ្លា ឲ្យជ្រះថ្លាឡើង,

៨- បសន្នានំ ភិយ្យោភាវាយ ដើម្បីញុំាងជនទាំងឡាយដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើង,

៩- សទ្ធម្មដ្ឋិតិយា ដើម្បីតាំងនៅមាំនៃព្រះសទ្ធម្ម,

១០- វិនយានុគ្គហាយ ដើម្បីអនុគ្រោះដល់វិន័យ ។

## ព្រះឥរិយាបថរបស់ព្រះពុទ្ធ ក្នុងសម័យដែលព្រះអង្គទ្រង់គង់ព្រះជន្មនៅឡើយ

ព្រះសម្មាសម្ពុទ្ធបរមគ្រូនៃយើងទាំងឡាយ ចាប់ដើមតាំងអំពីព្រះអង្គបានត្រាស់ដឹងឡើង ទៅទល់នឹងបរិនិព្វានទៅ ព្រះអង្គមិនដែលសម្រេចព្រះឥរិយាបថគង់នូវចាំវស្សាក្នុងវត្តណាមួយ ឬទីកន្លែងណាមួយ ជាប់ជា

និច្ច ហេតុដល់បរិនិព្វានទេ ។ ជួនកាល ព្រះអង្គទ្រង់គង់នៅចាំវស្សា ក្នុងវត្តជិតទីក្រុងដែលគេកសាងថ្វាយក៏មាន, ជួនកាល ទ្រង់គង់នៅចាំវស្សាក្នុងព្រៃ ឬលើភ្នំ ឬក៏ក្នុងស្រុកក៏មាន ដោយព្រះអង្គទ្រង់យល់ឃើញថាទីណាដែលមានប្រយោជន៍ច្រើនដល់សត្វលោក ទ្រង់តែងយាងទៅគង់នៅទីនោះ ដូចសេចក្ដីដែលបានលើកយកមកពណ៌នា តទៅនេះ គឺៈ

– វស្សាទី ១ ទ្រង់គង់នៅនាឥសិបតនមិគទាយវ័ន ជិតក្រុងពារាណសី ជាមួយនឹងព្រះអរហន្តថេរ ៦០ អង្គ ។

– វស្សាទី ២-៣-៤ ទ្រង់គង់នៅក្នុងវត្ត វេឡុវ័ន ជិតក្រុងរាជគ្រឹះ ។

– វស្សាទី ៥ ទ្រង់គង់នៅក្នុង កូដាគារសាលា នាមហាវ័ន ជិតក្រុងវេសាលី ។

– វស្សាទី ៦ ទ្រង់គង់នៅនា មកុឡបព៌ត ក្នុងដែនមគធៈ ។

– វស្សាទី ៧ ទ្រង់គង់នៅក្នុង តាវត្តិង្សទេវលោក លើបណ្ឌុកម្ពលសិលាសនៈ ទ្រង់ប្រទានសត្តប្បករណាភិធម្ម ប្រោសព្រះមហាមាយាទេវបុត្ត ( ជាពុទ្ធមាតា ) ។

– វស្សាទី ៨ ទ្រង់គង់នៅក្នុង ភេសកលាវ័ន ក្នុងភគ្គជនបទ ។

- វស្សាទី ៩ ទ្រង់គង់នៅក្នុងព្រៃ ចារិលេយ្យកៈ ។

- វស្សាទី ១០-១១ ទ្រង់គង់នៅក្នុងដងព្រៃជិតស្រុកព្រាហ្មណ៍ ឈ្មោះ សាលេយ្យគ្រាម ។

- វស្សាទី ១២ ទ្រង់គង់នៅក្រោមដើមស្ដៅដែលនឡេរុ-យក្សរក្សា ។

- វស្សាទី ១៣ ទ្រង់គង់នៅនា ចារិលេយ្យកបព៌ត ។

- វស្សាទី ១៤ ទ្រង់គង់នៅក្នុងវត្តជេតពន ជិតក្រុងសាវត្ថី ។

- វស្សាទី ១៥ ទ្រង់គង់នៅក្នុងវត្ត និគ្រោធារាម ជិតក្រុង កបិលព័ស្តុ ។

- វស្សាទី ១៦ ទ្រង់គង់នៅក្នុងស្រុក អាឡវី ។

- វស្សាទី ១៧-១៨-១៩ ទ្រង់គង់នៅក្នុងវត្ត វេឡុវ័ន ក្រុង រាជគ្រឹះ ។

- វស្សាទី ២០ ដល់ទី ២៩ ទ្រង់គង់នៅក្នុងវត្តជេតពន ជិត ក្រុងសាវត្ថី ។

- វស្សាទី ៣០ ដល់ទី ៣៩ ទ្រង់គង់នៅក្នុងវត្តបុព្វារាម ជិតក្រុង សាវត្ថី ។

— វស្សាទី ៣៦ ដល់ទី ៤៤ ទ្រង់គង់នៅក្នុងវត្តជេតពន ជិតក្រុងសាវត្ថី ។

- វស្សាទី ៤៥ ទ្រង់គង់នៅនាស្រុក វេឡុវគ្រាម ។

· ព្រះសម្មាសម្ពុទ្ធ ទ្រង់ចូលបរិព្វាន ក្នុងព្រះជន្មាយុ ៨០ ឆ្នាំគត់ នៅថ្ងៃអង្គារ ១៥ កើត ពេញបូណ៌មី ខែពិសាខ ឆ្នាំម្សាញ់នព្វស័ក ក្រោមដើមសាលព្រឹក្សទាំងគូ ក្នុងឧទ្យាននៃមល្លក្សត្រិយ៍ ជិតកុសិនារាជធានី ។

ពុទ្ធកិច្ច ចប់ដោយសង្ខេប

# មកពីហេតុអ្វី បានជាមនុស្ស ធ្វើអំពើអាក្រក់កើត?

លោក ប៊ូ—ប៉ូ រៀបរៀង

មានរឿងក្នុងចក្កវត្តិសូត្រ[1]ថា សម័យមួយ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរយកខ្លួន[2]ជាទីពឹងពំនាក់ ចូរយកធម៌ជាទីពឹងពំនាក់ កុំយករបស់ដទៃជាទីពឹងពំនាក់ឡើយ ។ គឺភិក្ខុក្នុងសាសនានេះ ពិចារណានូវកាយក្នុងកាយ ។ នូវវេទនាក្នុងវេទនាទាំងឡាយ ។ នូវចិត្តក្នុងចិត្ត ។ នូវធម៌ក្នុងធម៌ទាំងឡាយ ជាប្រក្រតី មានព្យាយាមជាគ្រឿងដុតកំដៅនូវកិលេស មានប្រាជ្ញាដឹងសព្វ មានស្មារតី កំចាត់បង់នូវអភិជ្ឈា និងទោមនស្សក្នុងលោក[3]បាន ។ យ៉ាងនេះហៅថា ភិក្ខុយកខ្លួនជាទីពឹងពំនាក់ យកធម៌ជាទីពឹងពំនាក់ មិនយករបស់ដទៃជាទីពឹងពំនាក់ ។ អ្នកទាំងឡាយ ចូរប្រព្រឹត្តក្នុងគោចរ ជាវិស័យដែលមានមកអំពីបិតា[4]របស់ខ្លួន ទើបមារ[5]មិនបាននូវចន្លោះ មិនបាននូវអារម្មណ៍ឡើយ ។ បុណ្យនេះ រមែងចម្រើនឡើង ព្រោះហេតុសមាទាន នូវកុសលធម៌ទាំងឡាយយ៉ាងនេះ ។

---

១ ស្រង់ដោយសង្ខេបពីចក្កវត្តិសូត្រ ក្នុងគម្ពីរព្រះត្រៃបិដកបាលី—ខ្មែរ លេខទី ១៨ ។
២ អដ្ឋកថា ថា លោកិយធម៌និងលោកុត្តរធម៌ ឈ្មោះថាខ្លួន ។ ព្រោះហេតុនោះ បានជាទ្រង់ត្រាស់ថែមទៀតថា ចូរយកធម៌ជាទីពឹងពំនាក់ កុំយករបស់ដទៃជាទីពឹងពំនាក់ឡើយ ។
៣ ក្នុងរូបរាងកាយ ។ ៤ ជាដំណែលរបស់ព្រះសម្មាសម្ពុទ្ធ ជាបិតានៃពុទ្ធបរិស័ទ ។
៥ អដ្ឋកថា សំដៅយកតែទេវបុត្រមារនិងកិលេសមារប៉ុណ្ណោះ ។

# រឿងស្តេចចក្រពត្តិព្រះនាមទល្ហនេមិ

ម្នាលភិក្ខុទាំងឡាយ កាលពីព្រេងនាយ មានព្រះរាជាមួយព្រះអង្គ ទ្រង់ព្រះនាមទល្ហនេមិ ជាស្តេចចក្រពត្តិ ព្រះអង្គជាធម្មិកធម្មរាជ ជាឥស្សរលើផែនដី ដែលមានសមុទ្រទាំងបួនជាទីបំផុត ជាស្តេចឈ្នះសង្គ្រាម ទ្រង់មានជនបទមាំមួន ទ្រង់បរិបូណ៌ដោយរតន៍៧ប្រការ(១) ។ ព្រះអង្គមានព្រះរាជបុត្រច្រើនជាងពាន់ សុទ្ធសឹងតែក្លៀវក្លាអង់អាច អាចសង្កត់សង្កិននូវសេនារបស់ស្តេចដទៃបាន ។ ព្រះអង្គទ្រង់ត្រួតត្រាគ្រប់គ្រងផែនដី ដែលមានសាគរជាព្រំប្រទល់នេះ ដោយធម៌ដ៏ស្មើ មិនបាច់ប្រើអាជ្ញា មិនបាច់ប្រើគ្រឿងសស្ត្រាវុធទេ ។

លុះកាលកន្លងទៅបានច្រើនពាន់ឆ្នាំ ព្រះបាទទល្ហនេមិទ្រង់បានជ្រាបថា ចក្ករតន៍ជាទិព្វឃ្លាតចាកទី ហើយទ្រង់ត្រាស់ហៅព្រះរាជបុត្រច្បងមកផ្តាំផ្ញើ ប្រគល់រាជសម្បត្តិ រួចស្រេចស្តេចចេញទៅទ្រង់ព្រះផ្នួស ។ កន្លងពីនោះមកបាន ៧ ថ្ងៃ ចក្ករតន៍ជាទិព្វបាត់ទៅ ព្រះរាជាជាព្រះរាជបុត្រក៏នឹកតូចព្រហឫទ័យសោកស្តាយ ចូលទៅគាល់ព្រះរាជឥសី ក្រាបបង្គំទូលពីចក្ករតន៍ជាទិព្វបាត់ទៅនោះ ។ ព្រះរាជឥសីទ្រង់ត្រាស់ថា ម្នាលបាកាលបើចក្ករតន៍ជាទិព្វបាត់ទៅហើយ អ្នកកុំតូចចិត្តឡើយ ព្រោះថាចក្ករតន៍

---

១ ចក្ករតន៍ ១ ហត្ថីរតន៍ ១ អស្សរតន៍ ១ មណិរតន៍ ១ ឥត្ថីរតន៍ ១ គហបតិរតន៍ ១ បរិនាយករតន៍ ១ ។

ជាទិព្វនេះ មិនមែនជាមត៌កដែលមានមកអំពីបិតាអ្នកទេ ណ្ហើយចុះ អ្នកចូរប្រព្រឹត្តចក្កវត្តិវត្តដ៏ប្រសើរវិញចុះ កាលបើអ្នកប្រព្រឹត្តចក្កវត្តិវត្តបានល្អហើយ ចក្ករតនៈជាទិព្វមានកាំ ១ ពាន់ ព្រមទាំងខ្នងកង់ ព្រមទាំងដុំបរិបូណ៌ទៅដោយអាការៈសព្វគ្រប់ នឹងកើតប្រាកដដល់បា ដែលកក់កេសា ហើយរក្សាឧបោសថ បិតនៅលើប្រាសាទដ៏ប្រសើរក្នុងថ្ងៃ ១៥ ជាថ្ងៃឧបោសថនោះ ហេតុនេះ រមែងមានប្រាកដ ។

ចុះចក្កវត្តិវត្តដ៏ប្រសើរនុ៎ះ តើដូចម្តេច ?

ចូរអ្នកអាស្រ័យនូវធម៌តែម្យ៉ាង ហើយធ្វើសក្ការៈចំពោះធម៌ គោរពធម៌ កប់អានធម៌ បូជាធម៌ កោតក្រែងធម៌ យកធម៌ជាទង់ជ័យ យកធម៌ជាស្លាក យកធម៌ជាអធិបតី ចាត់ចែងនូវការរក្សា ទប់ទល់ គ្រប់គ្រងប្រកបដោយធម៌ ចំពោះជនខាងក្នុង គឺបុត្រភរិយា ចំពោះពួកពល ពួកក្រពួកជនចុះចូល ពួកព្រាហ្មណ៍ គហបតី ពួកអ្នកនិគម អ្នកជនបទ ពួកសមណព្រាហ្មណ៍ និងពួកម្រឹគបក្សី អ្នកកុំធ្វើអកុសលធម៌ក្នុងដែនរបស់អ្នកឡើយ បើពួកជនណាក្នុងដែនរបស់អ្នកឥតទ្រព្យ អ្នកគប្បីផ្តល់ទ្រព្យដល់ជនទាំងនោះ :បើសមណព្រាហ្មណ៍ណាក្នុងដែនរបស់អ្នក ជាអ្នកវៀរចាកសេចក្តីស្រវឹងនិងសេចក្តីប្រមាទ តាំងនៅក្នុងខន្តិនិងសោរច្ចៈ តែងទូន្មានខ្លួនឯងតែម្នាក់ឯង ធ្វើខ្លួនឯងឲ្យស្ងប់រម្ងាប់តែម្នាក់ឯង ធ្វើខ្លួនឯងឲ្យរលត់ ចាកកតាទិក្កិលេសតែម្នាក់ឯង អ្នកគប្បីចូលទៅរកសមណ-

ព្រាហ្មណ៍ទាំងនោះសព្វៗកាល ហើយគប្បីចោទដណ្ដឹងថា បពិត្រលោកដ៏ចម្រើន អ្វីជាកុសល អ្វីជាអកុសល អ្វីជាអំពើប្រកបដោយទោស អ្វីជាអំពើមិនប្រកបដោយទោស អ្វីគួរសេព អ្វីមិនគួរសេព អំពើដូចម្ដេចដែលខ្ញុំធ្វើទៅហើយមិនជាប្រយោជន៍ ជាទុក្ខ អស់កាលយូរអង្វែង អំពើដូចម្ដេចដែលខ្ញុំធ្វើទៅហើយ ជាប្រយោជន៍ ជាសុខ អស់កាលយូរអង្វែង លុះអ្នកបានស្ដាប់ពាក្យសមណព្រាហ្មណ៍ទាំងនោះហើយ អ្នកគប្បីវៀរចាកអំពើដែលជាអកុសល ហើយសមាទាន ប្រព្រឹត្តនូវអំពើជាកុសល ម្នាលបា នេះឯង ជាចក្កពត្តិវត្តដ៏ប្រសើរនោះ ។

ព្រះមហាក្សត្រ បានទទួលស្ដាប់ព្រះបន្ទូលព្រះរាជឥសីហើយ ក៏ប្រព្រឹត្តចក្កពត្តិវត្តដ៏ប្រសើរ កាលដែលព្រះអង្គ កំពុងប្រព្រឹត្តចក្កពត្តិវត្ត កក់ព្រះកេសា សមាទានឧបោសថ ហើយស្ដេចឡើងទៅខាងលើប្រាសាទដ៏ប្រសើរក្នុងថ្ងៃ១៥ ដែលជាថ្ងៃឧបោសថនោះ ចក្ករតនៈជាទិព្វក៏កើតប្រាកដឡើង ។ ព្រះមហាក្សត្រទ្រង់ទតឃើញចក្ករតនៈជាទិព្វហើយ ទ្រង់ជ្រាបថា ឱហ្ន៎! អាត្មាអញប្រាកដជាស្ដេចចក្កពត្តិហើយតើ ទើបទ្រង់ក្រោកចាកអាសនៈ ធ្វើសំពត់ឧត្តរាសង្គៈឆៀងស្មាម្ខាង ព្រះហស្ដខាងឆ្វេងកាន់កុណ្ឌី ព្រះហស្ដខាងស្ដាំស្រោចព្រំចក្ករតនៈហើយទ្រង់អធិដ្ឋានថា សូមឲ្យចក្ករតនៈដ៏ចម្រើនប្រព្រឹត្តទៅ សូមឲ្យចក្ករតនៈដ៏ចម្រើនមានជ័យជំនះចុះ ។ គ្រានោះ ចក្ករតនៈក៏អណ្ដែតត្រសែតទៅកាន់ទិសខាង

កើត ។ ទើបព្រះបាទចក្រពត្តិស្តេចទៅតាមចក្ករតន៍នោះ ព្រមដោយចតុរង្គសេនា ។ បើចក្ករតន៍ទៅប្រតិស្ឋានក្នុងប្រទេសណា ព្រះបាទចក្រពត្តិ ក៏ស្តេចចូលទៅតាំងព្រះរាជនិវេសន៍ក្នុងប្រទេសនោះ ។ ចំណែកខាងស្តេចជាសឹកសត្រូវដែលនៅក្នុងទិសខាងកើត ក៏ចូលទៅគាល់ព្រះបាទចក្រពត្តិ ហើយក្រាបបង្គំទូលថា បពិត្រមហារាជ សូមព្រះអង្គស្តេចចូលមកចុះ ព្រះអង្គមានព្រះរាជដំណើរមកស្រួលហើយ ដែនរបស់ខ្ញុំព្រះអង្គ ជាដែនរបស់ព្រះអង្គហើយ សូមព្រះអង្គទ្រង់ប្រៀនប្រដៅចុះ ។

គ្រានោះ ព្រះបាទចក្រពត្តិ មានព្រះបន្ទូលប្រដៅថា អ្នកទាំងឡាយ មិនត្រូវសម្លាប់សត្វទេ មិនត្រូវលបលួចទ្រព្យរបស់គេទេ មិនត្រូវប្រព្រឹត្តខុស ក្នុងកាមទាំងឡាយទេ មិនត្រូវពោលពាក្យមុសាវាទទេ មិនត្រូវផឹកទឹកស្រវឹងទេ ចូរបរិភោគតែរបស់ដែលគួរបរិភោគចុះ ។ ព្រះបាទចក្រពត្តិ ទ្រង់ប្រៀនប្រដៅក្សត្រទាំងនោះចប់ហើយ ចក្ករតន៍ក៏អណ្តែតត្រសែតទៅកាន់ទិសខាងលិច និងទិសខាងជើងទៀត ។ ឯស្តេចជាសឹកសត្រូវដែលនៅក្នុងទិសទាំងពីរនោះ ក៏នាំគ្នាចូលទៅគាល់ព្រះបាទចក្រពត្តិ ហើយក្រាបបង្គំទូលសូមចុះចូល ដូចជាស្តេចក្នុងទិសខាងកើតនោះដែរ ។ ព្រះបាទចក្រពត្តិ ទ្រង់ប្រៀនប្រដៅស្តេចទាំងនោះឲ្យឋិតនៅក្នុងសីល ៥ ដូចន័យខាងដើម ។ កាលចក្ករតន៍បង្ក្រាបផែនដីដែលមានសមុទ្រជាព្រំប្រទល់រួចស្រេចហើយ ក៏ត្រឡប់មកកាន់ព្រះរាជ-

ជាទីនោះវិញ ឋិតនៅកន្លែងរបៀងនៃសាលាវិនិច្ឆ័យ ទៀបទ្វារព្រះបរម-រាជវាំងរបស់ព្រះបាទចក្រពត្តិ នៅទីនេះជួលហាក់ដូចជាបាក់ក្ដៅ បំភ្លឺព្រះបរមរាជវាំងរបស់ព្រះបាទចក្រពត្តិ ឲ្យភ្លឺព្រោងព្រាត ។

ចាប់តាំងពីស្ដេចចក្រពត្តិអង្គទី ២ រហូតដល់អង្គទី ៧ ទ្រង់បានប្រព្រឹត្តចក្កពត្តិវត្តប្រសើរដូច ៗ គ្នា ប្រទេសក៏បានសុខ បានចម្រើនដូច ៗ គ្នា ។ ប៉ុន្តែស្ដេចចក្រពត្តិអង្គទី ៨ មិនបានប្រព្រឹត្តចក្កពត្តិវត្តដូចស្ដេចចក្រពត្តិអង្គមុន ៗ នោះទេ ម្ល៉ោះហើយ ប្រទេសក៏អាប់ឱនបានទុក្ខលំបាកច្រើន ដូចមានសេចក្ដីតទៅនេះ ៖

កាលស្ដេចក្រពត្តិអង្គទី៧ បានទ្រង់ជ្រាបថា ចក្ករត្នជាទិព្វឃ្លាតចាកទីហើយ ក៏ត្រាស់ហៅព្រះរាជបុត្រច្បងមកទូន្មាន ព្រមទាំងព្រះរាជទានរាជសម្បត្តិ រួចស្ដេចចេញទៅទ្រង់ព្រះផ្នួស កាលទ្រង់ព្រះផ្នួសបាន ៧ ថ្ងៃ ចក្ករតនជាទិព្វក៏បាត់ទៅ ។ ព្រះរាជាទ្រង់ជ្រាបថា ចក្ករតនជាទិព្វបាត់ទៅហើយ ក៏តូចព្រះហឫទ័យសោកស្ដាយ ប៉ុន្តែ មិនចូលទៅក្រាបទូលសួរចក្កពត្តិវត្តនឹងព្រះរាជឥសី ជាព្រះវររាជបិតាឡើយ ទ្រង់ប្រៀនប្រដៅអ្នកជនបទ តែតាមព្រះយោបល់ព្រះអង្គ ។ លុះចំណេរមកខាងក្រោយ អ្នកជនបទក៏មិនបានចម្រើនស្មើនឹងកាលមុន ដូចកាលស្ដេចទាំងឡាយជាន់ដើម ដែលប្រព្រឹត្តចក្កពត្តិវត្តនោះឡើយ ។ គ្រានោះមហាជនទាំងឡាយ មានពួកអាមាត្យជាដើម ក៏ប្រជុំគ្នាចូលទៅក្រាប

បង្គំទូលព្រះរាជាថា បពិត្រព្រះសម្មតិទេព បានឮថា កាលព្រះអង្គទ្រង់
ប្រៀនប្រដៅអ្នកជនបទ តែតាមយោបល់ព្រះអង្គ លុះចំណេរមកខាង
ក្រោយ ពួកអ្នកជនបទមិនបានចម្រើនស្មើនឹងកាលមុន ដូចកាលព្រះ
រាជាទាំងឡាយជាន់ដើម ដែលទ្រង់ប្រព្រឹត្តចក្កវត្តិវត្តនោះឡើយ យើង
ខ្ញុំទាំងអស់ សុទ្ធតែជាអ្នកចាំស្គាល់នូវចក្កវត្តិវត្ត ពួកខ្ញុំព្រះអង្គសូមទូល
សូមព្រះអង្គទ្រង់សួរនូវចក្កវត្តិវត្ត នឹងពួកខ្ញុំព្រះអង្គចុះ ពួកខ្ញុំព្រះអង្គមុខជា
នឹងព្យាករថ្វាយបាន ។ ព្រះរាជាទ្រង់ត្រាស់បង្គាប់ពួកអ្នកទាំងនោះ ឲ្យ
ប្រជុំគ្នា ហើយទ្រង់សួរនូវចក្កវត្តិវត្ត ។ ពួកអ្នកទាំងនោះ ក៏ព្យាករថ្វាយ ។
លុះព្រះរាជា ទ្រង់ព្រះសវនាការពាក្យព្យាករណ៍ របស់ជនទាំងនោះហើយ
ទើបទ្រង់តាក់តែង នូវការរក្សា ទប់ទល់ គ្រប់គ្រង ប្រកបដោយធម៌វិញ
ប៉ុន្តែ ទ្រង់មិនបានព្រះរាជទានព្រះរាជទ្រព្យ ដល់ពួកអ្នកខ្វះខាតទ្រព្យឡើយ
សេចក្តីទាល់ក្រ ក៏មានច្រើនឡើង ។ មានបុរសម្នាក់ លបលួចទ្រព្យគេ
ពួករាជបុរស ចាប់ចោរនោះបាន នាំទៅថ្វាយស្តេច ។ ត្រាស់សួរ ក៏ក្រាប
ទូលថា ខ្ញុំព្រះអង្គលួចមែន ។ ចុះព្រោះហេតុអ្វី បានជាឯងលួចទ្រព្យគេ? ។
ព្រោះតែខ្ញុំព្រះអង្គគ្មានរបស់អ្វីនឹងចិញ្ចឹមជីវិត ។ ព្រះរាជាទ្រង់ព្រះរាជទាន
ព្រះរាជទ្រព្យដល់បុរសនោះ រួចទ្រង់ត្រាស់បង្គាប់ថា អ្នកចូរយកទ្រព្យ
នេះទៅចិញ្ចឹមជីវិតខ្លួនផង ចិញ្ចឹមមាតាបិតាផង ចិញ្ចឹមកូនប្រពន្ធផង ប្រកប
ការងារផង ចូរតម្កល់ទក្ខិណាទាន ដែលមានផលខ្ពង់ខ្ពស់ ចំពោះ

សមណព្រាហ្មណ៍ទាំងឡាយ ជាទានអាចនាំមនុស្សឲ្យកើតក្នុងឋានសួគ៌ មានផលជាសុខ ប្រព្រឹត្តទៅដើម្បីកើតក្នុងឋានសួគ៌ផងចុះ ៗ មានបុរសម្នាក់ទៀត លួចទ្រព្យគេ ៗ ចាប់បាន នាំទៅថ្វាយស្តេច ៗ ត្រាស់សួរ ក៏ក្រាបទូលថា ខ្ញុំព្រះអង្គគ្មានរបស់អ្វីនឹងចិញ្ចឹមជីវិត បានជាលួចគេ ៗ ព្រះរាជា ទ្រង់ព្រះរាជទានព្រះរាជទ្រព្យ ដល់បុរសនោះទៀត រួចទ្រង់ត្រាស់ផ្តាំ ដូចបុរសមុននោះដែរ ៗ

ពួកមនុស្សបានឮដំណឹងថា ព្រះមហាក្សត្រ ព្រះរាជទានព្រះរាជ-ទ្រព្យ ដល់ពួកអ្នកលួចទ្រព្យគេ ក៏គិតគ្នាថា បើដូច្នោះ មានតែពួកយើងទៅលួចទ្រព្យគេដែរ ឲ្យស្តេចព្រះរាជទានព្រះរាជទ្រព្យ ដល់ពួកយើងផង ៗ លុះគ្រាជាខាងក្រោយមក មានបុរសម្នាក់ ទៅលួចទ្រព្យគេ ៗ ចាប់បាន នាំទៅថ្វាយស្តេច ៗ ត្រាស់សួរ ក៏ក្រាបទូលដូចបុរសមុនៗ ៗ ព្រះរាជាទ្រង់រិះគិតថា បើអាត្មាអញ នៅតែឲ្យទ្រព្យដល់ពួកចោរយ៉ាងនេះ មុខជាអទិន្នាទានទឹងរឹងតែតែចម្រើនឡើង បើដូច្នោះ គួរតែអញផ្ចាញ់ផ្ចាលបុរសនេះ ផ្តាច់ផ្តិលឫសគល់គឺកាត់ក្បាលវាចេញ ទើបទ្រង់ត្រាស់បង្គាប់ពួករាជបុរស ឲ្យនាំយកចោរនោះទៅកាត់ក្បាល សម្លាប់ចោលទៅ ៗ

ពួកមនុស្សបានឮដំណឹងថា អ្នកណាលួចទ្រព្យគេ ស្តេចកាត់ក្បាលអ្នកនោះ, ទើបគិតគ្នាថា បើដូច្នោះ មានតែពួកយើងនាំគ្នាធ្វើសស្ត្រាវុធដ៏មុតៗ រួចនឹងលួចទ្រព្យរបស់អ្នកណា យើងនឹងកាត់ក្បាលអ្នកនោះ

ពោល, ក៏នាំគ្នាធ្វើសស្ត្រាវុធដ៏មុតក្លា ព្យាយាមសម្លាប់អ្នកស្រុកខ្លះ អ្នកនិគមខ្លះ អ្នកនគរខ្លះ អ្នកដំណើរខ្លះ ។

កាលបើព្រះបាទចក្រពត្តិ មិនទ្រង់ព្រះរាជទានព្រះរាជទ្រព្យ ដល់ពួកអ្នកខ្សត់ទ្រព្យដូច្នេះហើយ សេចក្ដីទាល់ក្រ ក៏មានច្រើនឡើង អទិន្នាទាន ក៏មានច្រើនឡើង គ្រឿងសស្ត្រាវុធ ក៏មានច្រើនឡើង បាណាតិបាត ក៏មានច្រើនឡើង មុសាវាទ ក៏មានច្រើនឡើង ។ កូនរបស់មនុស្សអាយុ ៨ ម៉ឺនឆ្នាំ ថយចុះមកនៅត្រឹមអាយុ ៤ ម៉ឺនឆ្នាំវិញ ។ មានបុរសម្នាក់ លួចទ្រព្យគេ ។ ចាប់បាន នាំទៅថ្វាយស្ដេច ។ ត្រាស់សួរ ក៏ពោលសម្បជានមុសាវាទ (កុហកដោយដឹងខ្លួន)ថា មិនមែនលួចទេ ។ កូនរបស់មនុស្សអាយុ ៤ ម៉ឺនឆ្នាំ ថយចុះមកត្រឹមអាយុ ២ ម៉ឺនឆ្នាំវិញ ។ មានបុរសម្នាក់ លួចទ្រព្យគេ ហើយមានបុរសម្នាក់ទៀត នាំយកសេចក្ដីនុះ ទៅក្រាបទូលញុះញង់ព្រះរាជាថា បុរសនេះ លួចទ្រព្យគេ ។ បិសុណាវាចា ក៏មានច្រើនឡើង ។ កូនរបស់មនុស្សអាយុ ២ ម៉ឺនឆ្នាំ ថយចុះមកត្រឹមអាយុ ១ ម៉ឺនឆ្នាំវិញ មនុស្សពួកខ្លះ មានពណ៌សម្បុរល្អ ពួកខ្លះ មានពណ៌សម្បុរអាក្រក់ ។ ពួកអ្នកមានពណ៌សម្បុរអាក្រក់ ស្រឡាញ់ពួកអ្នកមានពណ៌សម្បុរល្អ ហើយក៏ប្រព្រឹត្តមិច្ឆាចារកន្លងភរិយាអ្នកដទៃ ។ កាមេសុមិច្ឆាចារក៏មានច្រើនឡើង ។ កូនរបស់មនុស្សអាយុ ១ ម៉ឺនឆ្នាំ ថយចុះមកត្រឹម៥ពាន់ឆ្នាំវិញ ។ ធម៌ទាំងពីរប្រការគឺ ផរុសវាចា ១

សម្ផប្បលាបៈ ១ ក៏មានច្រើនឡើង ៗ កូនរបស់មនុស្សអាយុ ៥ ពាន់ឆ្នាំ ពួកខ្លះ ថយចុះមកត្រឹមអាយុ ២ ពាន់ ៥ រយឆ្នាំវិញ ពួកខ្លះ ត្រឹម ២ ពាន់ឆ្នាំវិញ ។ អភិជ្ឈានិងព្យាបាទ ក៏មានច្រើនឡើង ៗ កូនរបស់មនុស្សអាយុ ២ ពាន់ ៥ រយឆ្នាំ ថយចុះមកត្រឹមអាយុ ១ ពាន់ឆ្នាំវិញ ។ មិច្ឆាទិដ្ឋិ ក៏មានច្រើនឡើង ៗ កូនរបស់មនុស្សអាយុ ១ ពាន់ឆ្នាំ ថយចុះមកត្រឹមអាយុ ៥ រយឆ្នាំវិញ ។ ធម៌ទាំង ៣ ប្រការគឺ អធម្មរាគៈ(១)១ វិសមលោភៈ(២)១ មិច្ឆាធម្មៈ(៣)១ ក៏មានច្រើនឡើង ៗ កូនរបស់មនុស្សអាយុ ៥ រយឆ្នាំ ថយចុះមកត្រឹមអាយុ ២ រយ ៥០ ឆ្នាំខ្លះ ២ រយឆ្នាំខ្លះ ៗ ការមិនគោរពមាតាបិតា មិនគោរពសមណព្រាហ្មណ៍ មិនកោតក្រែងត្រកូលរៀមច្បង ក៏មានច្រើនឡើង ៗ កូនរបស់មនុស្សអាយុ ២ រយ ៥០ ឆ្នាំ ថយចុះមកត្រឹមអាយុ ១ រយឆ្នាំវិញ ។

ម្នាលភិក្ខុទាំងឡាយ តទៅខាងមុខ នឹងមានសម័យដែលកូនរបស់មនុស្សទាំងនេះ មានអាយុ ១០ ឆ្នាំ ។ សម័យនោះ ពួកនាងកុមារិកាអាយុ ៥ ឆ្នាំ នឹងល្មមឲ្យមានប្តី ។ រសដ៏ប្រសើរទាំងនេះ គឺទឹកដោះថ្លា ទឹកដោះខាប់ ប្រេង ទឹកឃ្មុំ ទឹកអំពៅ អំបិល នឹងបាត់អស់

---

១ អដ្ឋកថា ថា សេចក្តីត្រេកត្រអាលក្រៅគន្លងធម៌ បាននឹងតម្រេកក្នុងទីមិនសមគួរ គឺ តម្រេកក្នុងមាតា ម្តាយមីងខាងមាតា ម្តាយធំខាងបិតាជាដើម ។ ២ សេចក្តីចង់បានខ្លាំងពេក ។ ៣ សេចក្តីប្រាថ្នាខុសគន្លងធម៌ បាននឹងតម្រេករបស់បុរសក្នុងបុរស របស់ស្ត្រីក្នុងស្រី ។

ទៅ ៗ ស្មៅតែលលកនឹងជាភោជនដ៏ប្រសើរ ឥឡូវនេះ បាយស្រូវសាលីលាយដោយសាច់ ជាភោជនដ៏ប្រសើរ ដូចម្ដេចមិញ, ដល់ទៅសម័យមនុស្សអាយុ ១០ ឆ្នាំ ស្មៅតែលលកនឹងជាភោជនដ៏ប្រសើរ យ៉ាងនោះឯង ៗ កុសលកម្មបថទាំង ១០ នឹងសាបសូន្យទៅគ្រប់អន្លើ ៗ អកុសលកម្មបថទាំង ១០ នឹងចម្រើនច្រើនឡើង ៗ សូម្បីពាក្យថាកុសលក៏គ្មាន បើដល់ម្ល៉ោះទៅហើយ អ្នកធ្វើកុសល តើនឹងមានមកពីណា? ៗ បើអ្នកណា មិនគោរពមាតាបិតា សមណព្រាហ្មណ៍ មិនកោតក្រែងត្រកូលរៀមច្បង អ្នកនោះ ទើបជាអ្នកគួរគេបូជាផង គួរគេសរសើរផង ៗ នឹងគ្មានសេចក្ដីគោរពកោតក្រែងថា អ្នកនេះជាមាតា ជាម្ដាយមីងខាងមាតា ជាបិតា ជាម្ដាយមីងខាងបិតា ជាម្ដាយធំខាងមាតា ជាភរិយារបស់អាចារ្យ ឬថា ជាប្រពន្ធរបស់គ្រូនៃខ្លួន ដូច្នេះឡើយ ៗ សត្វលោកនឹងប្រឡូកប្រឡំគ្នា ដូចជាពពែ មាន់ ជ្រូក ឆ្កែ ចចក ដូច្នោះឯង ៗ

ម្នាលភិក្ខុទាំងឡាយ កាលមនុស្សលោកមានអាយុ ១០ ឆ្នាំនោះ គំនុំដ៏ក្លៀវក្លា ព្យាបាទដ៏ក្លៀវក្លា ចិត្តប្រទូស្តដ៏ក្លៀវក្លា ចិត្តប្រាថ្នានឹងសម្លាប់ដ៏ក្លៀវក្លា នឹងកើតប្រាកដដល់គ្នានិងគ្នាគឺ មាតានិងបុត្ត ៗ បុត្តនិងមាតា ៗ បិតានិងបុត្ត ៗ បុត្តនិងបិតា ៗ បងប្អូនប្រុសនិងបងប្អូនស្រី ៗ ប្រៀបដូចព្រានម្រឹគ ឃើញម្រឹគហើយ ប្រុងតែបាញ់សម្លាប់ដូច្នោះ ៗ គ្រានោះ

សត្ថន្តរកប្ប[១] នឹងកើតមានឡើងអស់ ៧ ថ្ងៃ ៗ មនុស្សទាំងនោះ នឹងសំគាល់គ្នាថាដូចជាម្រឹគ ៗ គ្រឿងសស្ត្រាវុធដ៏មុតក្លា នឹងជាប់នៅតែក្នុងដៃនៃមនុស្សទាំងនោះ ៗ មនុស្សទាំងនោះ សំគាល់ថា នេះជាម្រឹគ ហើយក៏ផ្តាច់ជីវិតគ្នានិងគ្នា ដោយគ្រឿងសស្ត្រាវុធដ៏មុតក្លា ៗ បណ្តាមនុស្សទាំងនោះ មនុស្សពួកខ្លះ នឹងគិតគ្នាថា ពួកយើង កុំសម្លាប់បុរសណាមួយឡើយ ទាំងបុរសណាមួយ ក៏កុំសម្លាប់ពួកយើងឡើយ បើដូច្នោះ ពួកយើង គួរតែចូលទៅកាន់ស្មៅស្បាត ព្រៃស្បាត ឈើស្បាត ស្ទឹង ដែលទៅមកបានដោយលំបាក ឬ ភ្នំមិនរាបស្មើ ហើយយកមើមនិងផ្លែក្នុងព្រៃជាអាហារចិញ្ចឹមជីវិត គិតរួច ក៏នាំគ្នាចូលទៅកាន់ទីកន្លែង តាមការដំនុំគ្នានោះ នៅអស់ ៧ ថ្ងៃ ៗ លុះថ្ងៃ ៧ នោះកន្លងហើយ ទើបអ្នកទាំងនោះ ចេញមកអំពីទីកន្លែងដែលជ្រកពួននោះ ហើយឱបរឹតគ្នាទៅវិញទៅមក រួចនិយាយពាក់ទាក់ លួងលោមគ្នា ក្នុងពេលទាំងឡាយថា ម្នាលអ្នកដ៏ចម្រើន អ្នករស់នៅដូចហ្នឹងសត្វដែលយើងបានឃើញហើយ ៗ

ម្នាលភិក្ខុទាំងឡាយ លំដាប់នោះឯង មនុស្សទាំងនោះ នឹងត្រិះរិះថា ពួកយើងនេះឯង បានជាព្រាត់ប្រាស ស្លាប់បាត់បង់អស់ញាតិជាច្រើនដូច្នេះ ព្រោះហេតុតែកាន់ធម៌អកុសលទាំងឡាយ បើដូច្នោះ មានតែពួកយើងធ្វើកុសលវិញ តើគួរធ្វើកុសលដូចម្តេច ? ណ្ហើយចុះ ពួក

---

១ លោកវិនាសទៅដោយគ្រឿងសស្ត្រាវុធ ។

យើង គួរវៀរចាកបាណាតិបាត ប្រព្រឹត្តសមាទាននូវកុសលធម៌នេះចុះ ។ ទើបអ្នកទាំងនោះ នាំគ្នាវៀរចាកបាណាតិបាត ប្រព្រឹត្តសមាទាន នូវកុសលធម៌នេះ ក៏បានចម្រើនអាយុនិងពណ៌សម្បុរឡើង ព្រោះហេតុដែលបានសមាទាន នូវកុសលធម៌ទាំងឡាយ ។

ម្នាលភិក្ខុទាំងឡាយ កូនរបស់ពួកមនុស្សមានអាយុ ១០ ឆ្នាំ ក៏ត្រឡប់ទៅជាមានអាយុចម្រើន ទៅឡើងដល់ ២០ ឆ្នាំវិញ ។ អ្នកទាំងនោះជំនុំគ្នាថា ពួកយើង បានចម្រើនអាយុនិងពណ៌សម្បុរឡើងវិញ ក៏ព្រោះហេតុតែបានសមាទាន នូវកុសសធម៌ទាំងឡាយ បើដូច្នោះ ពួកយើង គួរតែធ្វើកុសលឲ្យច្រើន ក្រៃលែងជាងនេះទៅទៀត តើគួរធ្វើកុសលអ្វី ? ណ្ហើយចុះ ពួកយើងគួរតែវៀរចាកអទិន្នាទាន គួរតែវៀរចាកកាមេសុមិច្ឆាចារ គួរតែវៀរចាកមុសាវាទ គួរតែវៀរចាកបិសុណាវាចា គួរតែវៀរចាកផរុសវាចា គួរតែវៀរចាកសម្ផប្បលាបៈ គួរលះបង់អភិជ្ឈា គួរលះបង់ព្យាបាទ គួរលះបង់មិច្ឆាទិដ្ឋិចេញ គួរលះបង់ធម៌ ៣ ប្រការគឺ អធម្មរាគៈ ១ វិសមលោភៈ ១ មិច្ឆាធម្មៈ ១ ចេញ បើដូច្នោះ ពួកយើងគួរតែជាអ្នកគោរពមាតាបិតា គោរពសមណព្រាហ្មណ៍ និងជាអ្នកប្រព្រឹត្តកោតក្រែងត្រកូលរៀមច្បង ពួកយើងគួរតែនាំគ្នាប្រព្រឹត្តសមាទាន នូវកុសលធម៌ទាំងនេះចុះ ។

ម្នាលភិក្ខុទាំងឡាយ កាលបើអ្នកទាំងនោះ គោរពមាតាបិតា និង

សមណព្រាហ្មណ៍ គោរពកោតក្រែងត្រកូលវៀមច្បង ប្រព្រឹត្តសមាទាន នូវកុសលធម៌ទាំងនេះហើយ ក៏បានចម្រើនពណ៌សម្បុរ និងអាយុឡើងវិញ ។ កូនរបស់ពួកមនុស្សដែលមានអាយុ ២០ ឆ្នាំ ក៏ទ្វេឡើងដល់ទៅអាយុ ៤០ ឆ្នាំ ។ កូនអ្នកទាំងនោះ រេះតែចម្រើនអាយុទ្វេឡើង តាំងពី ៤០ ឆ្នាំ រហូតដល់អាយុ ៨០ ឆ្នាំ ។ ដល់ ១៦០ ឆ្នាំ ។ ដល់ ៣២០ ឆ្នាំ ។ ដល់ ៦៤០ ឆ្នាំ ។ ដល់ ២ ពាន់ឆ្នាំ ។ ដល់ ៤ ឆ្នាំ ។ ដល់ ៨ ពាន់ឆ្នាំ ។ ដល់ ២ ម៉ឺនឆ្នាំ ។ ដល់ ៤ ម៉ឺនឆ្នាំ ។ ទ្វេឡើងរហូតទៅដល់អាយុ ៨ ម៉ឺនឆ្នាំ ព្រោះហេតុតែអ្នកទាំងនោះ បានកាន់កុសលធម៌ទាំងឡាយ ដូចពោលហើយខាងដើម ។

ម្នាលភិក្ខុទាំងឡាយ កាលបើពួកមនុស្ស មានអាយុ ៨ ម៉ឺនឆ្នាំ ពួកនាងកុមារិកា មានអាយុ ៥ រយឆ្នាំ ទើបល្មមឲ្យមានប្ដី ។ សម័យនោះនឹងមានអាពាធតែ ៣ យ៉ាងគឺ ចំណង់កងអាហារ ១ បរិភោគអាហារមិនបាន ១ សេចក្ដីគ្រាំគ្រាកងកាយ ១ ។ ជម្ពូទ្វីបនេះ នឹងជាទ្វីបស្ដុកស្ដម្ភធំទូលាយ មានស្រុកនិគមរាជធានី ត ។ គ្នាមួយរយៈមាន់ហើរធ្លាក់ ។ ជម្ពូទ្វីប នឹងពេញដោយមនុស្ស រកចន្លោះគ្មានទេ ដូចអវិចិនរក ពុំនោះសោត ដូចព្រៃប្របុស ឬ ព្រៃកំពង់ភ្លុ ។ ក្រុងពារាណសីនេះ នឹងប្រែឈ្មោះជា កេតុមតីរាជធានី វិញ ជារាជធានីស្ដុកស្ដម្ភធំទូលាយ មានមនុស្សច្រើនកុះករ នឹងមានភិក្ខាហារដ៏សម្បូណ៌ ។ ក្នុងជម្ពូទ្វីបនេះ

ទឹងមាននគរ ៨ ម៉ឺន ៤ ពាន់ មាននគរកេតុមតីរាជធានីឯងជាប្រធាន ។

ម្នាលភិក្ខុទាំងឡាយ សម័យនោះ ទីងមានព្រះរាជាមួយព្រះអង្គ ព្រះនាមសង្ខ: ទ្រង់កើតឡើងក្នុងកេតុមតីរាជធានី ជាស្តេចចក្រពត្តិ ទ្រង់ជាធម្មិកធម្មរាជ ជាឥស្សរលើផែនដី មានសមុទ្រទាំង ៤ ជាទីបំផុត ជាស្តេចឈ្នះសង្គ្រាម ទ្រង់មានជនបទមាំមួន ទ្រង់បរិបូណ៌ដោយរតន៍ ៧ ប្រការ ព្រះអង្គទីងមានព្រះរាជបុត្រច្រើនជាងពាន់ សុទ្ធសឹងតែក្លៀវក្លា អង់អាច អាចសង្កត់សង្កិនទូវពួកសេនារបស់ស្តេចដទៃបាន ។ ព្រះបាទសង្ខ:នោះ ទ្រង់គ្រងគ្រាគ្រប់គ្រងនូវផែនដី ដែលមានសាគរជាទីបំផុត ដោយធម៌ មិនបាច់ប្រើអាជ្ញា មិនបាច់ប្រើគ្រឿងសស្ត្រាវុធទេ ។

ម្នាលភិក្ខុទាំងឡាយ សម័យនោះ ព្រះមានព្រះភាគទ្រង់ព្រះនាមមេត្តេយ្យ: ទឹងកើតឡើងក្នុងលោក ទ្រង់ឆ្ងាយចាកកិលេស ទ្រង់ត្រាស់ដឹងញេយ្យធម៌ទាំងពួងដោយប្រពៃ ចំពោះព្រះអង្គ ។ បេ ។ ទ្រង់មានដំណើរទៅកាន់ត្រៃភពខ្ពង់ខ្ពស់បោលហើយ ដូចជាតថាគតដែលឆ្ងាយចាកកិលេស ។ បេ ។ ក្នុងកាលឥឡូវនេះដែរ ។

ព្រះបាទសង្ខ: ទ្រង់ត្រាស់បង្គាប់ឲ្យលើកប្រាសាទ ដែលព្រះបាទមហាបនាទឲ្យកសាង ហើយទ្រង់ប្រថាប់នៅក្នុងប្រាសាទនោះ ទ្រង់លះបង់(១)ប្រាសាទនោះ ឲ្យជាទានដល់ពួកសមណព្រាហ្មណ៍ មនុស្សកំព្រា

---

១ អដ្ឋកថា ថា ទ្រង់អធិដ្ឋានឲ្យប្រាសាទនោះបែកខ្ទេច ហើយទ្រង់ព្រះរាជទាន ។

អ្នកដំណើរ អ្នកនិយាយសរសើរហើយសូម និងពួកសូម រួចទ្រង់ដាក់ព្រះកេសានិងព្រះមស្សុ ទ្រង់ស្លៀកដណ្ដប់កាសាវពស្ត្រ ចេញចាកពជាគារស្ថាន ចូលទៅកាន់ផ្នួស ក្នុងសំណាក់ព្រះមេត្តេយ្យៈ ដ៏មានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ទ្រង់ព្រះផ្នួសស្រេចហើយ ទ្រង់គេចចេញទៅតែមួយព្រះអង្គឯង ឥតមានសេចក្ដីប្រមាទឡើយ មានសេចក្ដីព្យាយាម ជាគ្រឿងដុតបង់នូវកិលេស មានព្រះហឫទ័យបែរឆ្ពោះទៅរកព្រះនិព្វាន ពុំយូរប៉ុន្មាន ក៏ព្រះសង្ខត្ថេរ បានត្រាស់ដឹង បានធ្វើឲ្យជាក់ច្បាស់ នូវអនុត្តរធម៌ ដែលជាទីបំផុតនៃព្រហ្មចារ្យ ដោយខ្លួនឯង ក្នុងបច្ចុប្បន្ននេះ ក៏សម្រាន្តទៅ ដោយឥរិយាបថទាំង ៤ ។

ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរយកខ្លួនជាទីពឹងពំនាក់ ចូរយកធម៌ជាទីពឹងពំនាក់ កុំយករបស់ដទៃជាទីពឹងពំនាក់ឡើយ ។

ចុះភិក្ខុយកខ្លួន យកធម៌ជាទីពឹងពំនាក់ តើដូចម្ដេច ?

ភិក្ខុក្នុងសាសនានេះ ពិចារណានូវកាយ ។ នូវវេទនា ។ នូវចិត្ត ។ នូវធម៌ក្នុងធម៌ទាំងឡាយជាប្រក្រតី មានព្យាយាមជាគ្រឿងដុតកំដៅនូវកិលេស មានប្រាជ្ញាដឹងសព្វ មានស្មារតី កំចាត់បង់នូវអភិជ្ឈា និងទោមនស្សក្នុងលោកបាន ។ យ៉ាងនេះ ហៅថា ភិក្ខុយកខ្លួន យកធម៌ជាទីពឹងពំនាក់ មិនយករបស់ដទៃជាទីពឹងពំនាក់ឡើយ ។

ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរប្រព្រឹត្តក្នុងគោចរ ជា

វិស័យដែលមានមកអំពីបិតានៃខ្លួន ទើបនឹងបានចម្រើនអាយុផង បានចម្រើនពណ៌សម្បុរផង បានចម្រើនសេចក្ដីសុខផង បានចម្រើនភោគៈផង បានចម្រើនកម្លាំងផង ។

ចុះអ្វី ជាហេតុឲ្យបានចម្រើនអាយុរបស់ភិក្ខុ?

ភិក្ខុក្នុងសាសនានេះ ចម្រើនឥទ្ធិបាទ ប្រកបដោយឆន្ទសមាធិ និងបធានសង្ខារ ចម្រើនឥទ្ធិបាទ ប្រកបដោយវីរិយសមាធិ និងបធានសង្ខារ . . . ចិត្តសមាធិ និងបធានសង្ខារ . . . វីមំសាសមាធិ និងបធានសង្ខារ ភិក្ខុនោះ បើមានបំណងនឹងរស់នៅ គប្បីឋិតនៅអស់ ១ អាយុកប្ប ឬ ១ អាយុកប្បក្តាយ ព្រោះហេតុដែលបានចម្រើន បានធ្វើឲ្យច្រើន នូវឥទ្ធិបាទទាំង ៤ នេះ ។ នេះឯង ជាហេតុឲ្យបានចម្រើនអាយុរបស់ភិក្ខុ ។

ចុះអ្វី ជាហេតុឲ្យបានចម្រើនពណ៌សម្បុររបស់ភិក្ខុ ?

ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសីល សង្រួមក្នុងបាតិមោក្ខសំវរៈ បរិបូណ៌ដោយអាចារៈនិងគោចរៈ ជាអ្នកឃើញភ័យក្នុងទោសសូម្បីបន្តិចបន្តួច សមាទាន សិក្សា ក្នុងសិក្ខាបទទាំងឡាយ ។ នេះឯង ជាហេតុឲ្យបានចម្រើនពណ៌សម្បុររបស់ភិក្ខុ ។

ចុះអ្វី ជាហេតុឲ្យបានចម្រើនសេចក្ដីសុខរបស់ភិក្ខុ ?

ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ចូលបឋមជ្ឈាន ដែលប្រកបដោយវិតក្កៈវិចារៈ

មានបីតិនិងសុខៈ ដែលកើតអំពីសេចក្តីស្ងប់ស្ងាត់ជាអារម្មណ៍ ភិក្ខុនោះលុះរម្ងាប់វិតក្កៈវិចារៈរួចហើយ ។ បេ ។ ក៏ចូលទុតិយជ្ឈាន ។ ចូលតតិយជ្ឈាន ។ ចូលចតុត្ថជ្ឈាន ។ នេះឯង ជាហេតុឲ្យបានចម្រើនសេចក្តីសុខរបស់ភិក្ខុ ?

ចុះអ្វី ជាហេតុឲ្យបានចម្រើនភោគៈរបស់ភិក្ខុ ?

ភិក្ខុក្នុងសាសនានេះ មានចិត្តប្រកបដោយមេត្តា ផ្សាយទៅកាន់ទិស១ ទិសទី២ ក៏ដូចគ្នា ទិសទី ៣ ក៏ដូចគ្នា ទិសទី ៤ ក៏ដូចគ្នា តាមទំនងនេះ សូម្បីទិសខាងលើ ទិសខាងក្រោម ទិសទទឹង ក៏មានចិត្តប្រកបដោយមេត្តាដ៏ធំទូលាយ រកប្រមាណមិនបាន ជាចិត្តឥតមានចងពៀរ ឥតមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងអស់ ព្រោះហេតុប្រៀបផ្ទឹមខ្លួន ឲ្យស្មើនឹងសត្វលោកទាំងអស់ ក្នុងទិសទាំងពួង ។ មានចិត្តប្រកបដោយករុណា ។ មានចិត្តប្រកបដោយមុទិតា ។ មានចិត្តប្រកបដោយឧបេក្ខា ផ្សាយទៅកាន់ទិស ១ ទិសទី ២ ក៏ដូចគ្នា ។ បេ ។ ព្រោះហេតុប្រៀបផ្ទឹមខ្លួន ឲ្យស្មើនឹងសត្វលោកទាំងអស់ ក្នុងទិសទាំងពួង ។ នេះឯង ជាហេតុឲ្យបានចម្រើនភោគៈរបស់ភិក្ខុ ។

ចុះអ្វី ជាហេតុឲ្យបានចម្រើនកម្លាំងរបស់ភិក្ខុ?

ភិក្ខុក្នុងសាសនានេះ បានត្រាស់ដឹង បានធ្វើឲ្យជាក់ច្បាស់

ដោយខ្លួនឯង នូវចេតោវិមុត្តិនិងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយក្នុងបច្ចុប្បន្ន ហើយសម្រាន្តនៅដោយឥរិយាបថទាំង៤ ។ នេះឯង ជាហេតុឲ្យបានចម្រើនកម្លាំងរបស់ភិក្ខុ ។

ម្នាលភិក្ខុទាំងឡាយ តថាគត ពិចារណាមើលមិនឃើញកម្លាំងដទៃ សូម្បីតែកម្លាំង ១ ដែលបុគ្គលគ្របសង្កត់បានដោយកម្រ ឲ្យដូចជាកម្លាំងនៃមារនេះឡើយ ។ ម្នាលភិក្ខុទាំងឡាយ បុណ្យនេះ តែងចម្រើនឡើងយ៉ាងនេះ ព្រោះហេតុសមាទាននូវកុសលធម៌ទាំងឡាយ ។

ចប់ ចក្កវត្តិសូត្រ ។

# បម្លើយក្នុងប្រស្នាខាងដើម

ដែលចោទឡើងថា « មកពីហេតុអ្វី បានជាមនុស្សធ្វើអំពើអាក្រក់កើត » ?

សូមដោះស្រាយចំណោទនេះ ដោយសរុបសេចក្តីតាមលំអាននៃព្រះពុទ្ធតម្រាស់ ក្នុងចក្កវត្តិសូត្រ ថា :

ម្នាលភិក្ខុទាំងឡាយ កាលបើព្រះបាទចក្រពត្តិ មិនទ្រង់ព្រះរាជទានព្រះរាជទ្រព្យ ដល់ពួកអ្នកក្រត់ទ្រព្យហើយ សេចក្តីទលិទ្ទ ក៏មានច្រើនឡើង កាលបើសេចក្តីទលិទ្ទ មានច្រើនឡើងហើយ អទិន្នាទាន ក៏មានច្រើនឡើង កាលបើអទិន្នាទាន មានច្រើនឡើងហើយ គ្រឿងសស្ត្រាវុធ

ក៏មានច្រើនឡើង កាលបើគ្រឿងសស្ត្រាវុធ មានច្រើនឡើងហើយ ចាណាតិបាត ក៏មានច្រើនឡើង កាលបើបាណាតិបាត មានច្រើនឡើងហើយ មុសាវាទ ក៏មានច្រើនឡើង កាលបើមុសាវាទ មានច្រើនឡើងហើយ បិសុណាវាចា ក៏មានច្រើនឡើង កាលបើបិសុណាវាចា មានច្រើនឡើងហើយ កាមេសុមិច្ឆាចារ ក៏មានច្រើនឡើង កាលបើកាមេសុ-មិច្ឆាចារ មានច្រើនឡើងហើយ ផរុសវាចានិងសម្ផប្បលាបៈ ក៏មានច្រើនឡើង កាលបើធម៌ទាំង ២ ប្រការនេះ មានច្រើនឡើងហើយ អភិជ្ឈានិងព្យាបាទ ក៏មានច្រើនឡើង កាលបើអភិជ្ឈានិងព្យាបាទ មានច្រើនឡើងហើយ មិច្ឆាទិដ្ឋិ ក៏មានច្រើនឡើង កាលបើមិច្ឆាទិដ្ឋិ មានច្រើនឡើងហើយ អធម្មរាគៈ១ វិសមលោភៈ១ មិច្ឆាធម្មៈ១ ក៏មានច្រើនឡើង កាលបើធម៌ទាំង ៣ ប្រការនេះ មានច្រើនឡើងហើយ ការមិនគោរពមាតាបិតា មិនគោរពសមណព្រាហ្មណ៍ មិនប្រព្រឹត្តកោតក្រែងត្រកូលរៀមច្បង ក៏មានច្រើនឡើង កាលបើធម៌ទាំងនេះ មានច្រើនឡើងហើយ អាយុនិងពណ៌សម្បុររបស់មនុស្សទាំងនោះ ក៏ថយចុះ គឺថយតាំងពីអាយុ ៨ ម៉ឺនឆ្នាំ ចុះមកនៅតែត្រឹមតែអាយុ ១០ ឆ្នាំវិញ ។

កាលដំណាន់មនុស្ស មានអាយុ ១០ ឆ្នាំនោះ នាងកុមារិកាអាយុ ៥ ឆ្នាំ មានប្ដី ។ រសដ៏ប្រសើរគឺ ទឹកដោះថ្លា ទឹកដោះខាប់ ប្រេង ទឹកឃ្មុំ ទឹកអំពៅ អំបិល បាត់អស់ទៅ ស្មៅតែលលកជាភោជនដ៏ប្រសើរ ស្មើនឹង

បាយស្រូវសាលីលាយដោយសាច់ កន្លែកាលឥឡូវនេះ ៗ កុសលកម្មបថទាំង ១០ សាបសូន្យទៅគ្រប់អន្លើ អកុសលកម្មបថទាំង ១០ ចម្រើនច្រើនឡើង ៗ សូម្បីតែពាក្យថា កុសល គ្មានទេ បើដល់ម្លោះទៅហើយ អ្នកធ្វើកុសល តើនឹងមានមកពីណា? ៗ បើអ្នកណា មិនគោរពមាតាបិតា មិនគោរពសមណព្រាហ្មណ៍ មិនកោតក្រែងត្រកូលវៀមច្បង ទើបគេបូជា គេសរសើរអ្នកនោះថា ជាមនុស្សគ្រាន់បើទៅវិញ ៗ គ្មានចិត្តកោតក្រែង ថា អ្នកនេះជាមាតា ជាម្ដាយមីងខាងមាតា ជាបិតា ជាម្ដាយមីងខាងបិតា ជាម្ដាយធំខាងមាតា ជាភរិយារបស់អាចារ្យ ឬថា ជាប្រពន្ធរបស់គ្រូនៃខ្លួនឡើយ ៗ សត្វលោកនឹងប្រឡូកប្រឡំគ្នា ដូចជា ពពែ មាន់ ជ្រូក ឆ្កែ ចចក ៗ ចិត្តគំនុំ ព្យាបាទ ប្រទូស្ត ប្រុងសម្លាប់ដំកៀវគ្នា កើតប្រាកដដល់គ្នានិងគ្នា គឺ មាតានិងបុត្ត ៗ បុត្តនិងមាតា ៗ បិតានិងបុត្ត ៗ បុត្តនិងបិតា ៗ បងប្អូនប្រុសនិងបងប្អូនស្រី ៗ បងប្អូនស្រីនិងបងប្អូនប្រុស ។ សំគាល់មនុស្សផងគ្នាថា ជាម្រឹគទៅវិញ ហើយប្រុងតែនឹងសម្លាប់គ្នាទៅវិញទៅមក ហាក់បីដូចព្រានតាមសម្លាប់ម្រឹគ ៗ សម័យនោះ មានសត្ថន្តរកប្ប ៧ ថ្ងៃ មនុស្សសំគាល់គ្នាថាជាម្រឹគ កាន់អាវុធជាប់នឹងដៃជានិច្ច ហើយសម្លាប់គ្នានិងគ្នា រហូតគ្រប់ ៧ ថ្ងៃទើបបាត់

ស្លាក់ ៗ ប៉ុន្តែ មនុស្សមិនស្លាប់សូន្យអស់រលីងទេ នៅមានសល់អ្នកខ្លះ ដែលគេនាំគ្នារត់ចូលទៅជ្រកពួន លាក់ខ្លួននៅក្នុងព្រៃស្បាត ៗ លុះផុតពី ៧ ថ្ងៃនោះហើយ គេនាំគ្នាចេញពីព្រៃមកវិញ ក៏ប្រែចិត្តគំនិតប្រព្រឹត្តកាន់កុសលធម៌ទាំងឡាយ ទើបបានចម្រើនអាយុពី ១០ ឆ្នាំ ទៅដល់ ២០ ឆ្នាំ ៤០ ឆ្នាំ ៦០ ឆ្នាំ ៗលៗ រហូតដល់អាយុ ៨ ម៉ឺនឆ្នាំឡើងវិញ ។

ក្នុងជំនាន់មនុស្សអាយុ ៨ ម៉ឺនឆ្នាំនោះ ព្រះបាទចក្រពត្តិព្រះនាមសង្ខៈទ្រង់កើតឡើង ។ ព្រះសម្មាសម្ពុទ្ធ ព្រះនាមមេត្តេយ្យៈ ទ្រង់បានត្រាស់ឡើងក្នុងលោក ។ កុសលធម៌ទាំងពួង មានកុសលកម្មបថ ១០ ជាដើម ក៏កើតមានបរិបូណ៌ ដូចមានក្នុងចក្កវត្តិសូត្រស្រាប់ ។

នៅទីបញ្ចប់នេះ សូមអស់លោកអ្នកជាព្រឹទ្ធាចារ្យ ជួយពិចារណាមើលផង ក្នុងជំនាន់យើងថយអាយុចុះពី ១ រយឆ្នាំមកនេះ តើមានអកុសលធម៌អ្វីខ្លះ កើតចម្រើនច្រើនឡើងហើយ ។

ប ប់

# ផ្នែកអក្សរសាស្ត្រ

| | |
|---|---|
| អក្សរសាស្ត្រខ្មែរ | ខ្មែរគួរថែថ្នម |
| ឲ្យបានខ្ជាប់ខ្ជួន | គង់វង្សគត់មត់ |
| ព្រោះអក្សរជាតិ | គោលជាតិប្រាកដ |
| អក្សររលត់ | ជាតិក៏រលាយ |

ប.ព.

## វចនានុក្រមសំស្ក្រឹត-ខ្មែរ

(ត)

*ព្រះមហា ចា៉ង ទាត់ រៀបរៀង*

អនុគម បុ. កិរិយាទៅតាម, កិរិយាជូនទៅ (ទោះនៅរស់ ឬ ស្លាប់), កិរិយាធ្វើត្រាប់ ។

អនុគមន៍ នបុ. កិរិយាទៅតាម, កិរិយាជូនទៅ ។

អនុគម្យ គុ. ដែលគប្បីទៅតាម ។

អនុគជ៌ ធាតុ. ស្រែកតបវិញ ។ អនុគជ៌ិត នបុ. រំពង ។

អនុគា ធាតុ. ទៅតាម, ដើរតាមក្រោយ ។

អនុគា ធាតុ. ច្រៀងជូន, ច្រៀងផងជូនផង ។

អនុគាមិន៑ គុ. ដែលទៅតាម, ដែលជូន, ។ បុ. អ្នកជូន, អ្នកបំរើ, ខ្ញុំ, អ្នកហែហម ។

អនុគាមុក គុ. ដែលធ្លាប់តែជូន ឬ នាំ ។

អនុគិរម៉ិ ក្រិ. វិ. នៅលើភ្នំ ។

អនុគីត នបុំ. អនុគីត, ការច្រៀងជូន ។ អនុគីតា ស្ត្រី. ឈ្មោះ

កណ្ឌមួយក្នុងគម្ពីរមហាភារត ។

អនុគុណ គុ.ដែលមានគុណដូចគ្នា, សមគួរដល់ ។ អនុគុណាម៉ិ សមគួរ

តាមគុណ ។ —ត្វ នបុំ. ភាវនៃបុគ្គលជាអនុគុណ ។

—វិន្ត គុ. ដែលមានគុណគួរដល់ (ជាតិខ្លួន) ។

អនុគុប្ត គុ. ដែលរក្សារឿយៗ, ដែលបិតបាំង ។

អនុគ្ឫធិ ធាតុ. ចង់រឿយៗ, ចង់ណាស់, ល្មោភពេក ។

អនុគ្ឫ ធាតុ. និយាយរឿយៗ, និយាយបន្ថែម ។

អនុគៃ ធាតុ. ច្រៀងរឿយៗ ។

អនុគោទម៉ិ ក្រិ. វិ. ជិតស្ទឹងគោទា (វរី) ។

អនុគោប្ត្ឫ ក. ន. អ្នកជួយ ។

អនុគ្រហ៊ិ ធាតុ. អនុគ្រោះ (កិរិយាយកចិត្តទៅកាន់រឿយៗ) ។

អនុគ្ឫហីត គុ. ដែលអនុគ្រោះ ។

អនុគ្រហ បុំ. កិរិយាអនុគ្រោះ, ការអនុគ្រោះ ។

( នៅមានត )

# ព្រះរាជនិពន្ធរាមកេរ្តិ៍
(ត)
ភាគ ៨

លោក ឌឹក-គាម

ស្រាវជ្រាវ និង រៀបរៀង

កាលនោះ ទើបអង្គព្រះកោសិយក្រាបទូលស្នងទៅវិញថា ឥឡូវនេះ មហាឥសីទាំង ៤ អង្គ មកក្រាបទូលសម្តេចព្រះឥសូរគ្រូវ័យថា ត្រៃលោកា បានសេចក្តីក្តៅក្រហាយខ្លាំងណាស់ដូចភ្លើងក្រុត ទើបព្រះបមមកុដកៃលាស ស្តេចត្រាស់ឲ្យយើងខ្ញុំមកអញ្ជើញព្រះអង្គទៅគាល់ក្នុងវេលានេះ ៗ ទើបឯអង្គព្រះនារាយណ៍នោះ លុះបានស្តាប់ស្តេចទេវរាជទូលដូច្នោះហើយ ព្រះអង្គក៏ទ្រង់គិតរំពឹងទៅបានដឹងក្នុងព្រះអង្គ ក្នុងគ្រានេះត្រូវអង្គអញនឹងបែងភាគ ចុះទៅបង្ក្រាបពួកពាលបច្ចាមិត្រអសុរ-រិទ្ធិយក្សា ពួកវាទាំងអស់នេះ សុទ្ធតែមានឫទ្ធានុភាព សិល្បសាស្ត្រវាក៏មានគ្រប់ ៗ គ្នា ជាវិសេសអញតែម្នាក់ឯងនេះ នឹងដើរត្រាច់បង្ក្រាបទៅឃើញជាមិនសម្រេចបានដោយងាយ សែនមហាលំបាកណាស់ ទ្រង់គិតហើយព្រះអង្គទ្រង់បែរភក្ត្រមកមានបន្ទូលថា: ម្នាលនាងកល្យាណណុងលក្ខណ៍លក្ស្មីដួងជីវី នាងជាជនទីក្នុងត្រៃលោកា ឥឡូវនេះណា បងនឹងបែងភាគចុះទៅរំលាងអសុរយក្សា សែនមហាលំបាកយ៉ាកយ៉ាប់ដល់ ៩ គ្រា ដ្បិតពួកអសុរាមានឫទ្ធាណាស់ បងគិតទៅឃើញច្បាស់ជាលំបាកទៅថ្ងៃមុខខាយ សូមអញ្ជើញព្រះនាងនោមឆាយជំរួមជីវី

១ នឹងបង់តាំងបល្ល័ង្កនាគផង ចុះទៅជួយបងនឹងដើរបង្ក្រាបអសុរកឲ្យ លោកាបានសុខក្សេមក្សាន្តសប្បាយ ថាហើយអង្គព្រះនារាយណ៍ក៏ទ្រង់ ចាប់ស័ង្ខមោលីនិងចក្រកែវមណីគទាវុធ តាំងព្រះលក្ស្មីផង ហើយ ព្រះអង្គតាំងពីនោះ ក៏ស្តេចចាកពីក្រសៀនឆ្នេរសាគរទ្រង់ជិះគ្រុឌពជ-បក្សាជាពាហនៈមកជាមួយនឹងអស់ទេពទេវិន្ទនោះ ក៏ស្តេចហែតាមមក ៗ លុះដល់គិរីកៃលាសហើយ ស្តេចក៏បបួលព្រះនាងយាងទៅតាំងព្រះបាទ អនន្តនាគ ចូលទៅនោសម្តេចព្រះឥសូរលោកា ៗ កាលនោះ ទើបអង្គ ព្រះឥស្សរនោះ លុះឃើញព្រះនារាយណ៍ធិបតីតាំងព្រះលក្ស្មីនិងព្រះបាទ គ្រុឌពជនិងព្រះបល្ល័ង្កនាគមកព្រមស្រេច ព្រះអង្គស្តេចក៏សែនត្រេក សោមនស្ស ហើយអង្គព្រះឥស្សរស្តេចក៏ជ្រាបដឹងហេតុថា នារាយណ៍ នេះវិសេសសេដ្ឋា ទើបស្តេចមានព្រះឱង្ការថា នៃនារាយណ៍អើយ អ្នកអើយ ឥឡូវនេះ លោកាកើតសេចក្តីក្តៅក្រហាយដូចភ្លើងឆេះ ការ នេះត្រូវអ្នកចុះទៅបង្ក្រាបប្រាប ពួកអសុរពាលា អ្នកយាត្រាទៅបដិសន្ធិ នឹងវង្សព្រះបាទធតរដ្ឋធិបតី ក្នុងពជនាទីបុរីសិរីអយុធ្យា នឹងបានជា ពំនាក់ត្រៃលោក រម្ងាប់ទុក្ខសោកឲ្យបានសុខគ្រប់ទិសា ព្រះកិត្តិយស ឈ្មោះនាមអ្នកនឹងល្បី ព្ររន្ទឹទូទ័រប្រាកដក្នុងលោកា ទៅទាល់តែអស់ កប្បកល្បហោង ៗ គ្រានោះ រីព្រះនារាយណ៍ឫទ្ធីច្បង បានស្តាប់ព្រះ ឱង្ការព្រះមហាឥសូរ ក៏អភិវន្ទទូលស្នងព្រះវចីថា ដែលទ្រង់ព្រះករុណា

ថាឲ្យបែងភាគចុះទៅបង្រ្កាបពួកពាលបច្ចាមិត្រគតិរីយ៍ ឲ្យរាបដូចផែនដី ឬផ្ទៃស្គរ ក្នុងគ្រានេះឃើញថាកម្រក្រៃក្រ ព្រោះដៀតពួកអសុរចង្រៃនោះ សុទ្ធតែពូកែក្លៀវក្លាហានណាស់ តែខ្ញុំព្រះករុណាម្ចាស់បានបង្រ្កាបប្រាបមកច្រើនដងច្រើនគ្រា ហើយជាសុខរហូតទូទៅទាំងត្រៃចក្រ ឥឡូវនេះ អសុរពួកយក្ស វាក៏មានឫទ្ធាជាវិសេសណាស់ណា តែខ្ញុំម្នាក់ឯងឯកាទីង បង្រ្កាបប្រាបពួកវា កាលណាឡើយនឹងបានសុខឲ្យពង្សវង្សាបច្ចាមិត្របានដោយងាយ ៗ ៗ ការណ៍នេះ ដូច្នេះខ្ញុំព្រះករុណាសូមទាំងជំបងពេជ្រ នឹងចក្រពេជ្រទាំងមហាស័ង្ខទក្ខិណាវដ្តទិងបល្ល័ង្កនាគផង សូមឲ្យទៅកើតព្រមផងរួមវង្សក្សត្រមួយទង្គា ក្នុងនគរព្រះមហាចក្រពត្តិពង្ស ហើយសូមទាំងអង្គព្រះលក្ស្មីជាជនទីនៃលោកជាកំពូលសង្ខារ ហើយទាំងពួកទេវាជាបរិវារផង នឹងបានជួយរំលាងប្រហារជីវិតពួកកុម្ភណ្ឌអសុរី ៗ កាលនោះ ព្រះឥស្សរាធិបតីបានស្តាប់ព្រះនារាយណ៍ឫទ្ធីរង្គទ្រង់ធម៌ ទើបស្តេចពោលពណ៌នាថា យុគនេះ អញបានរិះគិតជិងមកអំពីមុនដើមមក ហើយ នៃនារាយណ៍អើយ ថាត្រៃលោកានឹងបានក្តៅក្រហាយទៅមុខ អញក៏បានចាត់ទុកឲ្យទេពយោធា ទៅកើតរង់ចាំនៅនាគរាខិកខិនបូរីក្នុងត្រកូលក្រុងពាលីទិងធានីជម្ពូតើកជ សុទ្ធតែមានឫទ្ធីអំណាចអានុភាពបេស្តា ហើយមានទាំងប្រើជាឆ្លាតឆ្លៀវវាងវៃ ៗ ណ្ហើយអ្នកកុំភ័យ ចូរចុះទៅចាប់កំណើត កើតក្នុងត្រកូលសូរិយវង្សបក្រោមមហាសាល-

សេដ្ឋា ទ្រង់ព្រះនាមជាព្រះកាមា នៅក្នុងនគរសេរីអយុធ្យាទ្វារាវតី រីចក្រពេជ្រជ័យនោះឲ្យទៅកើតបង្កើតជាព្រះពិរុទ្ធវិទ្ធ ចុះមកលេខ២ ៗ រីស័ង្ខទិន បល្ល័ង្កនាគនោះទៅបង្កើតជាព្រះអនុជ រីដំបងពេជ្រនោះឲ្យទៅកើតជាព្រះសុតទ្រុឌធិបតី រីអង្គព្រះលក្ខ្មី នោះឲ្យកើតក្នុងនគរក្រុងលង្កាទ្វីបនោះ ឈ្មោះហៅថានាងសិតាណុងលក្ខណ៍យៅវមាន ជាបុត្រព្រាណទសក័ក្រ្ដយក្យ ចូរអ្នកទៅឲ្យមានសិរីវង្សនាជាសុខ កុំឲ្យមានរោគព្យាធិឡើយ ហើយក្នុងគ្រានោះ រីឯស់ហ្វូងទេពទេវតូចធំ ទេវខ្លះក៏សុំយកអាសាព្រះភូវនាថជាតិពង្ស នឹងទៅកើតជាពលសេនាទាហាន សម្តេចព្រះពមអវតារ នឹងបានជួយបំផ្លាញ ពួកបច្ចាមិត្រមារអសុរវង្សា ដែលវាមកបៀតបៀនត្រៃលោកា ទើបទេវព្រះពហ្មជ៏មានបុទ្ធីក្លៀវក្លាហាននោះ អញ្ចឲ្យទៅកើតជាទាហានឈ្មោះនិលបានន្ទ ព្រះកីណាយនោះឲ្យទៅកើតជានិលឯក ឯព្រះកិនែកឲ្យមកកើតជានិលខ័ន ព្រះកេតុនោះ ឲ្យទៅកើតជាសេនីយឈ្មោះកុមិតាន់ ព្រះអង្គារជាវិសន្តកវី រីព្រះហិមវ័នោះ ឲ្យទៅកើតជាព្រះកោមុត ព្រះសមុទ្ទនោះឲ្យទៅកើតជានិលពជក្រប័ ព្រះក្ញ៊ុងនោះនៃឲ្យទៅកើតជានិលនន្ទមន្ត្រី ព្រះសៅរ៍ឲ្យទៅកើតជានិលពានក ព្រះសុខនោះ ឲ្យទៅកើតជានិលបាស័ន្ទ-សេនា ព្រះហស្បតិ៍នោះ ឲ្យទៅកើតជាមាលុនកេសរ ព្រះពុធនោះឲ្យទៅកើតជាពានរសុរសេនបុទ្ទី ព្រះចន្ទនោះ ឲ្យទៅកើតជាសត្តពាលី

វិរុឡ្ហក: វិរូបក្ខទាំងពីរត្រកូលនេះ ឲ្យទៅកើតជាកែយូមាយូពានក ។ ពួកទេវតាទាំងពីរទេវតាពានរ ក្រៅអំពីនោះ សុទ្ធតែឲ្យទៅកើតជាពលទាំងអស់ ពប់បញ្ចីឈ្មោះទៅត្រូវ ៧៧ សមុទ្រ ។

កាលនោះ ព្រះឥសូរបមមកុដលោកា ស្ដេចបានស្ដាប់អស់ពួកទេវាទូលថ្វាយបោះហើយ ព្រះអង្គក៏ទ្រង់ព្រះញញឹមអរណាស់ ទើបស្ដេចទ្រង់ត្រាស់ឲ្យពរប្រសិទ្ធអស់ទេពនិករអមររមេឃថា អើបើពួកអស្សុកនឹងកាប់ចាក់ស្លាប់នៅកាលណាក្ដី តែត្រូវព្រះពាយបក់មកខ្ចីត្រូវកាយកាលណាឲ្យរស់រូបាឡើងវិញហោង ។ គ្រានោះអស់ហ្វូងទេវាគ្រប់កសិស្ថាន បានទទួលពរពីព្រះឥសូរហើយ ក៏មានសេចក្ដីត្រេកអរពេកក្រៃ លើកដៃថ្វាយបង្គំក្រាបក្រោមព្រះបាទព្រះអង្គ ហើយសូមបារមីជួយទ្រទ្រង់លើសិរសីខ្ញុំទាំងអស់គ្នាផង ស្រេចហើយហោង អស់ទេពទេវ័ទក៏ក្រាបថ្វាយបង្គំលាហើយក៏ច្យុតចុតិចុះមកបង្កើតជាពានរហោង ។ គ្រានោះ ព្រះបមមកុដកៃលាសបព្វតា លុះពួកទេវាទៅអស់ហើយ ព្រះអង្គទ្រង់ពជទានមន្តវិជ្ជាឲ្យព្រះមហាកាលិយកោដ្ឋឥសីសិទ្ធ ចូរអ្នកទៅតាំងប្រព្រឹត្តកាឡាកិច្ចពិធីទៅទីងបង្កើតជាកងអគ្គីផុះឡើងជាកណ្ដាលពិធីជ័យ ហើយទីងមានអស្សុ-ពទូលថាសរមាស មានបាយទិព្វនៅលើក្បាល ផុះឡើងក្នុងកងភ្លើងនោះ ហើយប្រាកដចំពោះទីងមាន គាកនាស្សូរមកឆាបឆក់យកបាយទៅពុំទានតែថាវាដណ្ដើមបានបាយតែពាក់កណ្ដាលពំនូតទៅទេ តែអ្នកនោះវាក៏

ហើរទៅទិសខាងឯត្បូងទិសា រីបាយនោះណាទឹងបានទៅបង្កើតជានាង
សិតាណុងលក្ខណ៍យៅវិមាន ទឹងបានជាទំពាក្ង ទឹងបានបំផ្លាញពួក
អសុរីដែលបាយនៅសល់បំពាំទូត មួយកំណាត់នោះទឹងទៅបង្កើតជា
ទេសរឿងបុប្ផាទាំង ៤ អង្គ ក្នុងនគរអយុធ្យាជាទីទាំង ៤ នាក់នោះ
សុទ្ធតែមានបុប្ផានុភាពមហិមា ទឹងបានបង្ក្រាបពួកពលពាលាបច្ចាមិត្រ
បត្តត្ថិរយ៍ ។ ទើបអង្គព្រះឥសីកាលិយកោដ្ឋនោះ លុះព្រះឥស្សរពោមោលី
ស្ដេចប្រាប់បង្រៀនមន្តបុទ្ធវិជ្ជាការនោះ ចេះចាំបានស្រេចហើយ ពុំលង់
ឡើយ ក៏បបួលគ្នាតាបសទាំង ៤ អង្គក៏កំបង់លាព្រះឥសូរ ហោះមក
ឯនគរអយុធ្យា លុះបានមកដល់នាមហានិវេសន៍រាជស្ថានភាព ទើប
អង្គព្រះមហាអាចារ្យជាធំនាំគ្នាចូលទៅព្រះរាជពេងជ័យ ។ កាលនោះ
ព្រះបាទធតរដ្ឋរិទ្ធិក្រៃនោះ លុះក្រឡេកឃើញព្រះឥសីទាំង ៤ អង្គនិមន្ត
មកហើយ ព្រះត្រាណត្រើយក៏ថ្វាយបង្គំដោយគ្រេកអរហើយ ក៏សួរ
ថា ព្រះអាចារ្យជាម្ចាស់ ដូចម្ដេចដែលស្ដេចនិមន្តទៅគាល់ព្រះឥសូរធិបតី
សួរសេចក្ដីតាមពាក្យញោមថា នោះតើព្រះអង្គទឹងទ្រង់ព្រះមេត្តាប្រោស
ដូចម្ដេចខ្លះ ។ កាលនោះ រីព្រះឥសីកាលិយកោដ្ឋជាធំនោះ លុះបាន
ស្ដាប់ហើយក៏ថ្វាយព្រះពរថា រីរូបអាត្មានេះ ទៅគាល់ព្រះឥសូរលោកា
បានមានវាចាទូលតាមហេតុគ្រប់ប្រការ ហើយអង្គព្រះឥស្សរលោកក៏
ព្រមទទួលគ្រេកអរក្រៃណាស់ ទើបព្រះអង្គត្រាស់បង្គាប់ប្រាប់ឲ្យព្រះ

នារាយណ៍ បែងភាគចុះមកប្រាកដពិត ហើយព្រះអង្គទ្រង់ឫទ្ធិនោះ ស្ដេចក៏ព្រមទទួលការ ទើបមានវាចាប្រាប់ប្រាយរាយរឿងសេចក្ដីសព្វគ្រប់ ប្រការ ហើយក៏ថាកុំឲ្យព្រះអង្គព្រួយព្រះទ័យ ការអ្វី ៗ អាចក្ដីក៏បាន សម្រេចស្រេចមកហើយ ចូរតាំងតែងចាត់ចែងធ្វើព្រះរាជរោងមណ្ឌបឲ្យ គ្រប់ ១៩ ល្វែង ឲ្យវែងធំទូលាយឧត្តមឧត្តុង្គធ្វើនៅក្នុងទីព្រះលានជ័យមុខ នោះ ចំពោះឲ្យទាន់សុកឫក្សពារពេលាល្អក្នុងនាទីព្រឹកនេះឲ្យទាន់ការ ៗ កាលណោះ ព្រះបាទធតរដ្ឋបេស្ដាស្ដេចស្ដាប់ហើយក៏ត្រេកអរណាស់ក្រៃ ក៏លើកដៃថ្វាយអញ្ជលីវន្ទ័យព្រះអាចារ្យហើយ ពុំលង់ឡើយស្ដេចក៏មាន ព្រះឱង្ការ បង្គាប់ប្រាប់ប្រើទៅសេនីយមន្ត្រីឲ្យសង់រោងរាជពិធីការ ឲ្យបាន ទាន់តាមឫក្សពារពាក្យមហាឥសីហោង ៗ គ្រានោះ ពួកសេនានោះផង ក្រាបរាប់រងទទួលព្រះឱង្ការ ហើយក៏បង្គំលារថយចេញមក តាំង ចាត់រើសរកពួកចាំងពួងក្រសួងមេការ នាំគ្នាធ្វើរោងរាជពិធី ១៩ ល្វែងឲ្យ ខ្ពស់ទូលាយធំវែងស្រឡះ ៤ ជ្រុងស្មើ ហើយក៏ប្រកបទៅដោយនូវគ្រឿង អលង្ការរនាំងរាំងនន ពិតានបិទបាំងជុំវិញ ហើយចងរយោល មាលា ផ្កាកម្រង : ហើយរាជវតិឆត្រទង់ផងចងចិញ្ចែងចិញ្ចាច លាដផ្កាទៀន ធូបនូវសុគន្ធវិលេបន៍ ស្រេចហើយដ៏ល្អដូចវិមានទេពទេវា កណ្ដាល រោងពិធីការនោះក៏ធ្វើជាព្រះវេទនមណីនព្វរត្ន ចងស្វេតច្ឆត្រហើយតាំងនូវ គ្រឿងបូជាគ្រប់គ្រាន់តាមព្រះបង្គាប់ក្នុងរោងពិធីការហោង ៗ គ្រានោះ

ព្រះតាបសទាំង ៤ អង្គស្រេចហើយក៏ទ្រង់គ្រឿងបរិក្ខារពាក់ឆៀងអង្គ ស្រេចហើយក៏នាំគ្នាយាត្រាចូលទៅកាន់ពេទិកដពិធីការ ទើបអង្គព្រះមហាកាលិយគោដ្ឋជាធំនោះ ឲ្យព្រះឥសីទាំង ៤ អង្គនោះអង្គុយនៅ មួយអង្គមួយជ្រុង គ្រប់ជ្រុងទាំង ៤ ហើយព្រះឥសីកាលិយគោដ្ឋជាធំនោះចំពោះអង្គុយនៅកណ្តាល ហើយក៏សង្រួមឥន្ទ្រិយសញ្ញាវិញ្ញាណកាយ ក៏តាំងអុជទៀនធូបនូវគ្រឿងសក្ការបូជាវិសេស ស្រេចហើយក៏នាំគ្នាបរិកម្មការនាមន្ត ដែលព្រះឥសូរប្រទានមកគ្រប់ ៗ គ្នា ៗ លុះតាំងពិធីការទៅបានបីត្រីកាល បណ្តាលព្រះធរណីនោះឮលាន់កង់គគ្រឹកគគ្រេងល្វែងល្វើយ ហើយបង្កើតជាភ្លើងឆេះផុះឡើងភ្លឺរុងរឿងមួយរំពេច ក៏លេចអស្ចារ្យទូលថាសមាសផុះឡើងកណ្តាលក្នុកភ្លើងធំ មានពំទូតបាយទិព្វនោះ ៤ ពំទូតដាក់លើថាសមាស ក្លិននោះក្រអូបពេញពាសឈ្ងុយឈ្ងប់ត្រឡប់ពាំដាវទូទៅគ្រប់ទិសា រហូតដល់នាក្រុងពិជ័យលង្កាទ្វីប ដោយអានុភាពឫទ្ធិបារមីមន្តព្រះឥសូរ ៗ កាលនោះ រីនាងមន្ទោគិរីនោះនៅក្នុងប្រាសាទសោភ័ណ ក៏ក្រអូបក្លិននោះជាប់ក្នុងដួងចិត្តផ្អិតផ្អែត បណ្តាលហេតុឲ្យកើតក្តីរំជួលក្តៅក្រហាយក្រហល់ទើងទប់ទល់តម្កល់អាត្មានោះពុំបានឡើយ ហើយនាងក៏រវើយទូលទៅនឹងព្រះស្វាមីថា ទុសម្តេចព្រះភស្តាស្វាមីម្ចាស់ថ្លៃអើយ ព្រះគុណអើយ សូមទានទ្រង់ព្រះមេត្តាប្រោសខ្ញុំម្ចាស់ ៗ នេះធុំក្លិនក្រអូបរសជាតិអ្វីក៏ខ្លាំងក្រៃ ក៏ចាប់ក្នុងដួងថៃ

នាសាខ្ញុំម្ចាស់នេះណាស់ សល់ធ្ងល់ស៊ុនពេកពិត ស្មើរនឹងក្ស័យជីវិតជីវី ថាបើមិនបានកូនរសជាតិនោះមកបរិភោគអាស្រ័យទេ ឃើញជីវជីវិតខ្ញុំម្ចាស់នឹងដាច់ខ្យល់ដង្ហើមស្លាប់អាសា នាងថាតែម៉្លោះហើយក៏សោកាបម្រះនទៀលទៅវិញទៅមកផ្កាប់ផ្ងារ ។ កាលនោះ វីរក្រុងទេសកក្រ្ពយក្សសោតបានឃើញនាងមណ្ឌាគិរីទេពីសោយសោកា អង្វរថាឲ្យរកកូនរសនោះឲ្យបាន អសុរកក៏អង្អែលបបោសប្រាណថា ប្អូនអើយអ្នកកុំសោយសោកាធ្វើអ្វី កុំភ័យសូមបងជានារកយកមកឲ្យបាន ចូរកែវកំសាន្តសោកា ថាហើយអសុរកក៏ត្រាស់បង្គាប់ប្រាប់ប្រើទៅកាកនាសូរអម្បូរព្រះញាតិ ថាចូរអ្នកខំឃាតហើរហោះផ្ទោះទៅកណ្ដាលអាកាសវេហាស៍ ចូរទៅម្នីម្នា ស្រូបស្រង់កូនក្រអូបផ្អែមនេះរកយកមកឲ្យបាន ហើយអ្នកខំគិតគានធ្យានរក ឲ្យគ្រប់ទិសានុទិស តាំងពួងក្រសួងគ្រប់ប្រក បើបានមកមែនហើយ ពិតសុំអញគិតរង្វាន់ឲ្យពេញចិន្ដា ដោយគាត់នឹងរាជការគុងគ្រានេះហោង ។ កាលនោះ វីនាងកាកនានោះផងបានស្ដាប់ហើយ ពុំលង់ឡើយ នាងក៏ក្រាបបង្គំលា នាងក៏តំណែងកាយា ១ រំពេចវៃនៃកេទយក្សនោះ ក៏បំពោះត្រឡប់កាយក្លាយទៅជាកាកណាសូរធំក្រៃមហិមា ហើយក៏ហើរឡើងលើវេហាស៍ដោយពលាកាយ លឿនស្ទុងស្ទៅ សំដៅទៅតាមផ្លូវអាកាស បែរក្រឡាក្រឡេកភ្នែករំពៃមើលគ្រប់ទ្វីបតូច ធំ ហើយឃើញមានពេជ្រមណ្ឌបក្នុងក្រុងអយុធ្យា

ធំក្លិនខ្ទុជាវសទិព្វ ក្រោយនោះគ្រុឌប្រថាកដច្បាស់ដល់ទៅលើអាកាស ហើយ ពុំលង់ឡើយ កាកនានោះ ក៏មានចិត្តត្រេកអរណាស់ ក៏ហើរចុះហើសត្រង់តម្រង់ពេងពិធយ៉ាងឆាប់ដូចចិត្ត ។ កាលនោះ រីព្រះឥសីសិទ្ធិទាំង ៥ ព្រះអង្គ ទ្រង់បរិកម្មការនាសម្រឹមឥន្ទ្រិយវិញ្ញាណ លុះបានឮសំឡូសម្លេងនោះខ្លាំងក្រៃ ក៏ភ័យភិតតក្កមា ហើយក៏បើកនេត្រាឡើង ក្រឡេកមើលទៅឃើញក្អែកមួយធំមហិមា មានភ្នែកវានោះក្រហមដូចសែងភ្លើង ហើរចុះមកពីអាកាសត្រង់តម្រង់ចុះមកដោយកម្លាំងឫទ្ធិ រីពេងពិធនោះ ក៏បាក់ខ្ទេចខ្ទីទាំងអស់ តាបសទាំង ៥ អង្គនោះ ក៏ស្ទុះក្រោកឡើងម្នីម្នារត់ទៅមកដោយសេចក្តីភ័យភិត ។ គ្រានោះកាកនាសួរនោះ លុះទំលាយពេងពិធបាក់ខ្ទេចខ្ទីអស់ សកុណនោះ លុះក្រឡេកឃើញមានកម្ពុទ្ធមួយនាក់ ទ្រថាសមាសទូលលើក្បាល មានបាយទិព្វនោះ ៤ ពំនូត ហើយនាងអសុរីក៏ស្រូតហើរទៅឆាបឆក់លួចយកបាយទិព្វបានទៅមួយកំណាត់ពំនូត ហើយក៏ហើរទៅហោង លុះបានដល់ស្ថានលង្កាទ្វីប ហើយក៏និម្មិតភេទចេញពីក្អែកទៅជាយក្សវិញ ហើយពុំលង់ឡើយក៏កាន់ពំនូតបាយទិព្វខ្ទុជាវសចូលមកថ្វាយសម្តេចក្រុងទសមុខមារ ។ កាលនោះ រីទសក័ត្រយក្សា អសុរក៏ទទួលយកពំនូតបាយដោយត្រេក-អរ រីបាយទិព្វនោះ ក៏មានក្លិនក្រអូបពិដោរខ្ចរខ្ចាយសាយសព្វហើយក៏ហុចឲ្យទៅនាងមណ្ឌោគិរីជាប្រពន្ធថា ចូរនាងកល្យាណសោយឲ្យសុខ

ហោង ៗ កាលនោះ រីនាងមណ្ឌាគិរីស្នេហ៍ស្នង ក៏ទទួលយកពំនូក
បាយទិព្វនុជារសហើយ នាងក៏បរិភោគត្តាមួយរំពេចវៃ រីឯជារសបាយទិព្វ
មន្ទសិល្បសៃយនោះ ក៏ជ្រួតជ្រាបសព្វគ្រប់ លោមាស្សុទ្ធាភោជនពិស្ថាន
ស្ដូតិ ក៏ទឹងប្រៀបពុំស្មើឡើយ ហើយក៏បង្កើតព្រឹកាយាហើយ ក៏លេច
ពណ៌សម្បុរនោះជ្រះថ្លាថ្លៃរុងរឿងដូចដួងព្រះចន្ទ្រា ៗ កាលនោះ រីឯ
ព្រះមហាធតរដ្ឋធិបតី លុះគម្រប់កំណត់កាត្រី ក៏មានសេចក្ដីត្រេកអរ
ណាស់ ទើបស្ដេចក៏នាំព្រះអគ្គជាយាទាំងបីអង្គទ្រង់ចុះចាកប្រាសាទ
កែវមណី លីលាមកកាន់ពេងភពតិធី ហើយក៏ក្រាបថ្វាយអភិវាទ ជិតព្រះ
បាទា មហាឥសីចក្រក៏ប្រគេនគ្រឿងសក្ការបូជាមាលី ទៅព្រះមុនីឥសី
ហោង ៗ កាលនោះ ព្រះមហាឥសីកាលិយកោដ្ឋតាបសនោះ
លុះឃើញអង្គព្រះបាទធតរដ្ឋមកដូច្នោះហើយក៏មានពុទ្ធដីកាថា រីការ
កិច្ចពិធីឥឡូវនេះ ក៏បានស្រេចសម្រេចដូចក្ដីប្រាថ្នា បង្កើតបានជា
បាយទិព្វដោយឫទ្ធិអានុភាពតបៈតេជៈកិច្ចពិធីកម្ម តែមានកាកនាសូរ
វាហើ មកឆាបឆក់យកបានបាយទិព្វនោះ ១ កំណាត់ពំនូកទៅ ហើយ
ត្រូវទឹងព្រះឧក្ការព្រះចមគិរីលោក មានវាទីថាមកហើយ កាលណាទឹង
ខុស ឥឡូវនេះបាយទិព្វនោះនៅ ៣ ពំនូត មួយកំណាត់នោះនៅល្អ
ថាហើយក៏ហុច ហ៏ប្ចូព្រះអង្គយកបាយមួយពំនូកនេះ ឲ្យទៅនាងកែវ -
សុរិយាយុផាកិន្ទរសាយ ហើយក៏ឲ្យបាយទិព្វនោះ ១ ពំនូត មួយកំណាត់

ក៏ឲ្យទៅនាងសមុទ្ទទៅរសោយទៅហោង ។ កាលនោះ រីនាងទាំង
បីជាអគ្គមហេសី បានទទួលបាយទិព្វសោយទៅ ក៏ជាប់នៅសេក្ខុនក្រយា-
ហារនោះក្រអូបពិដោរផ្អែមល្ហែមពេកក្រៃ ទឹងរកសេអ្វីមក ប្រៀបពុំបាន
ឡើយ ហើយក៏ជ្រួតជ្រាបសព្វអាការកាយព្រៃទាំងលោមាទាំងធាមយង
គ្រប់ទាំងបីអគ្គហោង ។ រីកាល កាះផង ព្រះមហាឥសីទាំង ៥ ព្រះ
អង្គនោះ លុះស្រេចពិធីការកិច្ចហើយ ពុំលង់ឡើយក៏ថ្វាយព្រះពរ
លាមហាក្សត្រថា ចូរទ្រង់ព្រះករុណាស្ដេចគង់នៅឲ្យសុខក្សេមក្សាន្ត
សម្រាន្តសិរីស្រេចហើយ ព្រះឥសីក៏ទ្វីនាំគ្នាលីលាទៅកាន់អាស្រម
កុដិទីទៃរៀងរូបហោង ។ កាលនោះ រីព្រះបាទធតរដ្ឋទ្វីប្បង
លុះបានដូចក្ដីបំណងប្រាថ្នា ព្រះអង្គក៏ទ្រង់មានមនោពិតស្មោះសរគ្រេក-
អរណាស់ ទើបនាំព្រះរាជទេពីទាំង ៣ វិលមកកាន់ប្រាសាទស្ថានវិញ
ហោង ។ គ្រានេះទឹងនិយាយពីព្រះនាគយណ៍រៀងទ្ធលោកា លុះ
ដល់បុកពេលវេលានាទីសុរិត្តមង្គលហើយ ក៏អញ្ជើញទ្វីលាសម្ដេចព្រះ
ឥសូរធិបតី ហើយក៏បបួលនាងលក្ស្មីទោមធាយទាំងព្រះបាទអានន្ទ
នន្ទា មកយើងនឹងនាំគ្នាចុះទៅ គ្រាសហើយអង្គព្រះចមហៅក៏បែង
ភាគបុត្រចុះមក ក្នុងគ្រានោះត្រៃលោកក៏បណ្ដាលកក្រើកអំពើក ញាប់
ញ័រមហាប្រថពី រីព្រះអង្គនាគយណ៍ទ្ធនោះ ក៏មកចាប់បដិសន្ធិក្នុងផ្ទៃ

នៃនាងកែវសុរិយា ។ រីឯចក្រកែវនោះណា ក៏ចូលមកចាប់បដិសន្ធិក្នុងផ្ទៃនាងកែវកេសីទេវី ដំបងពេជ្រមណី និងបល្ល័ង្កនាគនិងស័ង្ខនោះ ក៏មកចាប់បដិសន្ធិក្នុងផ្ទៃនៃនាងសមុទ្រធោមស្រី រីឯព្រះលក្ស្មណ៍នោះក៏ទៅចាប់បដិសន្ធិក្នុងគភ៌នាងមណ្ឌោគិរីហោង ។ ចុះមកជាមួយគ្នាថ្ងៃមួយផងព្រម ១ គ្នា ។ កាលណោះ រីអស់ហ្វូងទេវគ្រប់កសីស្ថាន លុះបានឃើញព្រះនារាយណ៍ធិបតី និងព្រះលក្ស្មណ៍ថ្វៃថ្វាទាំងគទាពេជ្រ ចក្រកែវបល្ល័ង្កនាគ ច្យុតចុតិចាកពីឆ្នេរសមុទ្រធំទៅបង្កើតជាមនុស្សលោកមានឫទ្ធានុភាព នឹងបង្ក្រាបប្រាប់ពួក អសុរៈ ពាលពាលាទីង មរណាដោយឫទ្ធិព្រះចក្រា ម្ល៉ោះហើយក៏នាំគ្នាបាចសាចនៅទិព្វមាលា មន្ទាបុស្ប ចុះមកដេរដាស ហើយក៏ប្រកាសថ្វាយសព្វសាធុការពរ កងរំពងឲ្យជ័យទះដៃអរ ទេវខ្លះក៏ផ្លុំត្រែស័ង្ខលាន់ឮគគ្រឹកគគ្រេងល្វែងល្វើយលើអាកាសេ ទេវខ្លះក៏រាំរបាំច្រៀងលេងសប្បាយទៅវិញទៅមកសព្វកន្លែងហោង ។ កាលនោះ រីនាងនួនល្អងទាំង ៣ អង្គអគ្គរេស្មីហេសី តាំងតែពីថ្ងៃបានសោយបាយទិព្វអាហារវេលាណាហើយ ក៏ជ្រួតជ្រាបសព្វសំឆ្អែតឆ្អន់ដល់ដួងចិត្ត ភ្លេចគិតទាំងសេពសោយ សអាហារមិនឃ្លានសោះឡើយ ហើយក៏នាងសេពសុខសម្រាន្តកាយសប្បាយអង្គ ។ លុះព្រឹកឡើងកាលណា នាងទាំងបីក៏ចម្រើន

សរីរកាយនោះមានឆវីវណ្ណដូចព្រះចន្ទ្រាទ្រង់ក្លស់កណ្ដាលវេហាស៍ នាងទាំងបីអង្គនោះ ក៏ទ្រង់គភ៌ នាងក៏សោយសុខគ្រប់ទិវារាត្រីទាំងបីព្រះអង្គ ៗ មានថ្ងៃមួយ ព្រះបាទចក្រពង្សធតរដ្ឋភូវបាល ស្ដេចចង់យាងទៅក្រសាលប្រពាតពនាល័យ ទើបបបួលរាជទេពីទាំង ៣ នាក់ ថាម្នាលនាងកល្យាណដ៏ចម្រើនអើយ កែវអើយ ចូរនាងទៅប្រពាតពនាល័យលេងនឹងបងមើលអស់រុក្ខជាតិផងនឹងសកុណាសកុណីឲ្យបានក្ដីសុខកំសាន្តចិត្ត ៗ កាលនោះ រីនាងទាំង ៣ អង្គនោះ លុះបានស្ដាប់ព្រះឱង្ការហើយ ក៏នាំគ្នាវន្ទាក្រាបបង្គំទូលតបថា ដែលទ្រង់ព្រះករុណាថានឹងនាំខ្ញុំម្ចាស់ទៅប្រពាតព្រៃព្រឹក្សាទតលេងសប្បាយនោះ ខ្ញុំម្ចាស់សែនត្រេកអរក្រៃ ៗ ស្រេចហើយព្រះចមមកុដក្សត្រមានព្រះឱង្ការហើយ ព្រះអង្គក៏ស្ដេចទ្រង់យាងកាន់ទីបុងព្រះរាជរោងជ័យ ៗ ហើយភូវន័យ ក៏ទ្រង់បង្គាប់ទៅសេនាអាមាត្យមន្ត្រី ឲ្យរៀបរថដំរីយោធាទាហានតូចធំទាំងឡាយ ត្បិតអញនឹងទៅលេងសប្បាយពនាល័យក្នុងវេលាព្រឹកនេះ ៗ ទើបសេនាបតីអស់នោះ ក៏ទទួលព្រះឱង្ការ ហើយក៏ថ្វាយបង្គំលាវរចេញមកតាំងកេណ្ឌយកបណ្ដាពួកពលយោធាតាមក្រសួងបុធអាការ មិម្មារៀបស្រេចក៏រង់ចាំស្ដេចយាត្រា ៗ លុះព្រឹកព្រាងស្វាងព្រះសុរិយាកាលណាហើយ ព្រះត្រាណត្រើយក៏បបួលបីអគ្គមហេសីទៅស្រង់ព្រះវារី

ស្រេចហើយ ក៏ស្តេចទ្រង់គ្រឿងរុងរឿងអាភរណ៍ ចមក្សត្រក៏នាំនាង ទាំង ៣ មកឡើងគង់លើរាជរថកែវសុរ្យកាន្ត ហើយក៏ឲ្យពលទាហាន យោធីលីលាចេញចាកពីនគរហោង ៗ លុះស្តេចគង់យានបានមក ដល់ថ្នល់ព្រៃដុះដាំដួររហាង ៗ ត្រង់ ៗ ដោយទួលទីរាបរាបកឹនព្រៃក្លំជ្រោះ ជ្រលងផង ពនាល័យទីដីខ្សាច់នៅមាត់ជ្រោះនោះ ស្តេចក៏បំពោះបញ្ឈប់ កងទ័ពឈប់នៅទីក្រោមម្លប់ឈើមួយជាទីសប្បាយចិត្ត ហើយក្សត្រក៏ បបួលទាំង ៣ មហេសី ត្រេចយាត្រាទតមើលអស់រុក្ខជាតិបុប្ផាផលទាំង ពួង នៅក្រសួងសត្វបក្សី ម្រឹគី ម្រឹគា តាមពនាល័យជាទីសប្បាយ ក្នុងព្រះទ័យព្រៃព្រឹក្សា ៗ នេះនឹងពណ៌នាពីហេរញ្ញទូតយក្សា នៅ ក្នុងទីហិមវាគីរី មានឫទ្ធិអានុភាពមហិមា ដើរចាប់សត្វគោក្ដាន់រូមនុស្ស ទាំងពួងទាំងឡាយ វាដេញកំចាយស្កាត់ចាប់យកជាអាហារ អសុរី នោះ ក៏មានចិត្តនោះក្រៀវក្លាហាន ឃោរឃៅកាចណាស់សហាវ សហ័សពេកក្រៃ ទោះទេពទេវានៅសួគ៌ត្រៃគ្រប់ៗស្ថាន ក៏វាគ្មានក្រែង ខ្លាចសោះឡើយ ហើយក្នុងដែនព្រៃរោះជារបស់វា តែមានអ្នកណា ហ៊ានចូលមកក្នុងដែននោះមិនបាន តែឮឈ្មោះសម្លេងព្រាណ ក៏សឹង កោតក្រែងខ្លាចអំណាចឫទ្ធាវាហោង ៗ រីទេវានៅស្ថានសួគ៌ ឬ ស្ថាន កណ្ដាលហេតុដល់បាតាល ក៏ពុំហ៊ានទន់វាឡើយ ៗ ហើយថ្ងៃនេះវា

ក៏នឹកចង់ទៅលេងព្រៃមើលនៃពនាវេស  ក៏សំដែងដេតរិទ្ធាពលាកាយ

អសុរារិទ្ធីដៃ ១  ក៏ចាប់ធ្នូសរសិល្បជ័យ  ហើយក៏ហោះឡាន

ទៅដោយឫទ្ធី  លុះបានមកដល់ទីកណ្ដាលព្រៃហិមវន្តកម្ពុទ  ក្រឡេក

មើលឆ្វេងស្ដាំគ្រប់ទិសា  ឃើញហ្វូងគោ មហិង្សាដំរីសេះសិង្ហគជសីហ៍

រមាសខ្លា តាមរីនោះច្រើនណាស់  ទីឯគណនាពុំអស់ឡើយ  ហើយ

អសុរាក៏មានចិត្តនោះត្រេកអរសោទរក្រៃ  ក៏ហោះចុះមកដេញដោយរិទ្ធី

អសុរា ។

ចប់ខ្សែ ៨ ហើយមានខ្សែ ៩ តទៅទៀត

# រឿងសាមកុក

ឧកញ៉ាវិបុលរាជសេនា

នូ-កាន

ប្រែរៀបរៀង

(តមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នករាជវៃឆ្លាសបើបានអាន
នឹងបេះឧបាយកលចំណាន
ទាំងមានសន្តានស្នេហាជាតិ
យូរ—អ៊ុន

ឯប៉ាំងតេក, តាំងហេង, តាំងឈៀវ, សេងហោ មានទាហានទៅជាមួយប្រហែល ៥០០ នាក់ ឈរនៅលើកំពូលភ្នំក្រឡេកឃើញគួនអ៊ូ ក៏មិនបានខ្លាច គួនអ៊ូក៏ឲ្យយកទូកបម្រាំងព័ទ្ធជុំវិញ ហើយបេឲ្យលើកធ្នូបាញ់បម្រុះបួលទៅត្រូវទាហានប៉ាំងតេកស្លាប់អស់ប្រហែល ២ ភាគ ។

ឯតាំងហេង, តាំងឈៀវ លុះឃើញទឹកដល់ទីអាប់ចុនហើយ ក៏និយាយនឹងប៉ាំងតេកថា ទាហានយើងស្លាប់ជាងពាក់កណ្ដាលទៅហើយ សូម្បីផ្លូវប្រកល្ហកក៏រកនឹងរត់ទៅពុំរួច គួរយើងនឹងព្រមចុះចាញ់គួនអ៊ូយកតែជីវិតឲ្យរួចទៅចុះ ប៉ាំងតេកឮដូច្នោះក៏ខឹងណាស់ថា យើងជាខ្ញុំព្រះចៅវុយអង យើងបានឲ្យសេចក្ដីសត្យពិតត្រង់ទុកទៅហើយ ដែលនឹងព្រមចំណុះចុះចាញ់ទៅធ្វើជាខ្ញុំគួនអ៊ូវិញនោះមិនត្រូវសោះ លុះនិយាយដូច្នោះហើយ ក៏ស្ទុះ

ទៅកាប់តាំង-ហេង, តាំងឈៀវស្លាប់នៅទីនោះ ហើយក៏និយាយនឹងទាហានទាំងពួងថា បើនរណាទៅតែនិយាយដូច្នេះ យើងត្រូវធ្វើទោសដូចតាតាំង ២ នាក់ដូច្នោះ ពួកទាហានទាំងអស់ឮហើយក៏ខំប្រឹងចូលទៅច្បាំងនឹងគួន-អ៊ូ មិនបានគោតញញើត តាំងពីពេលព្រឹកទាល់ដល់ថ្ងៃត្រង់ គួន អ៊ូ ក៏ឲ្យទាហានបាញ់ធ្នូនិងចោលដុំថ្ម តម្រង់ទៅបីដូចគ្រាប់ភ្លៀង ។

ឯប៉ាំងតេកនោះ ក៏ឲ្យពលចូលច្បាំងមិនកថយសោះ ហើយនិយាយនឹង សេង-ហោ ថា យើងបានឮគេនិយាយមកពីដើមថា ដែលនឹងឡើងឈ្មោះពេញជាទាហាននោះ លុះតែចូលក្នុងសង្គ្រាមមិនបានគោតញញើតនឹងសត្រូវសោះ មានចិត្តស្មោះស្វាហាប់ធ្វើការចម្បាំងតាំងយកជ័យជំនះឲ្យបានដូចយើងវេលានេះ ក៏អាប់-ចុនស៊ុនខ្លួនទៅក្នុងចំណោមទ័ពគួរឲ្យស្លាប់ហើយ ត្រូវតែមានមានះទាំងអស់គ្នាកុំកថយឡើយ ចូលស៊ូច្បាំងឲ្យទាល់តែស្លាប់ឲ្យហើយទៅចុះ សេង-ហោ ឮដូច្នោះក៏គិតមានះស្ទុះកាន់ដាវចេញទៅមុខ ចូលគ្រលុកតនឹង គួន-អ៊ូ ក៏ត្រូវធ្នូស្លាប់ ។

បណ្ដាទាហានទាំងពួងឃើញ សេង-ហោ ស្លាប់ ក៏ត្រឡប់ចិត្តគិតញញើតទាំងអស់គ្នា បបួលគ្នាទៅចំណុះចុះចូលជាពួក គួន-អ៊ូ ទាំងអស់ ឯ ប៉ាំង-តេក នោះក៏នៅតែម្នាក់ឯង ក្រឡេកឃើញទូកតូច ១ មានមនុស្ស ១០ នាក់ចែវចូលទៅជិត ប៉ាំង-តេក កាន់ដាវមិតរត់ចុះទៅក្នុងទូកបាន

ហើយបង្គំទាហានជើងថែវទាំងនោះឲ្យថែវរត់ទៅ ប៉ាំង-តេក នៅឈរលើទូក ដៃ ១ កាន់ដាវ ហៅបង្គំពួកជើងថែវ ៗ តម្រង់ទៅស្រុក អួន-សៀ ។

ខណៈនោះ ដាវ-ធង ទាហាន គួន-អ៊ូ មានកម្លាំង ចំណានតស៊ូច្បាំងក្នុងក្បួនទូក លុះក្រឡេកឃើញ ប៉ាំង-តេក ឲ្យថែវទូករត់ទៅដូច្នោះ ក៏បង្គំទាហានឲ្យថែវទូកបម្បាំងដេញទៅប្រកៀកលើទូក ប៉ាំង-តេក លិចទៅ ប៉ាំង-តេក ក៏បោះបោលដាវចេញហើយលោតចុះទឹក ហែលទៅ ដាវ-ធង ក៏ព្រួតគ្នាចាប់បាន ហើយចងនាំយកទៅជូន គួន-អ៊ូ ៗ ក៏លើកទ័ពត្រឡប់ចូលបន្ទាយវិញ ទើបឲ្យនាំយកខ្លួន អ៊ុ-គីម ឡើងមកពីក្នុងទូក ហើយសួរថា ហេតុម្តេចបានជាខ្លួនហ៊ានទ្រនង់អង់អាចមកច្បាំងនឹងយើង អ៊ុ-គីម ឆ្លើយថា ខ្ញុំបាទជាខ្ញុំព្រះចៅ វ៉ុយ-អង ១ ត្រាស់ប្រើហើយនឹងទទឹងម្តេចបាន ដែលមកច្បាំងនឹងលោក នោះមានទោសខុសណាស់ទៅហើយ សូមឲ្យលោកអនុគ្រោះលោះលាជីវិតទុកឲ្យទានចុះ ខ្ញុំបាទនឹងសុំនៅធ្វើកដការសឹកតបគុណលោកតទៅ ។

គួន-អ៊ូ ឮដូច្នោះ ក៏អស់សំណើចហើយថា យើងនឹងសម្លាប់ជីវិតខ្លួនចេញ ក៏ពីដូចជាសម្លាប់ក្អែ ១ ប៉ុណ្ណោះ ទើបបង្គាប់ទាហានឲ្យចងខ្លួន អ៊ុ-គីម នាំត្រឡប់ទៅដាក់គុកទុកឯស្រុក កេង-ជីវ ចាំ នឹងស្រេចការណ៍អង្គសង្គ្រាម ហើយបង្គាប់ឲ្យយកខ្លួន ប៉ាំង-តេក ចូលមកទៀតសួរថា ឥឡូវយើងចាប់ខ្លួនឯងបាន តើឯងនឹងគិតប្រការម្តេច? ។

ចាំង-គេក មានសេចក្ដីមានះ ឈរនៅមិនគំនាប់ គួន-អ៊ូ សោះ គួន-អ៊ូ សួរថា ចាំង-ហ៊ុរ បងឯង ហើយនឹង ម៉-ឈៀវ ជានាយចៅ-ហ្វាយតាស់នោះ ក៏ទៅនៅជាខ្ញុំកដការព្រះចៅ ឡៅ-ពី ឯស្រុកសៃ-ឈួន ឥឡូវយើងលើកទ័ពមកបង្ក្រាបសត្រូវ ហេតុម្ដេចខ្លួនឯងទើបមិនស៊ីគ្រ មកនៅនឹងយើង ចាំង-គេក ឆ្លើយថា យើងជាខ្ញុំព្រះចៅ វុយ-អង ១ ប្រើមកឲ្យយើងច្បាំងនឹងខ្លួន ១ ចាប់យើងបានហើយ ត្រូវធ្វើតាមចិត្តចុះ ដែលមកល្បួងឲ្យយើងព្រមចំណុះធ្វើកដការផងនោះ យើងមិនត្រូវការទេ ព្រោះយើងដឹងថា ព្រះចៅ វុយ-អង មានព្រះគុណជាទម្ងន់ណាស់ យើងស៊ូស្លាប់តែនឹងមុខដាវមុខលំពែង ហើយមិនបានជាអាល័យស្ដាយរូបកាយនេះប៉ុន្មានទេ ហើយក៏និយាយទ្រគោះអស្រុកេះជេរប្រមាថ គួន-អ៊ូ ជាច្រើន គួន-អ៊ូ ខឹងណាស់ ក៏បង្គាប់ឲ្យទាហាននាំខ្លួន ចាំង-គេក ទៅប្រហារជីវិត ហើយក៏ត្រឡប់គិតអាណិតអនាថពន់ប្រមាណ បានឲ្យយកសពទៅកប់តាមប្រវេណី ។

ឯចៅ យ៉ិន នៅក្នុងស្រុក អួន-សៀ នោះ លុះឃើញទឹកជំនន់ឡើងច្រើន ក៏បង្គុំឲ្យទាហាននិងបណ្ដាអ្នកស្រុកបិទផ្ទះព្រែកទាំងអស់ ទឹកនោះក៏ហូរបាក់ធ្លាយរលាយទំនប់ចូលទៅក្នុងស្រុកបាន ប្រជាជនក្នុងក្រុមឋានក៏បានសេចក្ដីលំបាកច្រើនណាស់ ចៅ យ៉ិន និយាយនឹងទាហានទាំងពួងថា គ្រានេះមុខជាយើងនឹងមានអន្តរាយជាប្រាកដហើយ ព្រោះ

ទឹកឡើងច្រើនណាស់ មនុស្សទាំងពួងបានសេចក្ដីលំបាកវេទនា បើសត្រូវចូលមកពាលាក៏គង់ពុំឈ្នះ គួរយើងនឹងលះបង់ចោលស្រុកនេះវេះរត់ទៅរក្សាអាយុជីវិតសិនចុះ ទើបបង្គាប់ឲ្យប្រុងប្រៀបរៀបទូកនឹងធ្វើរត់ទៅ ។

ខណៈនោះ ប៊ួ ចុង ទំប្រឹក្សាហាមឃាត់ចៅ យ៉េន ថា ដែលនឹងលះបង់ចោលស្រុក អ៊ួន-សៀ មិនគួរសោះ ព្រោះនៅតែ ២.៣ ថ្ងៃទៀតនឹងលើកទ័ពមកច្បាំងក្នុងគ្រានេះ ក៏ឃើញថាមុខជាមិនមកទេ មុខជានឹងឲ្យតែទាហានទៅទាំងទ័ពនៅ កៀប-ហៃ ដែលជាផ្លូវនឹងចូលមកក្នុងស្រុក អ៊ួន-សៀ ព្រោះខ្លាចពួកយើងនឹងលើកទៅលុកពីក្រោយ ឯស្រុក អ៊ួន-សៀនេះ ជាបន្ទាយមាំជាងអាណាខេត្តទិសខាងត្បូងទាំងអស់ បើចោលស្រុក អ៊ួន-សៀ បង់ហើយ ស្រុក ទៀង-អាន់ ក៏នឹងរលាយទៅ ។

ចៅ យ៉េន ឆ្លើយតបនឹង ប៊ួន-ចុង ថា អ្នកឯងនិយាយនេះ យើងក៏យល់ឃើញផងដែរ បើប្រសិនជាអ្នកមិនបានឃាត់ខាំងយើងមុខជាខូចការពជការទៅទេឥតប្រយោជន៍ និយាយហើយក៏ឡើងជិះសេះសមរទៅបញ្ជរ ពីសើនបន្ទាយ ហើយស្រែកប្រកាសប្រាប់ទាហានទាំងពួងថា គ្រានេះ យើងកាន់ព្រះតម្រាស់ព្រះចៅ វុយ-អង មក បើនរណាធ្វើរាជការកោតញញើតចេញពាក្យថា នឹងបោលស្រុក អ៊ួន-សៀ ទៀត យើងនឹងកាត់ក្បាលអ្នកនោះចេញ ទាហានទាំងពួងក៏ស្រែកឡើងព្រម

គ្នាថា យើងខ្ញុំសុំក្បាស្រុកនេះទុកត្រាតែអស់ជីវិត ៈហ យិនព្រុជូហ្នោះ ក៏ពេញចិត្តណាស់ ទើបប្រុងប្រៀបរៀបទាហានឲ្យមានគ្រឿងសស្ត្រាវុធ និងធ្នូស្នា ត្រួតត្រាឲ្យព្រមទាំងយប់ទាំងថ្ងៃ លុះរំលងមក ២-៣ ថ្ងៃ ទឹក ក៏ស្រកចុះទៅអស់ ឯគួន-អ៊ី កាលមានជ័យជំនះ ក៏ល្បីព្រុទ្ធីកេរ្តិ៍ឈ្មោះ ទូទៅដល់មនុស្សទាំងពួងលើសជាងពីដើម ។

ឯគួនហ៊ុនជាបុត្រទី ២ នៃគួនអ៊ី ដែលនៅស្រុកកេងជ័រ ក៏លើកពល មកសួរ បិតា គួនអ៊ី ក៏ប្រើគួនហ៊ុនឲ្យកាន់សំបុត្រ ១ ច្បាប់ទៅក្រាបទូល ព្រះចៅហានតុង ឯស្រុកសេងគោថា ឥឡូវគួនអ៊ីទូលបង្គំយកបាន ស្រុកសុងយ៉ុងហើយ ចាប់បានទាំងខ្លួនអ៊ុគិនបញ្ជូនទៅស្រុកកេងជ័រ ឯ ប៉ាំងគេកនោះ ទូលបង្គំក៏ចាប់បានសម្លាប់ចោលទៅហើយ បណ្តាទាហាន ដែលមានខ្លួនទៅធ្វើការសង្គ្រាមគ្រានេះ ក៏មានសេចក្តីគាប់ប្រសើរ ជាច្រើនណាស់ គួនហ៊ុនទទួលយកសំបុត្រនោះហើយ ក៏លាបិតា ចេញទៅស្រុកសេងគោ ៗ

ខណៈនោះគួនអ៊ី ក៏បែងទាហានទៅតាំងនៅទីតម្បន់កៀបហៃ ដ៏ជា ផ្លូវដែលចូលទៅក្នុងស្រុកអ៊ួនសៀ ហើយក៏លើកទាហានចូលទៅនឹងវាយ ទំលាយយកស្រុកអ៊ួនសៀ គួនអ៊ីជិះសេះបញ្ឈរនៅត្រង់ទ្វារទិសឯជើង ហើយយកខ្សែបន្តុលមុខ ហៅយិនស្រែកថា អាពួកជ្រូកហេតុម្តេចឯងទើប

មិននាំគ្នាចេញមកស្នំគ្រព្រមចំណុះ ចុះចូលអញ ទឹងបង្អង់ចាំដល់កាលណាទៅទៀត ។

ហោយិននៅឈរលើសើន ក្រឡេកឃើញគួនអ៊ូ ពាក់អាវមានតែក្រោះបិទទ្រូងមកឈរនៅដូច្នោះ ក៏ឲ្យទាហាន ៥០០ នាក់យកធ្នូបាញ់ ចម្រុះចុះមក គួនអ៊ូគេចរតមិនទាន់ព្រួញ ធ្នូក៏លឿនទៅត្រូវចុងស្មាខាងឆ្វេងធ្លាក់ពីលើខ្នងសេះ ហោយិនក្រឡេកឃើញគួនអ៊ូត្រូវព្រួញធ្លាក់ពីលើសេះដូច្នោះ ក៏ឲ្យទាហានលើកចេញច្បាំង ។

ឯគួនបេងជាបុត្រ ក៏ឲ្យទាហានចូលច្បាំងនឹងទាហានហោយិន ។ ក៏ថយត្រឡប់ទៅវិញចូលស្រុក គួនបេងក៏នាំយកបិតាវិលទៅបន្ទាយ ហើយឲ្យមនុស្ស ទាញកន្ត្រាក់ដកយកព្រួញចេញបាន ឯព្រួញនោះលាបចុងដោយថ្នាំពិស ជ្រាបចូលទៅដល់ឆ្អឹងមានពិសពេកចាប់ជាខ្លាំងណាស់ គួនអ៊ូទឹងកំរើកខ្លួនស្ទើរពុំបាន គួនបេងនិងទាហានទាំងពួងឃើញថាគួនអ៊ូឈឺខ្លាំងដូច្នោះ ក៏នាំគ្នាចូលទៅនិយាយនឹងគួនអ៊ូថា ឥឡូវនេះលោកក៏មានរបួសឈឺ ដែលនឹងធ្វើការតទៅនោះ ឃើញថាលោកបានសេចក្តីលំបាកណាស់ ខ្ញុំបាទប្រឹក្សាព្រមគ្នានឹងសុំលើកទ័ពត្រឡប់ទៅស្រុកកេងជីវ រក្សារបួសលោកឲ្យសះជាសិនសឹមធ្វើការតទៅ ។

គួនអ៊ូបានឮក៏មានសេចក្តីខឹងខ្លាំងណាស់ថា យើងនឹងខ្លាចអ្វីដល់សេចក្តីឈឺចាប់បន្តិចបន្តួចប៉ុណ្ណោះ យើងនឹងវាយយកស្រុកអួនសៀឲ្យ

បាន ហើយនឹងលើកទៅវាយយកស្រុកហ្វ៊ីតោទៀត ដើម្បីកំចាត់ចូច ចេញឲ្យព្រះចៅហៀនគេបានសេចក្ដីសុខ ចៅកុំថាដូច្នេះតទៅទៀត ឡើយ អស់អាណាប្រជាជនទាំងពួងក៏នឹងបានសេចក្ដីតូចចិត្ត គួនបេង និងទាហានទាំងពួងបានឮគួនអ៊ូថា ក៏មិនអាចនឹងទាស់ទែងបាន ទាំង អស់គ្នាក៏លាថយមក ក្នុងថ្ងៃនោះស្រាប់តែពេទ្យហ្វ៊ីតោជាគ្រូឯក ក្នុង ស្រុកចៅកុនមកដល់បន្ទាយ ទាហានទាំងពួងក៏ទៅប្រាប់គួនបេង ៗ ក៏ ឲ្យអញ្ជើញពេទ្យហ្វ៊ីតោចូលទៅ ៗ ពេទ្យហ្វ៊ីតោសួរថា ខ្ញុំបានឮថាបិតា អ្នកត្រូវព្រួញរបួសធ្ងន់ បានជាខ្ញុំស្ទុះស្ទែងមក នឹងជួយព្យាបាលរក្សា គួន-បេងថា កាលគ្រារក្សារបួសជីវថាយ ក្នុងស្រុកកាំងតាំងនោះ គឺលោក នេះឯងឬ ? ពេទ្យហ្វ៊ីតោឆ្លើយថា គឺខ្ញុំនេះឯងហើយ គួនបេងឮដូច្នោះក៏ មានអំណរណាស់ ទើបឲ្យទាហាននាំពេទ្យហ្វ៊ីតោចូលទៅក្នុងបន្ទាយ ៗ

ឯគួនអ៊ូបានសេចក្ដីឈឺចាប់ជាខ្លាំងណាស់ តែគិតក្រែងទាហាន ទាំងពួងដឹងនឹងនាំឲ្យខូចចិត្តគំនិត បានជាខំឧស្សាហ៍អត់ទ្រាំធ្វើជាថែប សប្បាយ ហើយហៅម៉ាលៀង ចូលលេងបាសកាប្រាថ្នានឹងឲ្យទាហាន ទាំងពួងមានចិត្តស្រើបស្រាល ស្រាប់តែឃើញពេទ្យហ្វ៊ីតោចូលទៅដល់ ក៏អញ្ជើញឲ្យពិសាតែ ហើយឲ្យពិចារណាមើលរបួសខ្លួន ពេទ្យហ្វ៊ីតោ ថា របួសព្រួញនេះលាបដោយថ្នាំពិសជ្រាបចូលទៅក្នុងឆ្អឹង បើមិនខំ

ប្រឹងមើលឲ្យដាច់ យូរទៅនឹងខូចស្មារតីនោះអសារ ៗ គួនអ៊ីសួរថា លោកនឹងប្រកបថ្នាំមើលបានទេ ? ពេទ្យហ៊ូគោថា ខ្ញុំនឹងមើលជូនបាន តែខ្លាចលោកអត់ធន់ពុំបាន គួនអ៊ីថា លោកត្រូវនឹងធ្វើម្ដេចក៏ធ្វើចុះ ហ៊ូគោថា ខ្ញុំបានឲ្យយក (ល្បោស) រុំលោកជាប់នឹងសសរមិនឲ្យកម្រើកខ្លួនបាន ៗ

គួនអ៊ីអស់សំណើចហើយថា ខ្ញុំមិនខ្លាចទេ កុំបាច់យក(ល្បោស)រុំឡើយ លោកនឹងធ្វើយ៉ាងម្ដេចក៏តាមតែធ្វើទៅចុះ ខ្ញុំនៅស្ងៀមឲ្យធ្វើ ទើបបបួលហ៊ូគោផឹកស្រា លុះស្រវឹងហើយក៏ហៅម៉ាលៀងឲ្យចូលមកលេងបាសកា ហើយក៏ផ្ទៀងស្មាម្ខាងឲ្យហ៊ូគោ ៗ ក៏យកកាំបិតមុតវះសាច់អាក្រក់ចេញអស់ហើយ ក៏យកថ្នាំលាបហើយទើបយក(ម្ជុលមក) ដេររុំទុកមនុស្សទាំងពួងឃើញដូច្នោះ ស្ញើរនឹងមិនហ៊ានមើល គួនអ៊ីក៏ក្រោកឡើងស្រែកថា យើងមិនមានឈឺទេ ជាអស់ហើយៗសរសើរថា ពេទ្យនេះវិសេសណាស់ បីដូចជាទេវតាក៏ថាបាន ហ៊ូគោថាតាំងពីខ្ញុំបានរេះមើលរបួស ជម្ងឺមនុស្សក៏ច្រើនណាស់មកហើយ មិនមាននរណាដូចលោកនេះទេ ឯលោកនេះចិត្តជាអ្នកពូកែអត់ធន់ព្រោះជម្ងឺមិនគក់ស្លុតរន្ធត់ខ្លាចភ័យសោះល្អណាស់ ៗ

ឯគួនអ៊ីនោះ លុះសះជាជម្ងឺរបួសនោះហើយ ក៏អរណាស់ ទើបឲ្យលើកតុអាហារទឹងស្រាបាយមកឲ្យហ៊ូគោបរិភោគតាមសប្បាយ ហ៊ូគោ

ក៏និយាយនឹងគួនអ៊ូថា របួសនេះទើបនឹងសះជា លោកត្រូវរម្ងាប់សេចក្តីកំហឹងត្រាតែគ្រប់ ១០០ ថ្ងៃ ទើបពិសព្រួញនោះនឹងជាអស់ស្និទ្ធ គួនអ៊ូក៏ទទួលពាក្យ និងមានអំណរគុណអរគុណហ៊ួតោច្រើនណាស់ ទើបយកមាសទម្ងន់ ៣ ដញ្ជឹង ១០ បាត ឲ្យហ៊ួតោជាបំណាច់រង្វាន់ ហ៊ួតោថាដែលខ្ញុំបាទបានមកព្យាបាលជម្ងឺ របួសលោកទាំងនេះ នឹងបានតាំងចិត្តប្រាថ្នាដោយរង្វាន់បំណាច់នោះក៏ទេ ខ្ញុំបានឃើញលោកនេះប្រកបដោយសេចក្តីស័ត្យពិតត្រង់ បានជាមកជួយព្យាបាល ដើម្បីមិនឲ្យមានអន្តរាយ ដែលលោកនឹងឲ្យទានបំណាច់រង្វាន់មកខ្ញុំបាទ ៗ មិនយកទេ សូមបង្វិលទុកជូនលោកវិញ ថាតែប៉ុណ្ណោះហើយក៏យកថ្នាំលាបរបួសម្តងទៀត ហើយក៏លាចេញទៅ ។

---

(នៅមានត)

# ឯកសារ សាស្ត្រាស្លឹករឹតនិងក្រាំង

*ដែលមាននៅវិជ្ជាស្ថាននៃពុទ្ធសាសនបណ្ឌិត្យ*

លោក ញ៉ុក-ថែម រៀបរៀង

( តពីលេខ ១២ ឆ្នាំ ១៩៦៦ )

ចំណងជើង  *“សាស្ត្រា និគ្រោធអម្រឹក(១)”*

អ្នកនិពន្ធ  *រកពុំទាន់ឃើញ ។*

កាលបរិច្ឆេទ  *គ្មានបញ្ជាក់ក្នុងអត្ថបទ ។*

របៀបនិពន្ធ  *ពាក្យកាយ : លំនាំទេសនា ។*

ប្រភពរឿង  *អត្ថបទជាតក ពុទ្ធនិយម ។*

លក្ខណៈឯកសារ  *សាស្ត្រាស្លឹករឹត ៣ ខ្សែ ។ ខ្សែទី ១ មាន ១១ សន្លឹក ខ្សែ ២ មាន ១៣ សន្លឹក ខ្សែទី ៣ មាន ៨ សន្លឹក ។ ឯកសារនេះ ពុទ្ធសាសនបណ្ឌិត្យបានមកអំពីវត្តផ្លិកជ្រុំ ខេត្តកំពង់ស្ពឺ ចុះលេខ ១០៥២ ។*

---

(១) នេះជារឿងជាតក ១ ខាងផ្នែកបលនាអក្សរសាស្ត្រពុទ្ធនិយម ប៉ុន្តែអ្នកនិពន្ធមិនបានបញ្ជាក់ថា ខ្លួនបានដកស្រង់ ឬ ប្រែសម្រួលអំពីនិបាតជាតកណាទេ ទាំងកាលបរិច្ឆេទ ក៏គ្មានបញ្ជាក់ដែរ ។ ប៉ុន្តែក្នុងការចាំនិងនឹកឃើញថា រឿងជាតកនេះ មានក្នុងជាតកជាភាសាបាលីដែរ គ្រាន់តែឈ្មោះតួ ខុសខ្លះ ស្របគ្នាខ្លះប៉ុណ្ណោះ ។ ឧទាហរណ៍ តួអង្គ នាងហេមា បុត្រីមហាសេដ្ឋី និងចៅកុលាបុត្រ មហាសេដ្ឋី ។ ឯក្នុងជាតកបាលី តួអង្គស្រីឈ្មោះនាង ខេមា ។ ឯតួអង្គប្រុសគ្មានឈ្មោះទេ ។ ឯតួអង្គក្នុងអតីតជាតិ មានឈ្មោះស្របគ្នា ធ្វីបនិគ្រោធម្រឹគ សាខម្រឹគ ជាដើម ។ ( កន្លែងខ្លះដាក់ថា សាគរម្រឹគក៏មាន ប្លែកពីអត្ថបទបាលី) ។

អត្ថបទផ្ដើម នមោតស្ស ។ តទាការេ ជេតវនេ វិហរន្តោ ការេត្ត កថេសិ ។ សត្ថា រីព្រះដ៏មានបុណ្យ សត្ថវាហោ សត្ថនាយ-កោ រីព្រះដ៏ជានាយក តែងនឹងកៀរគរប្រមូលបញ្ចូល អស់ឥន្ទ្រព្រហ្មទេវតា មនុស្សសត្វផងទាំងឡាយ ដាក់ដល់ត្រើយថ្នល់ អម្រឹតបុរីស្រីមហានគរនិព្វាន គឺគង់ជាឋាន បរមសុខប្រសើរនោះទៀងប្រាកដហោង ។ . . . ។ល។ . .

អត្ថបទបញ្ចប់ ភិក្ខវេ ម្នាលភិក្ខុផងទាំងឡាយអើយ នាកាលតថា-គតយកជាតិជាស្ដេចនិគ្រោធអម្រឹគ នៅនាឧទ្យាន ទូន្មានប្រដៅ ស្ដេចព្រះបាទព្រហ្មទត្ត បានលុះដំបូន្មាននោះ ទើបហៅជាអស្ចារ្យក្រៃពេកហោង ។ រីព្រះបាទព្រហ្មទត្ត គិតដ៏បេរវិលវិញមក បានជាមហាអានន្ទត្ថេរ ។ រីឯសាគរអម្រឹគ គិតបេរវិលវិញមក បានជាទេវទត្តត្ថេរ ។ រីឯមេព្រាយ គិតដ៏បេរវិលវិញមក បានជានាងហេមភិក្ខុនី ។ រីឯកូនព្រាយនោះ គិតដ៏បេរវិលវិញមក បានជាមហាកស្សបត្ថេរ ។ រីឯស្ដេចនិគ្រោធអម្រឹគនោះមិញ គឺអង្គអញតថាគតនេះហោង ។

ភគវា រីព្រះដ៏មានបុណ្យ ព្រះអង្គសំដែងថ្លែង និទានអំពីដំណើរស្ដេចនិគ្រោធអម្រឹគនោះមិញ ។ និដ្ឋិតា ស្រេចនូវប្រការអម្បាលណោះហោង ។

បំណងជើង „សាស្ត្រា ទុគ្គតបុរស(១)„

អ្នកនិពន្ធ រកពុំទាន់ឃើញ ។

កាលបរិច្ឆេទ គ្មានបញ្ជាក់ ក្នុងអត្ថបទ ។

របៀបនិពន្ធន៍ ពាក្យរាយ , លំនាំទេសនា

ប្រភេទរឿង ប្រហែលស្រង់ប្រែសំរួលពីគម្ពីរធម្មបទដ្ឋកថា ។

លក្ខណៈឯកសារ សាស្ត្រាស្លឹករឹតមាន ២ ខ្សែចប់ ។ ខ្សែទី ១ មាន ១៣ សន្លឹក ខ្សែទី ២ មាន ១៣ សន្លឹក ។ ឯកសារនេះ ពុទ្ធសាសនបណ្ឌិត្យ . បានមកអំពីវត្ត សុវណ្ណរង្សី ខេត្តកំពង់ចាម ចុះលេខ ១០៣៧ ។

អត្ថបទផ្ដើម នមោតស្ស ។ ឧទកំ ហិ នយន្តិ ឥមំ ធម្មទេសនំ សត្ថា ជេតវនេ វិហរន្តោ បណ្ឌិតសាមណេរំ អារព្ភ កថេសិ ។ សត្ថា រីអង្គសម្ដេចព្រះបរមពិជិតមារ ជាគ្រូដ៏ប្រសើរ នៃយើងទាំងឡាយ ។ វិហរន្តោ កាលស្ដេចសម្រាកសម្រាន្តកំសាន្តព្រះកាយគង់នៅ ។ ជេតវនេ ក្នុងព្រះជេតពន សុគន្ធកុដី ស្រីមហាវិហារ ។ អារព្ភ មោះ ទើបព្រះអង្គទ្រង់ប្រារព្ធ

(១) រឿងទុគ្គតបុរសនេះ អ្នកនិពន្ធចង់បង្ហាញផល នៃការកសាងទាន ក្នុងពុទ្ធសាសនា អាចផ្ដល់វិបាកអស្ចារ្យជាក់ស្ដែង ក្នុងបច្ចុប្បន្នកាល ដូចទុគ្គតបុរសក្នុងនិទាននេះជាឧទាហរណ៍។

បំពោះហើយ ។ បណ្ឌិតសាមណេរ នូវបណ្ឌិតសាមណេរ ។ កថេសិ ទើបព្រះអង្គទ្រង់ត្រាស់សំដែងព្រះធម៌ . . ។ល។ .

អត្ថបទបញ្ចប់ សោ សេដ្ឋី រីឯទុគ្គតមហាសេដ្ឋីនោះ សង់ផ្ទះរួចស្រេចហើយ ក៏គាត់ធ្វើនូវទានធំ និមន្តនូវព្រះភិក្ខុសង្ឃ មានព្រះពុទ្ធអង្គជាដើម ជាប្រធានធាន់អស់ ៧ ថ្ងៃ ។ អណ្តាប់អំពីនោះ គាត់ក៏ធ្វើបុណ្យទាំងឡាយ ពុំដែលមានដាច់មួយវេលាឡើយ ដរាបដល់គាត់អស់អាយុអំពីលោកនេះទៅហើយ បានទៅកើតនាឋានទេវលោក សោយតែសម្បត្តិទិព្វ ។ ឯកំ ពុទ្ធនំ អស់ពុទ្ធន្ត ១ ហោង ។

បពិត្រអើយ អាត្មាភាពសំដែងកង់រឿងនិទាននេះ ពុំទាន់បានជាអស់សេចក្តីនៅឡើយ គ្រាន់តែជាហេតុបន្តិច គ្រាន់ជាសណ្តាប់អស់បពិត្រទាំងពួង និងបានឲ្យជាវិត្ថារពិស្តារឆ្ងាយទូលាយទៅនោះពុំបានឡើយ។ ឯរំ ចប់សូវេចនូវប្រការទាំងអម្បាលណោះឯងហោង។

X X X

បំណាងជើង „ សាស្ត្រា ព្រះស្រីអារ្យមេត្រី (១) „

អ្នកនិពន្ធ រកពុំទាន់ឃើញ ។

កាលបរិច្ឆេទ គ្មានបញ្ជាក់ក្នុងអត្ថបទ ។

(១) — ប្រភពនៃអត្ថបទ ប្រហែលកើតឡើងនៅវត្តវៃ ស្រុកបារាយ (កំពង់ធំ) ឬមួយនៅបារាយទឹកថ្លា (សៀមរាប)

**របៀបនិពន្ធ** ពាក្យរាយ : លំនាំទេសនា ។

**ប្រភពរឿង** ថ្លែងពីប្រវត្តិព្រះពោធិសត្វ ព្រះស្រីអារ្យមេត្រី

( ប្រហែលគេទើបនិពន្ធឡើងក្នុងស្រុកខ្មែរ? )

**លក្ខណៈឯកសារ** សាស្ត្រាស្លឹករឹត១ខ្សែ មាន៣៦សន្លឹក ។ ឯកសារនេះ ពុទ្ធសាសនបណ្ឌិត្យបានមកអំពីវត្តខ្ចៅ ខេត្តកំពង់ឆ្នាំង ចុះលេខ ១០៣៦ ។

**អត្ថបទផ្ដើម** នមោ តស្ស ។ . . . . . .(១) ។

សោ ភគវា ។ បពិត្រអើយ អាត្មាភាពចម្រើនពរបវរ សិរីសួស្ដី ពិភពមង្គល ជន្មាយុយឺនយូរជាសុខគ្រប់ប្រការ ចូរមានដល់បច្ចយទានាធិបតី ជាអ្នកមានសទ្ធា មានចេតនាជ្រះថ្លាដើម្បីនឹងស្ដាប់ព្រះធម៌ទេសនា បបួលគ្នាមកកាន់រោងធម្មសភាសាលា ក្នុងពេលថ្ងៃនេះ មានចិត្តប្រកបដោយសទ្ធាជាកាមាវចរកុសល ប្រកបដោយសោមនស្សសម្បយុត្ត គឺសភាពជឿចូលចិត្ត ក្នុងព្រះពុទ្ធសាសនា ថាអាត្មាអញនឹងធ្វើការកុសលសីលទាន ជាការសុចរិត . . ។ល។ . .

**អត្ថបទបញ្ចប់** សាធវោ បពិត្រសប្បុរសជនទាំងពួងអើយ ចូរប្រុងសតិ

(១) – អត្ថបទបាលី មានវិបត្តិច្រើនណាស់ មើលមិនយល់ជាអ្វី ? ប្រហែលជាអ្នកចារចំឡង មិនចេះបាលីសោះ ម្ល៉ោះហើយចេះតែចារដាក់តាមតែស្មានៗទៅ ?

ស្មារតីឲ្យខ្ជាប់ ស្តាប់រឿងនិទាន មានមកដូច្នេះ ចូរខំទស្សាហ៍ ពីព្យាយាមធ្វើបុណ្យឲ្យបាន ចម្រើនមេត្តាតាវនា នូវវិបស្សនា-កម្មដ្ឋាន ឈានសមាបត្តិ កំចាត់អកុសលគម្ពល់បុណ្យ កាលបើរលាន់ខន្ធទៅ នឹងបានកពប្រសព្វ នឹងលោកអ្នកមានបុណ្យបារមី សេចក្តីសុខសេចក្តីចម្រើនរឿងរូចដល់បាននិព្វាន ជាឋានបរមសុខប្រសើរនោះទៀតប្រាកដហោង ។

បពិត្រអើយ អាត្មាភាពសំដែងថ្លែងគម្ពីរព្រះស្រីអារ្យមេត្រីនេះមិញ ។ ឯរំ កំចប់សូរេចនូវប្រការអម្បាលណោះឯងហោង ។

X X X

បំណងជើង « សាស្ត្រា ព្រះសុគតព្រះចមក្សារ (១) »

អ្នកនិពន្ធ ព្រះបាទចមក្សារ រដ្ឋកាលទី ៤ ពជជាទីបាន៍កក (ប្រទេស ថៃឡង់ )

កាលបរិច្ឆេទ ប្រហែលក្នុងសតវត្សរ៍ទី១៨ ។

របៀបនិពន្ធ ពាក្យពយ អត្ថបទបកប្រែពីគម្ពីរបាលី ។

ប្រភពរឿង ថ្លែងអំពីគោលលទ្ធិពុទ្ធនិយម ។

(១) — ឯកសារនេះ ថ្លែងអំពីគោលទស្សនៈផ្សេង ៗ ក្នុងពុទ្ធសាសនា មានព្រះត្រៃលក្ខណ៍ជាដើម ។ ទស្សនៈខាងការដោះស្រាយបញ្ហានៃជីវិតសត្វលោក តាមគន្លងពុទ្ធសាសនាបៀសវាងការប្រព្រឹត្តអាក្រក់ផ្សេងៗដោយកាយ វាចាចិត្ត នឹងការធ្វើកាយវាចាចិត្តឲ្យស្អាតស្អំបរិសុទ្ធកុំឲ្យអកុសលមូលមាន តណ្ហា រាគៈ លោភៈ ជាដើម ចូលមកយាយីញាំញីដល់ផ្លូវចិត្តបាន ។

លក្ខណៈឯកសារ សាស្ត្រាស្លឹករឹត១ខ្សែមាន២៣សន្លឹក ៗ ឯកសារនេះពុទ្ធសាសនបណ្ឌិត្យបានមកអំពីវត្តសំពេងសែន ខេត្តកំពង់ឆ្នាំង បុះលេខ ១០៣៥ ៗ

អត្ថបទផ្ដើម អហោ អនិច្ចា សង្ខារា ឱសង្ខារទាំងឡាយអើយ មិនទៀងសោះឡើយ ៗ គេកាលិកា អសណ្ឋិតា ប្រកបក្នុងកាលទាំងបី មិនឋិតនៅបាន ៗ សកាលាកា លិកាសព្វេសង្ខារទាំងឡាយទាំងពួង ប្រព្រឹត្តទៅក្នុងកាលមួយ ប្រកបដោយកាលមួយ ៗ ហុត្វា ហុត្វា ន ហោន្តិ គេសង្ខារទាំងឡាយមានហើយ ក៏ប្រែជាគ្មានទៅវិញ ៗ តតុដេតលក្ខណោ ព្ទោ សង្ខារដែលទៀងនោះ និងមានមកពីណា ៗ យទុប្បន្នំ ននស្សតិ សង្ខារដែលកើតឡើងហើយ មិនវិនាសទៅគ្មាន ៗ . . . . . . . ៗល ៗ

អត្ថបទបញ្ចប់ សព្វោមេ សង្ឃោ ខមាតុ សូមព្រះសង្ឃអត់ទោសទាំងពួងដល់ខ្ញុំ ៗ អាតុរស្មិម្បិមេ កាយេ នាកាលកាយយើងរសាប់រសល់ ៗ ចិត្តំ នមោ សតា តុរំ ចិត្តខ្ញុំមិនរសាប់រសល់ ៗ ឯវំ សិក្ខាមិខ្ញុំទីងសិក្សាយ៉ាងនេះ ៗ ពុទ្ធសាសនានុគតកំរ ការធ្វើតាមគតិសាសនានៃព្រះពុទ្ធអង្គ ៗ នេតំ មម នេសោហមស្មិ ន មេសោអត្តា ៗ ចប់រឿងព្រះសុគត ព្រះបមក្សារតែប៉ុណ្ណេះ ៗ (នៅមានត)

# អធិប្បាយភាសិត (ត)

## ២– នាយល្អក្ររកបាន នាយក្លាហានបានស្រេចការ

សាស្ត្រាចារ្យ ឈឹម-ស៊ុម តែងជាកាព្យ

ពាក្យ ៧

ពាក្យថា “នាយល្អក្ររកបាន ឯនាយក្លាហានបានស្រេចការ”

ពីរឃ្លោងយោងឃ្លាជាវោហារ បុរាណាចារ្យតែងចងទុក ។
ខ្ញុំសូមអធិប្បាយស្រាយសេចក្តី ប្រយោជន៍ដើម្បីជាទំនុក
តតាមទំនៀមត្រាត្រៀមទុក ធ្វើជាទំនុកតំណទៅ ។
ឲ្យបច្ឆាជនជាន់អនា– គតកាលគ្រប់គ្នាជាកូនចៅ
ជាសិស្សជាគណជាពូជផៅ តទៅក្រែងត្រូវរើសនាយកោយ ។
ព្រោះថាធម្មតាជនប្រុសស្រី កើតលើផែនដីទោះមុនក្រោយ
ការក្រនៅលើអ្នកនាយកោយ តែនាយធ្វស់ធ្វោយធ្លាយខូចការ ។
ទាល់តែនាយកោយកើតកាក់កប របៀបរបបអ្នកសង្ហារ(១)
ទើបនាំប្រយោជន៍គ្រប់កិច្ចការ នាំផលខ្ទឹមសារយកមកបាន ។
ឯពាក្យថានាយឆាយយល់ទេ គឺជនជាមេយើងគ្រប់ប្រាណ
មេវត្តមេក៉ទាំងប៉ុន្មាន មេគ្រួសារហ៊ានមេភូមិស្រុក ។
បើគេពុំពោលពាក្យថានាយ ពោលថាចៅហ្វាយក៏ស្រណុក
គឺចៅហ្វាយខេត្តចៅហ្វាយស្រុក ចៅហ្វាយឃុំធំគុកចៅហ្វាយរដ្ឋ ។

---

១– អានថា: សង់ហា ។ (សំ.ម. សំហារ) ។ អ្នកសង្ហារ គឺអ្នកនាំ, អ្នកមានការរួបរួម, អ្នកទម្លាយបង់, អ្នកបំផ្លាញ, អ្នកផ្តាច់ផ្តិលនូវបច្ចាមិត្រ ។ កុំច្រឡំនឹងពាក្យ សង្ហា ដែលប្រែថា មានរូបឆើតឆាយ . . . ឡើយ ។

បើតាំពោលពាក្យថាចៅហ្វាយ    ពាក្យថ្មីនៅអាយមានប្រាកដ
ហៅថាប្រមុខមានមុខមាត់    ប្រាកដជាពាក្យវប្បធម៌ ៗ
ដូចពាក្យថាលោកប្រមុខខែត្រ    រុងរឿងត្រដែតដ៏បវរ
ប្រមុខយោធាក្រុងនគរ    ប្រមុខរដ្ឋបវរធំបំផុត ៗ
រីនាយគ្រួសារធម្មតាបែក    បាត់បែងវែកញែកឲ្យបរិសុទ្ធ
ប្អូនឲ្យសៅហ្មងមោះស៊ុតទ្រុត    នោះផុតវិស័យយើងជ្រើសរក ៗ
គឺថាបើយើងបានកសាង    យើងមានសំណាងពីមុនមក
គង់តែកុសលផ្តល់ឲ្យជ្រក    ឲ្យមកចាប់ជាតិក្នុងមេល្អ ៗ
ចិត្តថ្លើមត្រជាក់ទន់ល្អកល្អន    ចេះថ្មិតថ្នមកូនចេះបីទ្រ
ចេះផ្តុំផ្តើមកូនឲ្យបានល្អ    ស្ងួយផុតពីក្រទៅជាមាន ៗ
បើយើងឥតបុណ្យពីបុព្វ    ពុំបានរកទេដ្ឋវិសីលទាន
មុខជាអកុសលផ្តល់រុញច្រាន    ឲ្យកើតក្នុងឋានមេអប្រិយ៍ ៗ
ឥតមានអាណិតចិត្តបូស្សា    ឥតមានមេត្តាត្រាប្រណី
ឥតចេះសង្គ្រោះកូនប្រុសស្រី    ទ្រឹស្តីអន្យត្តិយ៍ខុសជាគាប់ ៗ
ហេតុនេះឃើញថានាយគ្រួសារ    អកិសង្ខារបាត់មកស្រាប់
មានល្អអាក្រក់ទុកសម្រាប់    អ្នកមានបុណ្យក៏ព្វប្សឥតបុណ្យ ៗ
តែទោះជាយ៉ាងដូចម្តេចក្តី    យើងទាំងប្រុសស្រីត្រូវដឹងគុណ
នាយគ្រួសារនេះទុកជាមុន    សឹមយើងដឹងគុណអ្នកដទៃ ៗ

នាយទៅហ្វាយក្រៅពីនេះ យើងត្រូវតែចេះគិតលកលៃ
សម្រាំងសម្រិតស្រិតហើយស្ទួ លកលៃស្ទួយកតែមនុស្សល្អ ។
នាយនេះលំបាករើសរកបាន ទើបចាស់បុរាណពោលថាក្រ
ព្រោះពុំសូវមានជនជាតិល្អ កម្រគ្រប់លក្ខណ៍ជានាយគេ ។
ជនល្អមិនត្រឹមតែអ្នកខ្សែ អ្នកធ្វើអំណោយដល់យើងទេ
មិនត្រឹមតែញាតិយើងញាតិគេ ឡែតែជននោះពេញលក្ខណៈ ។
ល្មមទាញប្រយោជន៍ចែកគេឯង ទៅតាមតំណែងតាមឋានៈ
អាចទ្រទ្រង់បានទូវការៈ ឋានៈដែលខ្លួនត្រូវកាន់រង ។
ចិត្តថ្លើមក៏ជាប់មានពិសោធន៍ មិនវិលប្រឡាកខុសទំនង
មិនលុះអគតិទាំងបួនផង ឬមិនជួរជងមិនខ្វះឈ្មោះ ។
ចំណេះវិជ្ជាស្របករណីយ៍ ទាំងពាក្យសំដីក៏ពីរោះ
ព្យាយាមម៉ឺងម៉ាត់មិនឡេះឡោះ មុខមិនក្រៀមក្រោះស្រស់ប៉ប្រេ ។
ជននោះទើបពេញជាមនុស្សជាំ ឥន្ទ្រព្រហ្មទេព្តាលោកបានថ្លៃ
បានគិតរំពឹងរិះរៃ ហើយលៃចាត់មកខ្សែជាមេ ។
បើផ្ទុយពីនេះពុំមែនជា ពុំមែនទេព្តាចាត់មកទេ
បើយើងជ្រើសរើសយកជាមេ ពុំបានស្រួលទេគង់មានមោះ ។
ចំណែកខាងនាយផ្លូវសាសនា មេវត្តមេវាក៏ដូចបោះ
លោកណាមានកិត្តិស័ព្ទពីរោះ កាន់ក្រិត្យឥតខ្ចោះខាងវិន័យ ។

បេះចាំធម៌អាថ៌ពិតប្រាកដ　　តាំងឥរិយាបថតាំងព្រះទ័យ
ស្របផ្លូវសិក្ខាផ្លូវវិន័យ　　តាំងអធ្យាស្រ័យទន់ត្រជាក់ ៗ
ចូលចិត្តខាងកិច្ចការសម្រប　　សម្រួលឲ្យស្របមិនឲ្យអាក់
មិនឲ្យមានអន់ឲ្យរាក់ទាក់　　ស្មោះស្ម័គ្រគេគ្នាជាប្រក្រតី ៗ
ចូលចិត្តគោចរបិណ្ឌបាត　　សង្វាតតពុទ្ធវេណី
មិនប្រកាន់បុគ្គលប្រុសស្រី　　ស៊ីវិល័យជាន់ថ្នូបដ៏សាសនា ៗ
ចូលចិត្តដឹកនាំបរិស័ទ　　ឲ្យកាត់តម្ងាថាសទ្ធា
ជឿជាក់ក្នុងព្រះពុទ្ធសាស្នា　　ស្មាទានលីលាសាងកុសល ៗ
ចូលចិត្តផ្តុងផ្តើមការសិក្សា　　ផ្លូវពុទ្ធសាស្នាឲ្យដឹងយល់
ឲ្យបេះចូលចិត្តដល់ឫសគល់　　ឲ្យយល់ច្បាស់ផ្លូវទៅនិព្វាន ៗ
មិនលោភប្រឡោភតាមលោកធម៌(១)　　មិនស្ងូវត្រេកអរខាងមានបាន
មិនខំសន្សំបន្តុំប្រាណ　　ស្វែងតែនិព្វានជាត្រីមុខ ៗ
មិនមានកំណាញ់គិតតែបាន　　អ្វីៗដែលមានមិនក្តាប់ទុក
បេះកបេះសាងខាងទំនុក　　បម្រុងផ្គុងផ្គុកក្នុងសាស្នា ៗ

១ អានថា : លោកៈធម៌ ។ ធម៌សម្រាប់ធ្វើសត្វលោកឲ្យមានរីករប៉េងឡើង ព្រមទាំងឲ្យមានរីកជ្រប់ស្រពោន មាន ៨ យ៉ាងគឺ លាភោ ការបាន ១, អលាភោ ការបង់ ១, យសោ ការបានយស ១, អយសោ ការបង់យស ១, និន្ទា ការរិះគន់ ១, បសំសា ការសរសើរ ១, សុខំ សេចក្តីសុខ ១, ទុក្ខំ សេចក្តីទុក្ខ ១ ។

មិនលុះក្នុងអគតិ(១)ប្អូន សូរគេជុំខ្លួនជូនប្រាជ្ញា
ចូលចិត្តធ្វើការផ្លូវសាសនា មិនប្រឹងស្រវាការព្រៃផ្សៃ ៗ
មិនដូចជាសត្វបរេះខា ទំលើមែកពោធិ៍ស៊ីផ្លែជ្រៃ
ជ្រកក្នុងសាសនាធ្វើការព្រៃ ហួសក្រិត្យវិន័យត្រៃសិក្ខា ៗ
លោកនោះទើបជាសង្ឃប្រាកដ គួរជាមេវត្តជាមេកា
ដឹកនាំឧបាសកសិកា ត្រូតត្រាកិច្ចសាមណេរផង ៗ
 នាយឬមេពីរវគ្គនេះ សេសគុនដូចេះទើបហាក់ហ្នង
ទើបនាំយើងជាបរិស័ទធ្ងន់ រំលងពាក្តីអន្តរាយបាន ៗ
 មួយទៀតបើពោលតាមបាលី ដែលព្រះជិនស្រីទ្រង់ទូន្មាន
ជាច្បាប់សម្រាប់នាយប្រធាន ជាត្រូវឲ្យមានធម៌ប្រាំមួយ ៗ
មានឈ្មោះថានាយកធម៌ ជាច្បាប់បវរសម្រាប់សួយ
នូវអ្នកជានាយកមួយៗ ធម៌ទាំងប្រាំមួយដូចតទៅ ៗ

## នាយកធម៌ប្រាំមួយប្រការ

*បទកាកគតិ*

---

១ ការលំអៀង ៤ យ៉ាងគឺ ឆន្ទាគតិ លំអៀងទៅតាមស្រឡាញ់ ១, ទោសាគតិ លំអៀងទៅតាមស្អប់ ១, មោហាគតិ លំអៀងទៅតាមសេចក្តីល្ងង់របស់ខ្លួន ១, ភយាគតិ លំអៀងទៅតាមការខ្លាច ១ ។

១- ក៏ខមា

ការទប់កិរិយា អំណត់អត់ធន់ ព្រោះហេតុក្នុងក្រៅ
ទោះស្រាលទោះធ្ងន់ ខមាការធន់ មានបីប្រការ ។

## ការអត់ធន់កាយ

មិនប្រទូសរ៉ាយ វាយដំប្រហារ ដាល់គប់ទាត់ធាក់
យុកយាក់ដូចមារ មិនឲ្យអសារ បង់ការព្រោះកាយ ។

## ការអត់វាចា

មិនជេរផ្ដាសា បញ្ចោហុយហាយ ស្ដីជៀលដល់ពូជ
ប្រដូចដល់ម្ដាយ មិនឲ្យអន្ដរាយ ព្រោះតែសំដី ។

## ការអត់ធន់ចិត្ត

មិនឲ្យវិបរិត កើតចិត្តអប្រិយ៍ ខឹងឃោរឃៅ
ហើរដូចអគ្គី មិនឲ្យធរណី ឆេះព្រោះភ្លើងចិត្ត ។

២- ជាគរិយ:

គឺសម្បជញ្ញ: ទឹកឃើញការពិត គឺភ្ញាក់ស្មារតី
សំភីពិនិត្យ ការក្រឡាយជិត ពិនិត្យឥតធ្វេស ។

៣- ឧដ្ឋាន:

គឺវិរិយ: ក្រវើនក្រោកក្រេស ខំធ្វើការងារ
ក្នុងក្រៅប្រទេស មិនលង់ទ្រនេស ក្នុងការទ្រមក់ ។

៤- សំវិភាគ

គឺការលះលាភ តាមបែបចាយក ការចែករំលែក
ដល់បដិគ្គាហក[1] សុម្បីទឹកជ្រក់ ក៏ចែកតាមមាន ។

៥- គីឧយា

អាណិតគិតគ្នា ជាញាតិសន្តាន យល់តាមសណ្តាប់
ធ្លាប់ពីបុរាណ និយមកប់អាន ឲ្យបានក្តីសុខ ។

៦- ឥក្ខណា

ការគន់ត្រិតត្រា ពិចារណាជ្រើសមុខ កិច្ចការគ្រប់យ៉ាង
មិនយោកគ្រលុក រៀបឲ្យដឹងមុខ សម្រាំងសម្រេច ។

ធម៌ប្រាំមួយនេះ ជនណាចាំចេះ កាន់កាប់ជាប់ស្រេច
ជននោះថ្លៃថ្លា ចបមាដូចពេជ្រ គួរតាំងសម្រេច
ជានាយយើងបាន ។

តែជនទាំងឡាយ នាលោកយាយ ច្រើនតែខ្ទាន
ដណ្តើមតំណែង ហើយតែងឈ្នានពាន រំលោភពុំមាន
មេត្តាករុណា ។ ច្រើនតែឈ្នានិះ កិរិយាជាន់ជិះ
ដោយចិត្តឫស្យា ប្រណែនខ្ទាចស្មើ ខ្ទាចលើអាត្មា
ម៉្លោះហើយផ្តន្ទា ពង្រីលពង្រេច ។ ហេតុនេះបុរាណ

1 អានថា ប:ដិកគាហ៊ក់ (អ្នកទទួល) ។

ពោលតាមលំនាំ ជាការសិតស្រេច ថានាយល្អ
ក្រមានដូចពេជ្រ នាយក្លាហានស្រេច កិច្ចការសុខសាន្ត ៗ
គឺថានាយល្អ ពិតជាមហាក្រ កម្រកបាន
ព្រោះលំបាកជ្រើស រើសរកកល្យាណ គ្រប់លក្ខណ៍ដូចបាន
សម្តែងមកនេះ ៗ បើបានកល្យាណ ល្អហើយក្លាហាន
មានទាំងចំណេះ ចំណាំចាំច្រើន ក្រវើនតាមចេះ
នាយកយ៉ាងនេះ ទើប យើងជ្រកបាន ៗ ខ្ញុំសូមស្រដី
តាមបទបាលី ជារឿងនិទាន ដើម្បីបញ្ជាក់
នាយល្អក្លាហាន កម្រកបាន បើមានបានសុខ ៗ

## រឿងទេវទត្តនិងពោធិសត្វកើតជាស្វា

### តយោធម្មជាតក

#### បទពំនោល

អតីតកាលកន្លង កពកាន់រលង វែងឆ្ងាយយូរយារហើយណា ៗ កាលណោះមែនមានសត្វស្វា ច្រើនក្រៃគ្រៀបគ្រា នៅព្រៃហេមពា ក្បាលស៊ឹង ៗ គង្គាជលធារធំល្វឹង ហូរចុះសន្ធឹង ធំល្វឹង កម្រឆ្លងបាន ៗ ពានរនួពិនពូជហនុមាន ក៏រយារយោនពាន ទន្ទ្រានជះជាន់ដណ្តើម ៗ យកទីជាស្តេចស្វាផ្ដើម ហើយហ៊ានហែកថ្មើម ពួកស្វាណាមិនគោរព ៗ តាំងខ្លួនជាម្ចាស់ពិតពួ

ព្រឹក្សាព្រៃផប់ ព្រៃជាំជំនាប់ហោមវ័ទ្ធ ។ ស្វាឈ្មោលទាំងរយទាំង
ពាន់ ត្រូវពានរិទ្ធជាន់ ចាប់ជិះសម្ទេះសម្លាប់ ។ នៅតែស្វាញី
គាន់គាប់ រស់នៅសម្រាប់ ធ្វើប្រពន្ធពុំម្នាក់ឯង ។ ស្វាញីកើត
កូនវែង កូនញីរាំលែង លោះលាឲ្យមានជីវិត ។ កូនឈ្មោល
រាំពុំអាណិត ធ្វើហាក់ផ្ដេកផ្ដិត ហើយគ្រិតគ្រញិចក្ស័យអស់ ។

មានមេស្វាមួយសប្បុរស បង់ឲ្យកូនរស់ ក៏កៀសហៃលទឹកធ្ងន់
ទៅ ។ តាំងពីកូនទោះបិតនៅ ក្នុងផ្ទៃមើលទៅ ពុំដឹងជាឈ្មោល
ឬញី ។ លុះផ្ទៃគ្រប់ខែពេញទី ទើបនាងស្វាញី ប្រសូតកូន
ឈ្មោលល្អគាត់ ។ គឺជាព្រះពោធិសត្វ ដែលត្រាច់រង្គាត់ មក
ចាប់ជាតិជាកូនស្វា ។ លោកនៅជាមួយមាតា ដឹងក្ដីកាលណា
សួរគេបិតាបានដឹង ។ ជាបិតាអាក្រក់ម៉្លឹង ទើបលោកខំប្រឹង
ហាត់ប្រាណបានស្ទាត់ក៏ឡា ។ ព្រឹកឡើងឡើងបេះផលា មក
ឲ្យមាតា គោក្ដាខ្លួនឯងសម្រន់ ។ ល្មមតែមានកម្លាំងគ្រាន់ ក៏
ស្ទុះបំភាន់ ឲ្យមាតាដេញតាមចាប់ ។ ឡើងចុះលោតផ្លោះ
ប្រញាប់ ឲ្យម្ដាយដេញចាប់ ប្រញាប់លោតហក់គេចកែ ។ ឈម
មុខខាងណោះហើយបែរ បត់ប្រាសគេចកែ បែរមកខាងណោះវិញ
ក្លែត ។ មាតាស្រវាចាប់បៃត កូនគេចចេញក្លែត ម្ដាយហត់
ម្ហិត ៗ នៅស្ងៀម ។ ធ្វើយ៉ាងនេះជាទំនៀម ពុំដែលនៅស្ងៀម

ពេលព្រឹកណាមួយសោះឡើយ ។ ទាល់តែចម្រើនធំហើយ ក៏ពុំកន្តើយ ខំហាត់អត្តពលកម្ម ។ អស់កាលយូរខែយូរឆ្នាំ អត្តពលកម្ម ចង់ចាំគ្រប់ល្បិចកិច្ចល្បង ។ ស្ទុះលោលោតផ្លោះរំលង លផ្នែកមែកផង មិនបាច់មានបង្គង់សួ ។ ហែលទឹកមិនបាច់មានស្នួ ហ៊ានហែលឆ្លងជួ ទឹកជ្រោះហូរចុះចំហុង ។ រំលិចទឹកជ្រៅសន្ធឹង ហ៊ានលោតប្លោកប្លុង(១) ទៅក្នុងជលធារធ្លារទឹក ។ មុជលើកដុំថ្មសន្ទឹក ស្រង់ផុតពីទឹក ឥតពូជស្វាណាធ្វើដូច ។ ព្រោះហេតុលោកគិតពីតូច ថានឹងបង្ខូច គំនិតអាក្រក់បិតា ។ បើអញទៅដល់កាលណា ពានរិន្ទស្ដេចស្វា ស្រវាចាប់អញអញគេច ។ បើចាប់អញបានហើយល្មួច អញមិនរត់គេច អញប្រឹងឡុងឹងកម្លាំង ។ បើបិតាក្រៀវក្រាខ្លាំង អញនឹងប្រឆាំង រុញវៃឲ្យចូលក្នុងស្ទឹង ។ បើម្ដឹងហើយគាត់នៅប្រឹង គង់ធ្លាក់ក្នុងស្ទឹង លង់ល្ងក់ផ្សេៗពុំខាន ។ ព្រោះគាត់នឹងទ្រាំពុំបាន នឹងបន្ទន់ប្រាណ អញបានឱកាសប្រដៅ ។ ឲ្យគាត់ក៏ចាត់ក្ដីក្ដៅ ជម្រះកម្ដៅ ឲ្យនៅជាសុខសប្បាយ ។

លុះដល់ឥទ្ធិពលពណ្ណរាយ ទើបលោកនាំម្ដាយ ឆ្លងចូលទៅក្នុងហុងធំ ។ ពានរិន្ទពិនភជឧត្តម នៅក្នុងហុងធំ បានឃើញ

---

១ ប្លុង ជាភាសាបារាំង ។ កិរិយាស័ព្ទ គេសរសេរ PLONGER , នាមស័ព្ទ គេសរសេរ PLONGEON ដូចគ្នានឹងភាសាខ្មែរថា : ប្ដោង, ការប្ដោង ។

ករិយាមកដល់ ។ មានទាំងកូនឈ្មោលរិមល ដែលពុំធ្លាប់យល់ ក៏ស្ទុះមកសាកសួរថា ។ តានេះឯងមកពីណា ឯងជាពូជស្វា ក្រៅវង្សចង់កេរឿងប្ត ?

ព្រះពោធិសត្វបានព្ ឆ្លើយថាខ្ញុំគឺ ជាបុត្របិតានេះឯង ។ កាលមាតាជាប់សង្វែង ព្រាត់ទៅម្នាក់ឯង បានប្រសូតខ្ញុំឯណោះ ។ ខ្ញុំពុំស្គាល់បិតាសោះ ទើបត្រាច់ចរផ្ដោះ មករកបិតាហ្នឹងឯង ។

ពានរិន្ទឈានដើរចំទែង លូកដៃប្រឡែង ថាឯងជាបុត្របិតា ។ ឥឡូវឱស្ងុំថើបបា ជាទីស្នេហា ចូរបាមកឥាយណាំទៅ ។

ពោធិសត្វលុតលូនទៅ ហត្ថប្រណម្យនៅ នៃបទិត្យជិតជាប់ទុក ។ ពានរិន្ទឱបក្ដោបកាយា រូបរិតហត្ថា ប្រាថ្នាគ្រញិចឲ្យស្លាប់ ។ ដើងជាន់ដៃឱបយ៉ាងខ្ជាប់ ម្រាមទិងម្រាមតាប់ តាក់ស្រេះប្រឡេះពុំបាន ។ មាត់ហាជង្គ្រងប្រឹងប្រាណ នឹងវាំបំពាន ឲគ្រាំនកកេរឲ្យស្លាប់ ។

ពោធិសត្វសោតប្រញាប់ លើកដៃជ្រោងតាប់ បំពង់កជាប់ដូចច្បោះ ។ គួយដៃគះតាំសោះ ដើម្បីទឹងដោះ ខ្លួនឲ្យរួចចេញទៅវិញ ។

ម្រាមដៃពានរិន្ទនោះមិញ គ្រេចចេញឈាមព្រិញ ដោះវិញប្រញាប់លែងតាប់ ។ ទុករកកល់ប្រេះស្លាប់ ញ័រមាត់ប៉ប៉ាប់ ឈឺកស្ទុឈាមមួយគ្រា ។ ប៉ុន្ដែកម្លាំងក្រោធា ឆ្លើឲ្យស្តេចស្វា មិនព្រមចុះចាញ់សោះឡើយ ។ ទ្រឹងមួយស្របក់នៅហើយ ស្ទុះមកបង្អើយ ថានៃ

អាហ្អើយបើចង់ ៗ ដឹងគេជះដៃពានវគ្គ ឯងកុំបង្អង់ កុំកុំរង់ឡើយណា ៗ
ចូរឡើងប្រណាំងបេស្តា លើចុងព្រឹក្សា បើថាអាឯងគ្រាន់បើ ៗ
ពោធិសត្វឆ្លើយថាយើ ឪខ្ញុំទេតើ ម្តេចធ្វើអំពើយ៉ាងហ្នឹង ៗ
ទ្រមម៉ើះហើយបេះតែប្រឹង គ្រោមដៃគ្រេចម៉ឹង ចង់ប្រឹងលើចុងព្រឹក្សា ៗ
ប៉ុណ្ណឹងចុះណាំបិតា លើចុងព្រឹក្សា ខ្ញុំតែក្មៀវក្លាជាងនេះ ៗ
កុំថាលើគោកដូច្នេះ បើជនណាបេះ ច្បាំងក្នុងទឹកខ្ញុំក៏ហ៊ាន ៗ
ហេតុនេះសូមឪអាក់ខាន កុំធ្វើបំពាន លើអ្នកឥតទោសដូច្នេះ ៗ
ពានរឮហើយស្ទើរប្រេះ ឧរបេះ ថ្ងើមធ្លាក់លើព្រះធរណី ៗ
ខឹងឃោរក្តៅដូចព្រះអគ្គី ស្ទុះមកទឹងឈើ ឡេខ្លួចឡូខ្លួដើងដៃ ៗ
ប៉ុន្តែពោធិសត្វថ្វៃ រហ័សពេកក្រៃ ស្ទុះវៃថយផុតពីមុខ ៗ
ពានរទូទង្គិចទង្គុក ទឹងគល់ឈើចុក ត្រទាំងពេកានគាំងអែនអន ៗ
ទ្រឹងមួយស្របក់លោតក្លូន ស្រវាគោងគន ចាប់គល់កន្ទុយយ៉ាងម៉ាំ ៗ
ពោធិសត្វរត់អូសនាំ ទង្គិចគល់គ្រាំ ស្វាឪព្រញាំឈាមមាត់ ៗ
នៅតែគោងស្អិតពេកក្តាត់ ទោះបីរត់កាត់ ព្រៃញាតស្បាតក៏ពុំលែង ៗ
គោងគ្នាឡើងដើមអញ្ចែង(១) ទឹងដើមកម្រៃង(២) បង្គាបបែកខ្នងស្វេស្វុក ៗ
កូនរុលរួចជាប់ឪពុក ក្នុងបង្គាបស្វុក ស្វញស្វាញប៉ូញបាញធ្មេញស្វេញ ៗ

---

(១) ឈ្មោះឈើមួយយ៉ាងដើមធំខ្ពស់ មែកសាងញ៉ាង ។ (២) ឈ្មោះដើមឈើមួយយ៉ាង ដើមធំខ្ពស់ សាច់រឹងដូចគ្នានឹងដើមកែស ស្លឹកដូចស្លឹកព្រាមរមាសមែកបែកខ្នែងក្ញុក ក្ញក់ជង្គុំសាងញ៉ាង ។

កូនគិតអាណិតដោះចេញ លំអុតលំគេញ សូមឲ្យបន្ថយកំហឹង ។
ស្វាឪក្រញូវខូវខ្ញឹង ទោះបីទ្រមម៉ឹង កំប្រឹងស្រវាឱបទៀត ។
ប្រហាប់ប្រដែងជ្រែងជ្រៀត បំបែរបំបៀត ពានរិទ្ធភ្ញាក់ស្មៀតផ្ទាក់ស្ទឹង ។
ខំស្ទុះលោតពេញកំហឹង ឡើងពីមាត់ស្ទឹង ខំប្រឹងឥតមានសំចៃ ។
កូនចាប់ជើងជាប់ខ្វៃ ៗ ដៃម្ខាងចាប់ដៃ ផ្អោបជាប់ផ្អាប់ជិតឧរា ។
បីទ្រពនាំស្តេចស្វា ចុះក្នុងគង្គា ស្ទួរថាប៉ាចងមុជទឹក ។
ឬមួយកំប៉ាចង់ផឹក ទឹកស៊ួរ្ស(១)សន្ទឹក ហូរចេញពីរូងថ្មជា ។
ហ៎ះឥឡូវខ្ញុំនាំប៉ា មុជជ្រែកគង្គា ចូលរូងថ្មជាផឹកទឹក ។
ពានរិទ្ធកិតភ័យពន្ទឹក ព្រុថាមុជទឹក កំនឹកថាឱអញស្លាប់ ។
ទើបអង្វរគេប្រញាប់ ថាកូនកុំចាប់ ប៉ាសូមចុះចាញ់ហើយកូន ។
ពោធិសត្វសោតលំអូន លំអុតទន្ទូន ថាកូនឥតមានប្រទូស្ត ។
ប៉ុន្តែខុងឯងរឹងរូស ខំប្រឹងប្រទូស្ត នឹងខ្ញុំដែលឥតទោសសោះ ។
តទៅកុំធ្វើដូច្នោះ នាំខូចកេរ្តិ៍ឈ្មោះ ពីព្រោះខុសច្បាប់អ្នកធំ ។
បិតាជានាយឧត្តម ធម្មជាតិរៀបចំ ឲ្យជានាយកលើកូន ។
ច្បាប់ថាត្រូវតែល្អួកល្អួន បិតុស្ងួនទន្ទូន រកកូនជានិច្ចប្រក្រតី ។
ឪមិនត្រឹមតែជាបី- តាយើងប្រុសស្រី ជាព្រះចក្រីថែមទៀត ។

---

១ ស៊ួរ្ស ភាសាបារាំង សរសេរ Source អានថា សួក ។ គឺទឹកស្អាតហូរចេញពីរូងថ្មជ្រោះភ្នំ ។ បាលីហៅថា បភវោទក ។

ហេតុនេះគួរតែប្រឹងទៀត កុំឲ្យវាត ពីច្បាប់សម្រាប់នាយក ។
បើនាយប្រើចិត្តតក់ម៉ក់ ជាធម៌តម្រក់ ឈ្លីឈ្លក់ជិះជាន់ពលឯង ។
ឲ្យខ្លាចណាវាកោតក្រែង នាយជាន់ពលឯង អាយុស្មមិនវែងទេ ។
ហេតុនេះតាំងពីឥឡូវ ឲ្យត្រូវស្វែងត្រូវ តាមខ្ញុំនាំផ្លូវកុំខាន ។

ស្ដេចស្វាជាទីកល្យាណ អ្នកពោលទូន្មាន មកតាំងប៉ុន្មានឲ្យតាម ។
ជាហើយនាំគ្នាវិលភ្លាម ចរត្រាច់ទៅតាម រកហ្វូងសុំស្នំស្រីគ្ការ ។
ទៅជិតទៅចមបរិពារ ចេញមកខ្សៀវខ្សារ មេនាងមេទៅជួបជុំ ។ នៅ
ទិត្យជួបជិតជាក្រុម ជាសុខពិតពុំ មានមោះគ្រោះថ្នាក់អ្វីឡើយ ។ ដោយ
សារបានទីពឹងហើយ ដូចអ្នកដល់ត្រើយ បានស្បើយចាកភ័យអន្តរាយ ។
ពួកស្វាលុះសុខសប្បាយ កូនដូចគេពាយ រស់នៅតាំងញីតាំងឈ្មោល ។
ពោធិសត្វជាបង្គោល ឲ្យស្វាញីឈ្មោល ពឹងផ្អែកជ្រកកោនគ្រប់គ្នា ។
សាមគ្គីសាមគ្គា រួមរស់ពល់គ្នា មានសេរីភាពស្មើមុខ ។

តមកស្ដេចស្វាជាទុក្ខ គិតថាទៅមុខ អញអស់អំណាចសូន្យឈឹង ។
ព្រោះតែអាដែងកូនហ្នឹង វាជាទីពឹង នៃពួកពលស្វាទាំងអស់ ។
កូននេះបើវានៅរស់ វាឲ្យអញអស់ ជន្មាយុផងពុំដឹង ។
ដូច្នេះគួរឲ្យទៅស្វឹង រំលិចចំលឹង ព្រៃស្ដុក[១] ស្រោងស្រីងមានស្រះ ។

---

១ ព្រៃស្ដុក ( ដើង ដ ) គឺព្រៃញាតស្បាតដុះរួបរឹតជិតឈើធំៗក្នុងទីទំនាប ។ ត្រពាំងឬបឹងដែលមានឈើដុះពេញក្នុងទឹក ក៏គេហៅថាស្ដុកដែរ ( ត្រពាំងស្ដុក, បឹងស្ដុក ) ។

ឈូកផ្កាត្រៀបត្រាក្រៃក្រាស់ អារក្សកាចណាស់ នោះច្បាស់ជាវ៉ាទីងស្លាប់ៗ
គិតស្រេចស្តេចស្វាប្រញាប់ ហៅកូនមកឆាប់ ប្រាប់ថាកូនស្ងួនឪពុក ៗ
អ្នកឯងតែងបំបាត់ទុក្ខ ធ្វើឲ្យបានសុខ ដល់ពួកពលស្វាគ្រប់គ្នា ៗ
ប៉ុន្តែមាសមិត្រពាំងា ពុំទាន់បានជា ស្តេចស្វាពេញមុខនៅឡើយ ៗ
ដូច្នេះកូនកុំកន្តើយ កុំផ្សរផ្សងឡើយ ចូរកូនទៅរកឧប្បល(១) ៗ នោះ
ហ្ន៍ដែលមើលទៅយល់ ព្រៃស្តុកមណ្ឌល(២) មានស្រះឧប្បលនៅនោះ ៗ
ត្រូវកូនមាសស្ងួនបួលផ្ដោះ ចុះក្នុងស្រះនោះ បេះផ្កាឧប្បលម្ចុក ១ ៗ
ឈូកសក្រហមចម្លែក ស្លឹកផ្កាបែក គ្របកម្មួយរយស្រទាប់ ៗ
ឲ្យបានផ្កានោះមកឆាប់ ទុកទីងរណ្ដាប់ រៀបអភិសេកឲ្យបា ៗ
បានសោយរាជជាស្តេចស្វា គប់ដោយបេស្កា ថ្លៃថ្លាឧត្តមសមស័ក្តិ ៗ

ព្រះពោធិសត្វស្តាប់ជាក់ ក្រពុំហត្ថដាក់ លើត្បូងសិរសាប្រណម្យ ៗ
ចំពោះសម្ដេចបរម បិតាជាធំ ហើយទៅសំដៅស្រះស្រង់ ៗ
លោកមានស្មារតីតម្រង់ សម្បជញ្ញៈផ្ចង់ ឥតធ្វេសប្រហែសឡើយណា ៗ
ពិនិត្យមើលស្នាមបាទា សត្វផងនានា ឃើញសុទ្ធតែស្នាមដើរចុះ ៗ ឥត
ឃើញស្នាមដើរឡើងសោះ យល់ថាមានគ្រោះ អាក្រក់ក្នុងស្រះនោះឯងៗ

---

(១) ឧប្បល គួរអានថា ឧបបល់ ប៉ុន្តែទម្លាប់អានថា ឧបុល ដូចភទ្របទ ទម្លាប់អានថា ភាត់ទ្រះបុត, វិតក្ក ទម្លាប់អានថា វិតុក្ក, ឧសភ ទម្លាប់អានថា ឧសុប ។

(២) មណ្ឌល ប្រែថា មូលជុំ ។

ស្រះនោះពិតជាកន្ទ្វង អារក្សទឹកតែង តែចាប់សត្វបរិភោគ្គា ។
យល់ច្បាស់ឥតមានសង្កា លោកកំរេព ពុំហ៊ានឈានចុះចូលទឹក ។
គន់ឃើញផ្កាឈូកសន្ធឹក ដុះក្បែរមាត់ទឹក ទើបទៅបេះកាន់មកគរ ។
បានផ្កាច្រើនមួយគំនរ បម្រុងត្រាច់ចរ យាត្រាត្រឡប់វិលវិង ។

អារក្សទឹកនៅជិតហ្នឹង នេត្រាសម្លឹង សម្លក់ពិនិត្យចរិយា ។
យល់ជាអ្នកមានប្រាជ្ញា ស្មារតីថ្លៃថ្លា បុកពាកិរិយាក្លាហាន ។

ទើបយក្សប្លែងភេទផ្លាស់ប្រាណ ជាមនុស្សសាមាន្យ បានដើរចរចូលមកជិត ។ សម្លឹងហើយរឹងពេញចិត្ត ព្រោះហេតុឃើញពិត ជាអគ្គបណ្ឌិតគ្រប់លក្ខណ៍ ។ ទឹងបានជានាយសោភ័គ្គ ជាទីពឹងពាក់នៃពួជពង្សវង្សពានរ ។ ទើបសូត្រស្តុតិ(១)បវរ សរសើរពានរ ដោយបទព្រះគាថា ថា :

( យស្សេតេ ច តយោ ធម្មា វានរិន្ទ យថា តវ
ទក្ខិយំ សុរិយំ បញ្ញា ទិដ្ឋំ សោ អតិវត្តតិ )

---

១ បា. ថុតិ, សំ. ស្តុតិ; ខ្មែរស្តុតី អានថា ស្តុតដី ( សេចក្ដីសរសើរ ) ។

(នៅមានត)

# ឯកសារ កម្ពុជសុរិយា

( ក )

លោក ឌឹក-គាម ប្រមូលរៀបរៀង

គុណនៃព្រះត្រៃបិដក : លោក ស្រី-អ៊ូ, ទ.ក ១០, ទំព័រ៩៤០, ឆ្នាំ ១៩៥៨ (ម.៥២/៣០) ។

គុណសម្បត្តិនៃអ្នកទេស្ន : ព្រះទេពសត្ថា សួរ-ហាយ, ទ.ក ៥, ទំព័រ ៣៤៦, ឆ្នាំ ១៩៥២ (ម.៥២/២៤) ។

គុណសម្បទា : អាចារ្យ ហ៊ុម, ទ ក ១០-១១-១២, ទំព័រ ២១៥, ឆ្នាំ ១៩៣៩ (ម.៥២/១១) ។

គុណូបការកុស្សរណាសច្ចកិរិយា (របស់ព្រះមហាវិមលធម្មថោង) : ព្រះញាណបវរវិជ្ជា កែម, ទ.ក ២, ទំព័រ ៧៣, ឆ្នាំ ១៩២៧ (ម.៥២/២) ។

គួរដឹងទំនៀមខ្លះនៅប្រទេសឥណ្ឌូណេស៊ី : អ្នកស្រី ពេជ-សល់, ទ.ក ១២, ទំព័រ ១៤០៦, ឆ្នាំ ១៩៦០ (ម.៥២/៣២) ។

គួរតែប្រឡះភារៈចោលខ្លះ : លោក ផេង-ជ្រីវ, ទ.ក២, ទំព័រ ១៤៩, ឆ្នាំ ១៩៦៤ (ម ៥២/៣៦) ។

គួរតែអនុវត្តនូវការឃុំចីពរនៃសាមណេរឬ? : ព្រះមុនី-

គោលស សូរ-ហាយ ទ.ក ១១, ទំព័រ ១០៩៨, ឆ្នាំ ១៩៦៣ (ម.៥២/៥៣) ។

គេឱ្យច្រើនកុំយក : ម.រឿងព្រេងប្រាជ្ញសុភាសិត ៤ បទ ។

គោញី : លោក គ.ហ-ម៉ូណូទ៍ ទ.ក ១, ទំព័រ ២៤, ឆ្នាំ ១៩៣៥ (ម.៥២/៧ ។

គោលច្បាប់ព្រះពុទ្ធសាសនា : លោកហេង-សំអាន, ទ.ក៨, ទំព័រ ៨៦១, ឆ្នាំ ១៩៦២ (ម.៥២/៣៤) ។

គោលព្រះនិព្វាន : ព្រះឧបាលិវង្ស សូរ-ហាយ, ទ.ក ១, ទំព័រ៨១១, ឆ្នាំ ១៩៦០ (ម.៥២/៣២) ។

គោលសំខាន់ៗនៃព្រពុទ្ធសាសនា (សម្រាប់មនុស្ស ចំដើបផ្ដី (អំពី) : លោក គមោម៉ុតស៊ុ, ទ.ក ១១, ទំព័រ ៣, ឆ្នាំ ១៩៤០ (ម.៥២/២) ។

កំណូរថ្មីពីរបែប (អំពី) : ខេមរវង្ស ទ.ក ២, ទំព័រ ៣, ឆ្នាំ១៩៤០ (ម.៥២/១២) ។

កំរូកតញ្ញូធម៌ចំពោះមាតាបិតា (រឿងព្រេងជប៉ុន) : អ្នកស្រី អ៊ុច សុន, ទ.ក៨, ទំព័រ ៧១៧, ឆ្នាំ១៩៥៧ (ម.៥២/២៩)។

ក្រូនិងសិស្ស (រឿងព្រេង) : ទ.ក ៤-៥-៦, ទំព័រ ៧១, ឆ្នាំ ១៩៣៩ (ម.៥២/១១) ។

ក្រសាញ់អ្នកខ្ញាំងក្លៃគា : សាស្ត្រាចារ្យ ផេង-ជ្រើវ ទ.ក១, ទំព័រ ៣, ឆ្នាំ ១៩៥២ (ម.៥២|២៤)

ក្រោងការបុណ្យព.ស ២៥០០ : ធម្មការ, ទ.ក ៤, ទំព័រ៣៦៦, ឆ្នាំ ១៩៥៧ (ម.៥២|២៩) ។

ឃរាវាសធមិ : ព្រះអរិយកស្សប កែវ-អ៊ូច, ទ.ក ១០, ទំព័រ ៧៣១, ឆ្នាំ ១៩៥២ (ម.៥២|២៤) ។ ព្រះបាឡាត់ឧត្តមលិខិត សុង-ស៊ីវ ទ.ក ១១, ទំព័រ ៨០៣, ឆ្នាំ ១៩៥៥ (ម.៥២|២៧) ។

ឃរាវាសធម្មកថា . ព្រះគ្រូមុនីសោភ័ណ សេខ-នាង ទ.ក ៨, ទំព័រ ៥៧៤, ឆ្នាំ ១៩៥១ (ម.៥២|២៣) ។

ឃ្លានចំអត់ : ម. វឿន ពង់ប្រាព្ធសុភាសិត ៤ បទ ។

ឃ្លោកលិចអំបែងអណ្ដែត : ព្រះទេពសត្ថា គីម-តូវ, ទ.ក ៤, ទំព័រ ២៥៣, ឆ្នាំ ១៩៥៥ (ម.៥២|២៧) ។

ចក្កធម្ម: ព្រះវិនយធម្ម យូរ-ប៊ុណ, ទ.ក.៥, ទំព័រ ៣៨៨, ឆ្នាំ ១៥៤៨ (ម.៥២|២០) ។

ចក្កធម្មកថា: ព្រះមហាឌុច-សាទី, ទ.ក.២, ទំព័រ ១២៩, ឆ្នាំ ១៩៦០ (ម.៥២|៣២) ។

ចង្កូមកែវ (ព្រះ): លោក ឌឹក-គាម, ទ.ក.២, ទំព័រ ១២៦, ឆ្នាំ ១៩៦៣ (ម.៥២/៣៥) ។

ចចកក្មេងធ្វើស្ដេច (រឿងព្រេងចិន): លោក ក៉យ-ប៊ុក, ទ.ក. ៣, ទំព័រ៣២០, ឆ្នាំ ១៩៦៤ (ម.៥២/៣៦) ។

ចចកដល់ទ្វារគ្រោះថ្នាក់ (រឿងព្រេង): ទ.ក ១០-១១-១២, ទំព័រ ១៤៣, ឆ្នាំ ១៩៣៦ (ម.៥២/៨) ។

ចម្បាំងក្នុងលោក: លោក ប៊ូ-ឧរិទ្ធ, ទ.ក. ៤, ទំព័រ ៣៩២, ឆ្នាំ ១៩៦៤ (ម.៥២/៣៦) ។

ចម្រៀងគេត្ថារបស់បញ្ចសិខទេវបុត្រ: ព្រះអាចារ្យ ញ៉ុង-សឿង, ទ.ក.៥, ទំព័រ ២៤៩, ឆ្នាំ ១៩៥៣ (ម.៥២/១៥) ។

ចម្រៀងពួកយុវសាលា: ទ.ក. ៧-៨-៩, ទំព័រ ១៨៨, ឆ្នាំ ១៩៣៩ (ម.៥២/១១) ។

ចលនាអក្សរខ្មែរ: លោក ឌឹក គាម, ទ ក.២ , ទំព័រ ១៧៦, ឆ្នាំ ១៩៦៥ (ម ៥២/៣៧) ។

ចាតុរង្គបទ: ព្រះមហាពិទូរក្រសេម, ទ.ក.១-២-៣, ទំព័រ១២៣, ឆ្នាំ ១៩៣៨ (ម.៥២/១០) ។

ចាបពួកប្រល្បោះនឹងចាបក្បាលទំពែក: ទ.ក. ២-៣, ទំព័រ ៦៧, ឆ្នាំ ១៩៣៥ (ម.៥២/៧) ។

ចិញ្ចៀនពិត (រឿង): អ្នកស្រី សារ-យ៉ាន់, ទ.ក.៦, ទំព័រ៤៥៣,
ឆ្នាំ១៩៥៣ (ម.៥២/២៥) ។

ចិត្តកាជា: ព្រះបាឡាត់ឧត្តមលិខិតសុន-ស៊ុំ, ទ.ក.១២, ទំព័រ៨៩០,
ឆ្នាំ១៩៥៥ (ម.៥២/២៧) ។

ចិត្តដឹកនាំលោក: ព្រះពុទ្ធវង្ស កឹម-តូរ, ទ.ក.១-, ទំព័រ ៨៦៧,
ឆ្នាំ១៩៥៨ (ម.៥២/៣០) ។

ចិត្តតាក់តែងរូប: យុទបណ្ណាទុរក្ស ប៊ូ-ប៊ូ, ទ.ក.១០, ទំព័រ៩០៣,
ឆ្នាំ១៩៥៦ (ម.៥២/២៨) ។

ចិត្តល្ងង់ខ្លៅនិងចិត្តចេះដឹង: យុទបណ្ណាទុរក្ស ប៊ូ-ប៊ូ, ទ.ក.៥,
ទំព័រ ៤៣៣, ឆ្នាំ ១៩៥៦ (ម ៥២/២៨) ។

ចូឡបទុមជាតក: យុទ្ធសោភ័ណកក្ដី អ៊ុម-កន, ទ,ក,១២, ទំព័រ
៧៥៩, ឆ្នាំ១៩៤៥ (ម.៥២/១៧) ។

ចូឡសីលក្នុងសាមញ្ញផលសូត្រ: លោក ប៊ូ-ប៊ូ, ទ.ក.១១,
ទំព័រ ១.១៣៥, ឆ្នាំ ១៩៦៤ (ម.៥២/៣៦) ។

ចៀប-គ្រុក-ព្រះក្រុក្កសន្ដោ: លោក ផល-ទិត្យ, ទ.ក.៥,
ទំព័រ ៥៤៩, ឆ្នាំ ១៩៦៣ (ម.៥២/៣៥) ។

ចេតិយបុរាណក្នុងស្រុកកលញ្ញា: លោក ហុការត៍, ទ.ក.៦,
ទំព័រ ១, ឆ្នាំ១៩៤៧-៤៨ (ម.៥២/២) ។

ចែការផ្ទាង់សិស្សមកពីស្រុកកម្ពុសាំងស៊ុន (អំពី): ទ.ក.
១-២-៣, ទំព័រ ៤២, ឆ្នាំ ១៩៣៣ (ម. ៥២/៦) ។

ចោរកម្ម: លោក ផេង-ជ្រីវ, ទ ក. ១០, ទំព័រ ១០៣៦, ឆ្នាំ១៩៣៦
(ម.៥២/៣៥) ។

ចោរលួចក្រដាស (រឿងព្រេង): ទ.ក. ២៣, ទំព័រ២៥,
ឆ្នាំ១៩៤១ (ម.៥២/១៣) ។

ចៅកាំបិតឈ្នាល (និទាន): លោក ម័ន-អេង, ទ.ក.៣,
ទំព័រ ៣១១, ឆ្នាំ ១៩៥៩ (ម. ៥២/៣១) ។

ចៅកាំបិតបន្ទោះ (រឿង): ទ.ក. ១-២-៣, ទំព័រ ៦៣, ឆ្នាំ
១៩៣៩ (ម. ៥២/៣១) ។ លោក ហាន់-យេង, ទ.ក. ២, ទំព័រ
៨៨, ឆ្នាំ១៩៤៤ (ម.៥២/១៦) ។

ចៅតប់ប្រមល់: ទ.ក. ១-២-៣, ទំព័រ ២៧៣, ឆ្នាំ ១៩៣៩
(ម.៥២/១១) ។

ចៅដុងចៅសាញ់ (រឿងព្រេង): ទ.ក.៤, ទំព័រ២២៣,
ឆ្នាំ ១៩៤៣ (ម.៥២/១៥) ។

ចៅចាយក្តាំង: លោក ទៀង-តៃឈុន, ទ.ក. ១២, ទំព័រ១០៨៨,
ឆ្នាំ ១៩៥៩ (ម.៥២/១៩) ។

ចៅម្ចាស់ដួះនិងចៅសុំសិចត (រឿងព្រេង): ទ.ក.១១.១២, ទំព័រ ៥៤, ឆ្នាំ១៩៤៤ (ម.៥២/១៤) ។

ចៅរលោដូង: លោក ឱក-គាម, ទ.ក.១១, ទំព័រ ៥៦, ឆ្នាំ១៩៦៥ (ម.៥២/៣៧) ។

ចៅសុចចៅសោះ (រឿងព្រេង): ទ.ក. ១.២ ៣, ទំព័រ៧៧, ឆ្នាំ ១៩៣៦ ( ម.៥២/៨ ) ។

ចំណោះវិជ្ជាក្នុងលោក: ទ.ក. ១២, ទំព័រ១៥, ឆ្នាំ ១៩៤០ (ម.៥២/១២) ។

ចំពោះប្រទេសជាតិផងសេស: ទ.ក.៨, ទំព័រ១១, ឆ្នាំ ១៩៤១ (ម.៥២/១៣)។

ច្បាប់កេរកាលថ្មី (កាព្យ : ព្រះភិរម្យភាសា អ៊ូ ហៅ ង៉ុយ ទ.ក. ៣.៦, ទំព័រ១៨១, ឆ្នាំ ១៩៣១ (ម.៥២/៤) ។

ច្បាប់គិតកន្ត្រៃ (រឿងព្រេង): ទ.ក.១០-១១-១២, ទំព័រ ២៨៣, ឆ្នាំ ១៩៣៩ (ម.៥២/១១) ។

ច្បាប់ក្បួនចៅ: ក្រមង៉ុយ, ទ.ក. ៤-៥-៦, ទំព័រ ១០៩, ឆ្នាំ ១៩៣៧ (ម.៥២/៩) ។

ច្បាប់ក្រមថ្មី (កាព្យ) : ព្រះភិរម្យភាសា អ៊ូ-ហៅ ង៉ុយ, ទ.ក. ៣៦, ទំព័រ ១៤៩, ឆ្នាំ ១៩៣១(ម.៥២/៤) ។

ច្បាប់ក្រមបរិយាយៈ លោក ញឹក-នូវ, ទ.ក. ៦, ទំព័រ៣០៥, ឆ្នាំ ១៩៤៤ (ម.៥២/១៦) ។

ច្បាប់ក្រមសាមណេរៈ ហ្លួងទិពន្ធមន្ត្រី ញ៉ុក-ថែម, ទ.ក. ១២, ទំព័រ ៩៤០, ឆ្នាំ ១៩៤៩ (ម.៥២/២១) ។

ច្បាប់តែងឆង្គណា: (ជាខេមរភាសា): អ្នកឧញ៉ាសុត្តន្តប្រីជាឥន្ទ, ទ.ក. ៤, ទំព័រ ១៧១, ឆ្នាំ ១៩៤៧ (ម.៥២/១៩) ។

ច្បាប់ថ្មីប្រដៅកិច្ចការផ្សេង ៗ : ទ. ក. ៤-៥-៦, ទំព័រ ១៥៣, ឆ្នាំ ១៩៣៧ (ម.៥២/៩) ។

ច្បាប់ទូន្មានកុមារ-កុមារី: លោកកឹយ-ប៊ុក, ទ.ក.១, ទំព័រ៥, ឆ្នាំ ១៩៥០ (ម.៥២/២២) ។

ច្បាប់ទូន្មានខ្លួន: ទ.ក. ៤, ទំព័រ ១០, ឆ្នាំ ១៩៤២ (ម.៥២/១៤) ។

ច្បាប់បណ្ដាំបិតា : ទ.ក. ២១-២២, ទំព័រ៩១៧ ឆ្នាំ១៩៤២ (ម.៥២/១៨) ។

ច្បាប់បន្ទូលថែង: ទ.ក.១, ទំព័រ ២៥, ឆ្នាំ១៩៤៥ (ម.៥២/១៧) ។

ច្បាប់ប្រដៅជនប្រុស-ស្រី: ក្រមង៉ុយ, ទក ៧-៨-៩, ទំព័រ ២០៥, ឆ្នាំ ១៩៣៣ (ម.៥២/៩) ។

ច្បាប់ប្រុស: ទ.ក ១៧-១៨, ទំព័រ ១២, ឆ្នាំ ១៩៤២ (ម.៥២|១៤) ។

ច្បាប់ពាក្យចាស់: ទ.ក. ១, ទំព័រ ៤១, ឆ្នាំ ១៩៤២ (ម.៥២/១៤) ។

ច្បាប់មហាជេតិកជសួស្តី: ទ.ក. ២៣-២៤, ទំព័រ ១០, ឆ្នាំ ១៩៤២ ( ម.៥២|១៤ ) ។

ច្បាប់កជជេតិ. ទ.ក ២១-២២, ទំព័រ១១, ឆ្នាំ ១៩៤២ (ម.៥២|១៤) ។

ច្បាប់លោកនិងច្បាប់ធម៌: ឃុនបណ្ណានុក្រម ប៊ូ-ប៉ូ, ទ.ក៩, ទំព័រ ៨២៤, ឆ្នាំ១៩៥៦ (ម. ៥២|២៨) ។

ច្បាប់វិធូរបណ្ឌិត (កាព្យ): ទ.ក.២, ទំព័រ ៤២, ឆ្នាំ១៩៤២ (ម.៥២|១៤) ។

ច្បាប់សុភាសិត: អ្នកឧកញ៉ាវង្សាសារពេជ្ញ នង, ទ.ក.១, ទំព័រ១២, ឆ្នាំ ១៩៤១ (ម ៥២|១៣) ។

ច្បាប់ស្រី: ព្រះបាទអង្គឌួង ទ.ក. ១, ទំព័រ៣៩, ឆ្នាំ ១៩៥៩ (ម. ៥២|៣១) ។

ច្បាប់ស្រី: ទ.ក.១៩-២០, ទំព័រ ១៤, ឆ្នាំ ១៩៤២(ម. ៥២|១៤) ។

ច្បាប់ហៃឡេះឃាជនៈ ទ.ក. ២១ ២២, ទំព័រ ២៤, ឆ្នាំ ១៩៤២ (ម.៥២/១៤) ។

ច្បាប់អរិយសត្តា: ទ.ក.១៩-២០, ទំព័រ២៦, ឆ្នាំ ១៩៤២ (ម.៥២/១៤) ។

ឆ្នាក់ឱ្យទៅ: ម.រឿងព្រេង ប្រាប់ពួកពាក្យថា ,,វែកឆ្នាក់ឱ្យទៅ,, ។

ឆ្អែសត្វឡៃហ្សុនៈ លោក ផេង-ជ្រីវ, ទ.ក.១១, ទំព័រ១០៨២, ឆ្នាំ១៩៥៦ (ម.៥២/៣១) ។

ឆ្នាំងវែងអណ្តូងវែង (រឿង): ទ.ក.១២, ទំព័រ ៦៣, ឆ្នាំ ១៩៤៣ (ម ៥២/១៥) ។

ញុងនង្វៃ: លោក ចាប-ពិន, ទ.ក. ១០, ទំព័រ ៧៨៣ ឆ្នាំ ១៩៥៣ (ម.៥២/២៥) ។

ជនជាតិផ្សេងៗក្នុងឥណ្ឌូចិន (អំពី): ទ.ក.១៧, ទំព័រ១១, ឆ្នាំ ១៩៤១ (ម.៥២/១៣) ។

ជនជាតិអាមេរិកាំង: លោក ផេង-ជ្រីវ, ទ.ក ៧, ទំព័រ ៧២៨, ឆ្នាំ ១៩៦៤ (ម.៥២/៣៦) ។

ជម្ងឺឆ្លងពីញ្ញកាខ្ទុះ (អំពី): ជីវិតគោមារភត្យ ទ.ក ២០, ទំព័រ ៦, ឆ្នាំ ១៩៤១ (ម.៥២/១៣) ។

ជម្ងឺមេគ្រុនិងជម្ងឺរិទ្យ : លោកវេង-ជួរ, ទ.ក ៣, ទំព័រ ២៧៧, ឆ្នាំ១៩៦៤ (ម.៥២/៣៦) ។

ជម្ពុជម្ពូ : ហង្សនិពន្ធមន្ត្រី ញ៉ុក-ថែម ទ.ក. ៦; ទំព័រ ៤៨១, ឆ្នាំ ១៩៤៥ (ម.៥២/១៧) ។

ជយកោដា : ព្រះមហា ក៉ យ៉ាវ ទ.ក. ៤, ទំព័រ ៣០៣, ឆ្នាំ១៩៥៧ (ម.៥២/៤៩) ។ ព្រះធម្មបាលវង្ស សុរ-ហាយ ទ.ក១, ទំព័រ ៣, ឆ្នាំ ១៩៥៦ (ម.៥២/២៨) ។

ជយបរាជយកថា : គង្គ ពត-រ៉ទ ទ.ក ៤, ទំព័រ ៣៥១, ឆ្នាំ១៩៦៤ (ម ៥២/៣៦) ។

ជយសួស្តី (រឿងព្រេង) : លោក ប៊ូ-ប៉ូ, ទ.ក. ៨, ទំព័រ ៨៨៥, ឆ្នាំ ១៩៥៩ (ម.៥២/៣១) ។

ជលយាន (រឿង) : ទ.ក. ៨, ទំព័រ ៨៤៥, ឆ្នាំ ១៩៦៣ (ម.៥២/៣៥) ។

ជាតកភាសុភាសិត : លោកគ្រូព្រះអាចារ្យ ឈាង-សុខ, ទ.ក.៩, ទំព័រ ៤៩៩, ឆ្នាំ ១៩៤៣ (ម.៥២/១៥) ។

ជាតិសត្វខ្លា ពំ (រឿង) : ទ.ក ១០-១១-១២, ទំព័រ ១៣៤, ឆ្នាំ ១៩៣៣ (ម.៥២/៦) ។

ជិតពេកមើលមិនឃើញ : ឃុនបណ្ណនុរក្ស ប៊ូ-ប៉ូ, ទ.ក.១,
ទំព័រ ១៩, ឆ្នាំ ១៩៦៦ (ម.៥២/២៨) ។

ជីវប្រវត្តិនៃព្រះពុទ្ធវង្សកៅ-ស៊ឹម : ភិក្ខុ ចយ-ចេង, ទ.ក ៧,
ទំព័រ ៦៦៣, ឆ្នាំ ១៩៥៨, (ម.៥២/៣០) ។

ជីវប្រវត្តិសង្ខេប (នៃឯ.ឧ ភជគ្រិស្ណាឧអនុប្រធានាធិបតី
នៃសាធារណរដ្ឋឥណ្ឌា) : លោក ក៉យ-ប៊ុក, ទ.ក ៩,
ទំព័រ ៨៦៩, ឆ្នាំ ១៩៥ (ម ៥២/២៩) ។

ជីវប្រវត្តិព្រះសុធម្មបញ្ញាត្រេកែវ-ជួប (ចៅអធិការវត្ត
កោះច្រាក់ កំពង់ចាម) : ព្រះភិក្ខុ ម៉-សាន, ទ ក.៤,
ទំព័រ ៣១២, ឆ្នាំ ១៩៥២ (ម ៥២/២៤) ។

ជីវិតមានប្រយោជន៍ដូចនេះ? : ព្រះសាសនមុនី កឹម-តូរ, ទ.ក.១,
ទំព័រ ១៣, ឆ្នាំ ១៩៦៥ (ម.៥២/៣៧) ។

ជំនឿនាំឲ្យសម្រេចប្រយោជន៍ : អ្នកឧកញ៉ាឥស្សរវង្សា សំ-ស៊ុន
ទ.ក ៦, ទំព័រ ៣១២, ឆ្នាំ ១៩៤៨ (ម.៥២/១៩) ។

ជ្រកកតប្ចក (រឿង) : លោក ហេង-សមអាន, ទ.ក.១២, ទំព័រ
១៤១១, ឆ្នាំ ១៩៦០ (ម ៥២/៣២) ។

ញាណកោសរប្បវត្តិ : ឃុនសិរីមេធីស្រ៊ី-អ៊ូ, ទ.ក. ១០, ទំព័រ
៧៩៦, ឆ្នាំ ១៩៤៨ (ម.៥២/២០) ។

ឈ្មោះខ្លួនឯងប្រសើរបំផុត : លោក យូរ-អ៊ុន, ទ.ក. ៦, ទំព័រ ៤០៨, ឆ្នាំ ១៩៥៥ (ម.៥២/២៧) ។

ឈ្មួញម្នាក់ (រឿងព្រេង) : ទ.ក ១១, ទំព័រ ២៥, ឆ្នាំ ១៩៤១ (ម.៥២/១៣) ។

ជន្លេនិងក្អែកដោះប្រស្នាគ្នា : ទ.ក ២-៣, ទំព័រ ៦៣, ឆ្នាំ ១៩៣៥ (ម.៥២/៧) ។

ដឹងសងដឹង អំបែងសងអំបែង : ទ.ក ២, ទំព័រ ៥១, ឆ្នាំ ១៩៤២ (ម.៥២/១៤) ។

ដូនចាស់ម្នាក់ ឈ្មោះតាច្នានិសែន ឧទ្ទិសផលទៅឲ្យ ខ្មោចជនមិសុចរិត : ព្រះសាសនមុនី កិម-តូរ, ទ.ក ១០, ទំព័រ ១០២៧ ឆ្នាំ ១៩៦៣ (ម.៥២/៣៥) ។

ដើមកំណើតទីក្រុងភ្នំពេញក្នុងសតវត្សទី ១៥ : អ្នកស្រីសារិះយ៉ាន, ទ.ក ៣, ទំព័រ ២២៩, ឆ្នាំ ១៩៥៧ (ម.៥២/២៩) ។

ដើមកំណើតនិងការវិវត្តន៍នៃអារ្យធម៌ខ្មែរ : លោក លី-ធាមតេង ទ.ក ១០, ទំព័រ ១០៤១, ឆ្នាំ១៩៦៣ (ម.៥២/៣៥) ។

ដើមកំណើតប្រាសាទអង្គរ : លោក លុំហ៊ីណូត, ទ.ក ៣, ទំព័រ ៤៣, ឆ្នាំ ១៩២៧ (ម.៥២/២) ។

ដើមកំណើតរបាំ : លោក សិន-ហ៊ិន ទ.ក ៣, ទំព័រ ៣៣៨,
ឆ្នាំ ១៩៥៩ (ម.៥២/៣១) ។

ដើមកំណើតរឿងកមកេរ្តិ៍ : លោក តាប-ពិន ទ.ក ១១,
ទំព័រ ១៩២៧, ឆ្នាំ ១៩៥៨ (ម.៥២/៣០) ។

ដើមកំណើតល្បែងទាញពត្រ : លោក តាប-ពិន, ទ.ក១២,
ទំព័រ ១១២៤, ឆ្នាំ ១៩៥៨ (ម.៥២/៣០) ។

ដើមកំណើតសករាជ (អំពី) : លោក ប៊ូ-ប៊ូ, ទ.ក ៨, ទំព័រ
៥៨៦, ឆ្នាំ ១៩៥៤ (ម.៥២/២៦) ។

ដោយប្រការយ៉ាងណាខ្លះ ដែលគេគោរពព្រះបរម-
សម្មាសម្ពុទ្ធក្នុងស្រុកកណ្ដា : លោក ស-ប៊ុណ្ណ,
ទ.ក ១-២-៣, ទំព័រ ១៧, ឆ្នាំ ១៩៣៦ (ម ៥២/៨) ។

ដំណឹងតាមខ្យល់ក្នុងកាត្តា : លោក ផេង-ជ្រីវ, ទ.ក ២,
ទំព័រ ១៤៧, ឆ្នាំ ១៩៥៤ (ម ៥២/២៦) ។

ដំណឹងផ្សេងៗ : ខេមររង្សី, ទ.ក ៧, ទំព័រ ១៧, ទ.ក ១៥, ទំព័រ
២៣, ទ.ក ១៦, ទំព័ ១៨, ឆ្នាំ ១៩៤១ (ម.៥២/១៣) ។
ទ.ក ២, ទំព័រ ៦១, ទ.ក ៣, ទំព័រ ៤៥, ទ.ក ៤, ទំព័រ ៦៧
ទ.ក ៦, ទំព័រ ៩១, ទ.ក ៩, ទំព័រ ៤៧, ទ.ក ១១, ទំព័រ៥៩,
ឆ្នាំ ១៩៤០ (ម.៥២/១២) ។

ដំណើរពុទ្ធសាសនាក្នុងនានាប្រទេស : ហូនទិពទន្មត្រី ញ៉ុក-ថែម ទ.ក ១, ទំព័រ ៧៤, ឆ្នាំ ១៩៥០ (ម.៥២/៤២) ។

ដំណើរគណៈប្រតិភូខ្មែរទៅប្រជុំសន្និសីទនៅពុទ្ធយាគា ប្រទេសឥណ្ឌា : លោក ចាប-ពិន, ទ.ក ៦, ទំព័រ ៥៩៨, ឆ្នាំ ១៩៥៦ (ម.៥២/២៨) ។

ដំណើរជីវិត : ឃុនបណ្ណានុរក្ស ប៊ូ-ប៉ូ, ទ.ក ៤, ទំព័រ ៣០៣, ឆ្នាំ ១៩៥៦ (ម ៥២/២៨) ។

ដំណើរជីវិតនៃសត្វល្អិតៗ (ពិពិ) : លោក សង់.ហង់ហ្វាប, ទ.ក ១-២-៣, ទំព័រ ៣៦, ឆ្នាំ ១៩៤៣ (ម.៥២/១៥) ។

ដំណើរទស្សនាការសហរដ្ឋអាមេរិក នៃព្រះតេជព្រះគុណព្រះពោធិវង្ស ហួត-តាត : លោក ជា-ទន់ ទ.ក៨, ទំព័រ ៧៦៩, ឆ្នាំ ១៩៥៧ (ម.៥២/២៩) ។

ដំណើរទៅកាន់ប្រទេសភូមានៃប្រតិភូ ៨ រូប : ព្រះញាណវីរិយ ក៉ន-សាឌុំ, ទ.ក ៦, ទំព័រ ៥៨៨, ឆ្នាំ ១-៥៦ (ម.៥២/២៨) ។

ដំណើរទៅកាន់ស្រុកភ្នងលើ : ព្រះវិសុទ្ធិវង្ស ហួត-តាត (ក្របេះ): ទ.ក ១-២-៣, ទំព័រ ១៧, ឆ្នាំ ១៩៣៣ (ម.៥២/៦)។

ដំណើរទៅខេត្តកំពង់ស្ពឺមានជ័យ : លោក ហ៊ុន-សារី, ទ.ក៥, ទំព័រ ៥៣០, ឆ្នាំ ១៩៦៥ (ម.៥២/៣៧) ។

ដំណើរទៅកាន់ប្រទេសឥណ្ឌា នៃលោកកៃយ-ប៊ុក : លោកកៃយ-ប៊ុក, ទ.ក ២, ទំព័រ ១៨៨, ឆ្នាំ ១៩៥៧ (ម.៥២/២៩) ។

ដំណើរនិមន្តទៅកាន់ប្រទេសភូមា : ព្រះទេពសត្ថា កិម-ត៊ូរ, ទ.ក ១១, ទំព័រ ៨៦៦, ឆ្នាំ ១៩៥៤ (ម.៥២/២៦) ។

ដំណើរមកកាន់ប្រទេសកម្ពុជានៃមហាបណ្ឌិតកុណាលប៉ិយសេនម៉ាឡាល័រសេកែរ : ទ.ក ៧, ទំព័រ ៥៥០, ឆ្នាំ ១៩៥១ (ម.៥២/២៣) ។

ដំណើរមកកាន់ពុទ្ធសាសនបណ្ឌិត្យ នៃឯកឧត្តមបណ្ឌិតរាជេន្ទ្រប្រសាទអនុប្រធានាធិបតី នៃសាធារណរដ្ឋឥណ្ឌា : លោកកៃយ-ប៊ុក, ទ.ក ៨, ទំព័រ៧៨១, ឆ្នាំ ១៩៥៧ (ម.៥២/២៩) ។

ដំណើរអស្ចារ្យនៃលោក កំស្យូប៉ុយ្យូយេ : លោកកៃយ-ប៊ុក, ទ.ក ២, ទំព័រ ១៣៥, ឆ្នាំ ១ ៥៤ (ម.៥២/២៦) ។

( នៅមានត )

# ផ្នែកកំណត់និងប្រវត្តិការណ៍

## ពិធីប្រគល់ព្រះរាជអំណោយ
## នៃសម្តេចព្រះប្រមុខរដ្ឋ ចំពោះពុទ្ធិកវិទ្យាល័យ

កាលពីថ្ងៃចន្ទ័ទី ២១ កុម្ភៈ ១៩៦៦ ពេលម៉ោង ៩ ព្រឹក, នៅក្នុងសាលនៃបណ្ណាល័យពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ, មានពិធីប្រគល់បច្ច័យជាព្រះរាជអំណោយ នៃសម្តេចព្រះប្រមុខរដ្ឋចំនួនមួយលានរៀល ប្រគេនចំពោះ សម្តេចព្រះពោធិវង្ស អគ្គាធិការនៃពុទ្ធិកសិក្សា ក្រោមអធិបតីភាព នៃឯកឧត្តម សាន យុន ជាព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់ នៃសម្តេចឪ ដើម្បីឧបត្ថម្ភក្នុងការរុះរើកសាងជាថ្មី នូវអគារសិក្សាពុទ្ធិក-វិទ្យាល័យព្រះសុរាម្រឹត ដែលមានសភាពចាស់គ្រាំគ្រាទ្រុឌទ្រោម ឲ្យត្រឡប់បានជាអគារថ្មីមាំមួនឡើងវិញ ។

ក្នុងពិធីនេះ, ផ្នែកខាងព្រះសង្ឃ គឺមានសម្តេចព្រះពោធិវង្សជាប្រធាន ព្រមទាំងព្រះសង្ឃជាសាស្ត្រាចារ្យទាំងឡាយ នៃពុទ្ធិកមហា-វិទ្យាល័យព្រះសីហនុរាជ និងពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត មានព្រះមហាប៉ាង-ខាត់, ព្រះឥន្ទមុនី សេខ-នាង, ព្រះញាណសត្ថា ប៉ែន-សុខ, ព្រះពុទ្ធឃោសាចារ្យ ជាច់-គឹង ជាដើម ។ ផ្នែកខាងគ្រហស្ថ, មានសហជីវិន ទេព-ភិញ អនុរដ្ឋលេខាធិការក្រសួងធម្មការ, ព្រមទាំងសហការីទាំងឡាយ គឺសហជីវិន ច័ន្ទ-សុន នាយកការិយាល័យ,

សហជីវិន សេង-ពុំ នាយខុទ្ទកាល័យ, សហជីវិន តែ-ម៉េង-ហាប់ អគ្គ-លេខាធិការ ពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ, សហជីវិនថាច់-សេវ៉ាញ ទីប្រឹក្សាបច្ចេកទេស នៃអគ្គាធិការដ្ឋានពុទ្ធិកសិក្សា សហជីវិន លាង-ហាប់អាន នាយកពុទ្ធសាសនបណ្ឌិត្យ, សហជីវិន លិម-លាងជិន អគ្គ-លេខាធិការពុទ្ធសាសនបណ្ឌិត្យ និងសហការីព្រមទាំងសាស្ត្រាចារ្យភេទគ្រហស្ថជាច្រើនទៀត ដែលយើងសូមអភ័យទោសដោយពុំបានរៀបរាប់នាមសព្វគ្រប់គ្នាទីនេះ ។

មុននឹងប្រគេននូវព្រះរាជអំណោយដ៏ថ្លៃថ្លានេះ ឯកឧត្តម សាន យុន ជាព្រះរាជតំណាងបានថ្លែងនូវសុន្ទរកថាមួយដ៏ខ្លី ហើយសម្តេចព្រះពោធិវង្ស ក៏បានថ្លែងសុន្ទរកថាទទួលអំណរតបវិញ ដូចមានសេចក្តីទាំងស្រុង ដែលយើងចុះផ្សាយខាងក្រោមនេះ ។

នៅពេលចប់ពិធី, សម្តេចព្រះពោធិវង្ស បានអញ្ជើញ ឯកឧត្តមព្រះរាជតំណាងទៅទស្សនាអគារទាំងឡាយ នៃពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ដែលបានរុះរើកសាងជាថ្មីរួចហើយ និងកំពុងកសាងជាបន្តទៅទៀត ។

## សុន្ទរកថា

នៃឯកឧត្តម សាន-យុន ជាព្រះរាជតំណាង ក្នុងឱកាសនៃពិធីប្រគល់ហិរញ្ញវត្ថុចំនួន ១លានរៀល ចំពោះសម្តេចព្រះពោធិវង្ស ដើម្បីរុះរើកសាងជាថ្មី នូវអគារ ១ ខ្នង នៃពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត នៅថ្ងៃទី ២១ កុម្ភៈ ១៩៦៦ វេលាម៉ោង ៩ ព្រឹក ។

សូមនមស្ការ សម្តេចព្រះពោធិវ័ង្ស

សូមពិត ព្រះថេរានុត្ថេរគ្រប់អង្គ

សូមជំរាប លោកអនុរដ្ឋលេខាធិការក្រសួងធម្មការ និងអស់លោកទាំងឡាយ

បច្ច័យចំនួនមួយលានរៀល « ១.០០០ ០០០រ០០ » ដែលតម្កល់ទុកក្នុងទីចំពោះព្រះភក្ត្រ នៃសម្តេច ព្រះថេរានុត្ថេរៈគ្រប់អង្គ និងចំពោះមុខអស់លោកនេះ ជាព្រះរាជអំណោយនៃសម្តេចព្រះប្រមុខរដ្ឋ ដែលទ្រង់សព្វព្រះរាជហឫទ័យបរិច្ចាគជាវិភាគទាន ដើម្បីទបត្ថម្ភកិច្ចការរុះរើអគារសិក្សា នៃពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ដែលមានសភាពចាស់គ្រាំគ្រាទ្រុឌទ្រោម ហើយសាងជាថ្មីឡើងវិញ ។

ខ្ញុំព្រះករុណា ខ្ញុំ មានសេចក្តីរីករាយក្រៃពេកណាស់ ដោយបានទទួលនូវកិត្តិយសដ៏ខ្ពង់ខ្ពស់ជាព្រះរាជតំណាង នៃសម្តេចព្រះប្រមុខរដ្ឋ មកធ្វើជាអធិបតីក្នុងពិធីប្រគល់ប្រគេននូវបច្ច័យដែលមានចំនួនដូចខាងលើនេះ ចំពោះសម្តេចព្រះពោធិវ័ង្ស ដែលព្រះអង្គបានយកព្រះទ័យទុកដាក់ទទួលភារៈកិច្ចការសាងសាបនាអគារសិក្សានៅពុទ្ធិកវិទ្យាល័យ ព្រោះព្រះអង្គធ្លាប់ជាទីទុកព្រះរាជហឫទ័យនៃសម្តេចព្រះប្រមុខរដ្ឋ ។

ឥឡូវនេះ ខ្ញុំព្រះករុណា សូមប្រគល់ប្រគេនចំពោះសម្តេច នូវ

បច្ច័យមួយលានរៀល " ១.០០០.០០០៛០០ " នេះ សូមសម្ដេចទទួលយក ហើយចាត់ការរុះរើកសាងជាថ្មី នូវអគារសិក្សាណាដែលសម្ដេចយល់ឃើញថា ត្រូវរុះរើកសាង ដើម្បីឲ្យអគារសិក្សាទាំងនោះបានមាំ-មួនល្អឡើងវិញ ឲ្យបានសមតាមព្រះរាជបំណង នៃសម្ដេចព្រះប្រមុខរដ្ឋជាព្រះអគ្គពុទ្ធសាសនូបត្ថម្ភ ។

## សុន្ទរកថា

នៃសម្ដេចព្រះពោធិវ័ង្ស អគ្គាធិការនៃពុទ្ធិកសិក្សា ក្នុងឱកាសនៃពិធីប្រគល់បច្ច័យមួយលានរៀល ជាព្រះរាជទាននៃសម្ដេចព្រះប្រមុខរដ្ឋ ដែលមានឯកឧត្តមសាន-យុន ជាអធិបតី នៅថ្ងៃបន្ទី ២១ កុម្ភៈ ១៩៦៦ ។

សូមចម្រើនពរ ឯកឧត្ដម ជាព្រះរាជតំណាង

សូមចម្រើនពរ លោកអនុរដ្ឋលេខាធិការ ក្រសួងធម្មការ និងអស់លោកទាំងឡាយ

អាត្មាភាព មានបីតិសោមនស្សរីករាយជាទីបំផុត ចំពោះឯកឧត្តមជាព្រះរាជតំណាង ដែលបានអញ្ជើញមកជាអធិបតី ក្នុងពិធីប្រគល់នូវបច្ច័យមួយលានរៀល (១.០០០.០០០៛០០) ជាព្រះរាជអំណោយនៃសម្ដេចព្រះប្រមុខរដ្ឋ ដើម្បីឧបត្ថម្ភក្នុងការរុះរើកសាងជាថ្មីនូវអគារសិក្សា នៃពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ដែលបានកសាងយូរហើយ មានសភាព

ចាស់ទ្រុឌទ្រោមឲ្យបានត្រឡប់ជាអគារថ្មី មាំមួនល្អឡើងវិញ ។

អាត្មាភាព សូមទទួលដោយគោរព នូវបច្ច័យចំនួនមួយលានរៀល ជាព្រះរាជអំណោយ នៃសម្តេចព្រះប្រមុខរដ្ឋ ដែលឯកឧត្តមជាព្រះរាជតំណាងបានប្រគល់ប្រគេនមកអាត្មាភាព ក្នុងពិធីបុណ្យរៃនេះ ដោយសោមនស្សចេតនា ដ៏រំភើបយ៉ាងខ្លាំងក្លាជាទីបំផុត ។

ក្នុងឱកាសនេះ អាត្មាភាពជាតំណាង នៃព្រះសង្ឃទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជា មានសម្តេចព្រះសង្ឃរាជទាំងពីរព្រះអង្គជាប្រធាន និងជាតំណាង នៃពុទ្ធបរិស័ទទាំងអស់ សូមថ្លែងនូវកតញ្ញុតាធម៌យ៉ាងជ្រាលជ្រៅបំផុត ចំពោះព្រះករុណាធិគុណនៃសម្តេចព្រះ នរោត្តម សីហនុ ព្រះប្រមុខរដ្ឋ នៃប្រទេសកម្ពុជា ព្រះអង្គជាព្រះអគ្គពុទ្ធសាសនូបត្ថម្ភក៍ ដែលទ្រង់មានព្រះរាជហឫទ័យ ប្រកបដោយសប្បុរសធម៌ជានិច្ចនិរន្តរ៍ ក្នុងការជួយឧបត្ថម្ភព្រះពុទ្ធសាសនាគ្រប់វិស័យ ដើម្បីលើកតម្កើងព្រះពុទ្ធសាសនា ឲ្យមានការលូតលាស់ចម្រើនរុងរឿង ទាំងខាងផ្នែកសម្ភារៈ ទាំងខាងផ្នែកសិក្សា ។

ចំពោះខាងផ្នែកសម្ភារៈដែលទាក់ទងនឹងការសិក្សា អាត្មាភាពសូមឱកាស ឯកឧត្តមជាព្រះរាជតំណាងបន្តិច ដើម្បីថ្លែងរំលឹកឡើងវិញ នូវព្រះរាជអំណោយនៃសម្តេចព្រះប្រមុខរដ្ឋ អគ្គពុទ្ធសាសនូបត្ថម្ភក៍ ដែលទ្រង់ប្រោសព្រះរាជទាន ចំពោះការកសាងអគារសិក្សា នៅពុទ្ធិក

មហាវិទ្យាល័យព្រះសីហនុរាជ និងពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ដែលអាត្មាភាពបានចាំជាក់ដោយផ្ទាល់ខ្លួនដូចតទៅនេះ :

-កាលពិធីបញ្ចុះបឋមសិលា កសាងអគារសិក្សាទី ១ នៃពុទ្ធ-មហាវិទ្យាល័យព្រះសីហនុរាជ ពីឆ្នាំ ១៩៥៤ សម្តេចប្រមុខរដ្ឋ កាលព្រះអង្គគង់នៅលើព្រះរាជបល្ល័ង្កនៅឡើយ ទ្រង់បានធ្វើព្រះរាជអំណោយក្នុងការកសាងនោះចំនួនដប់ម៉ឺនរៀល (១០០.០០០រ០០)

-កាលក្នុងឱកាសដែលព្រះអង្គដាក់រាជសម្បត្តិពីឆ្នាំ ១៩៥៥ សម្តេចព្រះប្រមុខរដ្ឋ ទ្រង់បានប្រោសព្រះរាជទាន មួយលានប្រាំសែនរៀល (១.៥០០.០០០រ០០) ។ ក្នុងការជួយកសាងអគារសិក្សា នៃពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ ។

- កាលក្នុងឱកាស នៃពិធីប្រគេនសញ្ញាប័ត្រឧត្តមសិក្សាបឋមភូមិដល់សមណនិស្សិត ដែលប្រឡងជាប់ជាលើកដំបូង ពីឆ្នាំ ១៩៦២ សម្តេចព្រះប្រមុខរដ្ឋ ទ្រង់បានធ្វើព្រះរាជអំណោយ មួយលានរៀល (១.០០០.០០០រ០០) ។

- កាលក្នុងឱកាសនៃពិធីសម្ពោធធ្វើគ្រឹះស្ថាន សម្តេចព្រះនរោត្តមសីហនុ ក្នុងបរិវេណនៃពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ពីឆ្នាំ ១៩៦៣ សម្តេចព្រះប្រមុខរដ្ឋ ទ្រង់បានប្រោសព្រះរាជទាន ពីរលានរៀល

( ២.០០០.០០០ ៛ ០០ ) ដើម្បីឡើងកសាងជាថ្មី នូវអគារសិក្សា ចាស់ ២ ខ្នង ។

- ក្នុងថ្ងៃនេះ សម្ដេចព្រះប្រមុខរដ្ឋទ្រង់ប្រោសព្រះរាជទានមួយ-លានរៀល ( ១.០០០.០០០ ៛ ០០ ) ទៀត ដើម្បីឡើងកសាងជាថ្មី នូវអគារជាវិស្រមសាលដែលជាប់ជាមួយនឹងអគារសិក្សា ។

របរមព្រះរាជអំណោយទាំងអស់ខាងលើនេះ ឃើញចំនួន ប្រាំ-លានប្រាំមួយសែនរៀល ( ៥.៦០០.០០០៛០០ ) ហើយ ។

ដោយអាស្រ័យព្រះរាជអំណោយនៃសម្ដេចព្រះប្រមុខរដ្ឋ ជាព្រះអគ្គពុទ្ធសាសនូបត្ថម្ភក៏ ដែលមានព្រះរាជហឫទ័យប្រកបដោយសប្បុរស-ធម៌ដ៏ធំទូលាយនេះហើយ ទើបអគារសិក្សានៅពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ ដែលមានបន្តិចបន្តួច ក៏ត្រឡប់ជាមានបរិបូណ៌ឡើង ចំណែកអគារសិក្សានៅពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ដែលមានសភាពចាស់ទ្រុឌទ្រោម ក៏បានត្រឡប់ប្រែក្លាយទៅជាអគារសិក្សាថ្មី ១ មាន ២ ជាន់ ហើយមាំមួន អាចនឹងឋិតនៅបានជាស្ថាពរអស់កាលយូរអង្វែងទៅក្នុងអនាគត ។

សព្វថ្ងៃនេះ ខាងផ្នែកពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត នៅសល់តែអាគារមួយខ្នងទៀតនៅភាគខាងជើង ដែលជាវិស្រមសាលហៅតាមភាសាបារាំងថា préau ជាប់ជាមួយគ្នានឹងអគារសិក្សា ជាអគារធំ

ហើយវែងជាង ៩០ ម៉ែត្រ នៅពុំទាន់បានរុះរើកសាងនៅឡើយ ។ ឥឡូវនេះ ដោយអាស្រ័យព្រះរាជអំណោយមួយលានរៀល ដែលអាត្មាភាពទើបនឹងបានទទួលអម្បាញ់មិញនេះ អាត្មាភាពនឹងចាត់ការរុះរើអគារវិស្សមសាលនោះ ក្នុងពេលជាបន្ទាន់នេះ ហើយនឹងចាប់ក. សាងជាថ្មី ឲ្យបានជាអគារមួយមាន ២ ជាន់ ឲ្យបានសមរម្យដូចអគារឯទៀត ៗ ដែលបានស្ថាបនារួចហើយ ។

អាត្មាភាពមានសង្ឃឹមថា អគារវិស្សមសាលជាប់ជាមួយនឹងអគារសិក្សា ដែលនឹងស្ថាបនាក្នុងពេលជាបន្ទាន់នេះ មុខជានឹងបានទទួលនូវព្រះបរមរាជូបត្ថម្ភ អំពីសម្ដេចព្រះប្រមុខរដ្ឋត្រាតែបានរួចស្រេច ក្នុងឆ្នាំ ១៩៦៦ នេះ ។

អាត្មាភាព សូមកត់សំគាល់នូវព្រះរាជអំណោយនៃសម្ដេចព្រះប្រមុខរដ្ឋនេះ ជាព្រះរាជអំណោយជួយលើកស្ទួយព្រះពុទ្ធសសនា ជាព្រះរាជអំណោយជួយគាំទ្រទប់ទល់ព្រះពុទ្ធសាសនា ឲ្យមានជំហររឹងប៉ឹងតទៅក្នុងអនាគត ។

ឯកឧត្តមព្រះរាជតំណាង មុននឹងបញ្ចប់នេះ អាត្មាភាពសូមបញ្ជាក់ថា គុណសម្បត្តិដ៏ប្រសើរ និងព្រះរាជហឫទ័យបរិសុទ្ធប្រកបដោយការគោរពនិងក្ដីស្នេហា ចំពោះព្រះពុទ្ធសាសនា របស់សម្ដេចព្រះប្រមុខរដ្ឋ អាចដឹកនាំភាពញចិត្តព្រះសង្ឃទាំងប្រទេស និងពុទ្ធបរិស័ទទាំងអស់

ឲ្យមានសេចក្តីស្វាមីភក្តិចំពោះព្រះអង្គឥតកម្រើក ឲ្យមានសេចក្តីស្មោះត្រង់ចំពោះព្រះអង្គឥតល្អៀង ពុំអាចមានអ្នកណាមួយមកបំបែកបំបាក់ ឬឲ្យកន្ត្រប្រែឲ្យបានឡើយ ។ សេចក្តីស្វាមីភក្តិ និង សេចក្តីស្មោះត្រង់របស់ព្រះសង្ឃ និង ពុទ្ធបរិស័ទទាំងអស់ ចំពោះសម្តេចព្រះប្រមុខរដ្ឋ អាចឋិតនៅយ៉ាងខ្ជាប់ខ្ជួនរហូតដល់អវសាន ។

អាត្មាភាពសូមឧទ្ទិសព្រះរាជកុសល ដែលកើតឡើងអំពីព្រះរាជអំណោយនេះ ថ្វាយចំពោះសម្តេចព្រះមហាក្សត្រិយានី និងសម្តេចព្រះប្រមុខរដ្ឋ សូមព្រះអង្គបានប្រកបដោយព្រះសុខភាពបរិបូណ៌ មានព្រះជន្មទីឃាយុយឺនយូរ និងប្រកបដោយសិរីសួស្តីជយមង្គលវិបុលសុខ ព្រមទាំងប្រកបដោយជោគជ័យ ឈ្នះអស់មារសត្រូវគ្រប់ទិសទី ជានិច្ចនិរន្តរ៍តរៀងទៅ ។

អាត្មាភាព សូមជូនពរជាពិសេស ចំពោះឯកឧត្តមជាព្រះរាជតំណាង ដែលបានអញ្ជើញមកជាអធិបតី ក្នុងពិធីប្រគល់ព្រះរាជអំណោយនេះ សូមឯកឧត្តម បានប្រកបដោយពុទ្ធពរទាំង ៤ ប្រការ គឺ អាយុ វណ្ណៈ សុខៈ និង ពលៈ តរៀងទៅ កុំបីឃ្លៀងឃ្លាតឡើយ ។